# ការពន្យល់ច្បាប់ស្តីពីព្រៃឈើ

~~~~~~~~~

## ជំពូកទី ១៤

## នីតិវិធីដោះស្រាយបទល្មើសព្រៃឈើ

**មាត្រា ៧៦.-**

*បទល្មើសព្រៃឈើជាបទល្មើសព្រហ្មទណ្ឌដែលមានចរិតពិសេសដូចមានចែងក្នុងច្បាប់នេះ ។ រដ្ឋបាលព្រៃឈើមានសមត្ថកិច្ចជាមន្ត្រីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេតបទល្មើសព្រៃឈើ និង ចងក្រងសំណុំរឿងជូនតុលាការ ។*

*ការស្រាវជ្រាវ ទប់ស្កាត់ បង្ក្រាបបទល្មើសព្រៃឈើជាសមត្ថកិច្ចរបស់រដ្ឋបាលព្រៃឈើគ្រប់ថ្នាក់នៅក្នុងរង្វង់ដែនសមត្ថកិច្ចរៀងៗខ្លួន ។*

*ប្រតិបត្តិការរបស់មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ត្រូវអនុវត្តស្របតាមច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។*

- ***បទល្មើសព្រៃឈើជាបទល្មើសព្រហ្មទណ្ឌដែលមានចរិតពិសេសដូចមានចែងក្នុងច្បាប់ស្តីពីព្រៃឈើ :***

បទល្មើសព្រៃឈើមានចរិកដោយឡែកពីបទល្មើសព្រហ្មទណ្ឌ ដែលមានការផ្តន្ទាទោសដាក់ពន្ធនាគារ ឬ ពិន័យជាប្រាក់ ហើយពុំមានចែងនៅក្នុងបទល្មើសព្រហ្មទណ្ឌទូទៅឡើយ គឺជាបទល្មើសដែលមានចែងតែនៅក្នុងច្បាប់ស្តីពីព្រៃឈើ ។ ព្រះរាជអាជ្ញា នគរបាល យោធា កងរាជអាវុធហត្ថ ទោះបីជាបទល្មើសព្រៃឈើកើតឡើងក្នុងដែនដីក្រោមការគ្រប់គ្រងរបស់ខ្លួនក៏ដោយ ក៏ពុំមានសិទ្ធិធ្វើការស្រាវជ្រាវ ស៊ើបអង្កេត និង កសាងសំណុំរឿងជូនតុលាការដូចបទល្មើសធម្មតាបានឡើយ ។ ការស្រាវជ្រាវបទល្មើសព្រៃឈើជាសមត្ថកិច្ចរបស់រដ្ឋបាលព្រៃឈើក្នុងតំបន់គ្រប់គ្រងរបស់ខ្លួន ។ ការចោទប្រកាន់អាចធ្វើទៅបានចំពោះបទល្មើសជាក់ស្តែង ដែលអាចមើលឃើញ និង អាចប៉ះពាល់បាន នៅពេលបានជួបប្រទះជនល្មើសកំពុង ឬ បានធ្វើសកម្មភាពរួចហើយដូចជា: កាប់ឈើ អារឈើ រុករកផល អនុផលព្រៃឈើ កាប់ឆ្ការព្រៃ ដុតព្រៃ ដឹកជញ្ជូន ឬ ធ្វើសន្និធិផល អនុផលព្រៃឈើ ដោយគ្មានការអនុញ្ញាតពីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច ។

- ***រដ្ឋបាលព្រៃឈើមានសមត្ថកិច្ចជាមន្ត្រីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេតបទល្មើសព្រៃឈើ និងចងក្រងសំណុំរឿងជូនតុលាការ :***

ដើម្បីទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ មន្ត្រីរដ្ឋបាលព្រៃឈើត្រូវឆ្លងកាត់ការប្រឡង ហើយត្រូវធ្វើសច្ចាប្រណិធាននៅចំពោះមុខអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។ មានតែមន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ប៉ុណ្ណោះ ទើបមានសមត្ថកិច្ចចងក្រងសំណុំរឿងជូនតុលាការ ។ មន្ត្រីរដ្ឋបាលព្រៃឈើដែលពុំទាន់បានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ មិនអាចធ្វើការចងក្រងសំណុំរឿងជូនតុលាការបានឡើយ ។

- ***ការស្រាវជ្រាវ ទប់ស្កាត់ បង្ក្រាបបទល្មើសព្រៃឈើជាសមត្ថកិច្ចរបស់រដ្ឋបាលព្រៃឈើគ្រប់ថ្នាក់នៅក្នុងរង្វង់ដែនសមត្ថកិច្ចរៀងៗខ្លួន :***

មន្ត្រីរដ្ឋបាលព្រៃឈើគ្រប់ថ្នាក់មានសមត្ថកិច្ចដូចខាងក្រោម :

- *ស្រាវជ្រាវបទល្មើសព្រៃឈើ :* ត្រូវស្វែងរក តាមដាន ឃ្លាំមើល ស៊ើបសួរពត៌មានស្តីពីបទល្មើសព្រៃឈើដែលបម្រុងនឹងកើតឡើង ឬ កើតឡើងនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនតាមនីតិវិធី ។
~~~~~~~~~

- ***ទប់ស្កាត់បទល្មើសព្រៃឈើ :*** ត្រូវចាត់វិធានការជាមុន ធ្វើយ៉ាងណារារាំង និង បង្ការមិនឱ្យបទល្មើសព្រៃឈើកើតមានឡើងនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន តាមរយៈសេចក្ដីជូនដំណឹង ការផ្សព្វផ្សាយជាសាធារណៈ ការដាក់បម្រាម ស្លាកសញ្ញាសំគាល់ ។ល។
- ***បង្ក្រាបបទល្មើសព្រៃឈើ :*** ត្រូវចាត់វិធានការជាក់ស្ដែងចំពោះបទល្មើសដែលកំពុងកើតមាននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដោយធ្វើការឃាត់ខ្លួន ដកហូតវត្ថុតាង ចងក្រងសំណុំរឿង និង បញ្ជូនជនល្មើស ឬ ជនសង្ស័យដែលជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តបទល្មើសទៅតុលាការក្នុងករណីដែលនីតិវិធីនៃការដោះស្រាយបទល្មើសជាសមត្ថកិច្ចរបស់តុលាការ និង ចាប់ឃាត់ ដកហូតវត្ថុតាង និង ចងក្រងសំណុំរឿងបទល្មើសដើម្បីឱ្យជនល្មើសបង់ប្រាក់ពិន័យអន្តរការណ៍ ឬ សងការខូចខាតព្រៃឈើក្នុងករណីដែលនីតិវិធីនៃការដោះស្រាយបទល្មើសជាសមត្ថកិច្ចរបស់រដ្ឋបាលព្រៃឈើ ។

- ***ប្រតិបត្តិការរបស់មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ត្រូវអនុវត្តស្របតាមច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌ :***

ច្បាប់ព្រហ្មទណ្ឌគឺជាសំណុំវិធានបទដ្ឋានគតិយុត្តដែលកំណត់នូវអំពើល្មើស និង គោលការណ៍ដាក់ទោសទណ្ឌដល់ជនល្មើសឱ្យរាងចាល ដើម្បីការពារទ្រព្យសម្បត្តិរដ្ឋ និង ថែរក្សាការពាររបៀបរៀបរយសាធារណៈ ។ ព្រហ្មទណ្ឌពិសេសជាច្បាប់ដែលប្រើសំរាប់អង្គភាពរដ្ឋនីមួយៗដូចជាច្បាប់ស្ដីពីព្រៃឈើ ច្បាប់ស្ដីពីជលផលជាដើម ។

រាល់ប្រតិបត្តិការរបស់មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ត្រូវអនុវត្តស្របតាមច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌ គឺទាក់ទងទៅនឹងដំណើរការព្រហ្មទណ្ឌទាំងមូល ដោយចាប់ផ្ដើមពីបទល្មើសនោះត្រូវបានរកឃើញ ឬ រាយការណ៍ ហើយអាចឆ្លងកាត់ដំណាក់កាលជាច្រើនផ្សេងទៀតដូចជាដំណាក់ការស៊ើបអង្កេត ការឃាត់ខ្លួន ការដកហូតវត្ថុតាង ការចងក្រងសំណុំរឿង និង ការបញ្ជូនជនល្មើស ឬ ជនសង្ស័យទៅតុលាការ ។

**មាត្រា ៧៧.-**

*នៅពេលបំពេញបេសកកម្មស្រាវជ្រាវ ទប់ស្កាត់ និង បង្ក្រាបបទល្មើសព្រៃឈើ មន្ត្រីរដ្ឋបាលព្រៃឈើត្រូវស្លៀកពាក់ឯកសណ្ឋាន ពាក់សញ្ញាសំគាល់ ពាក់ឋានន្តរសក្តិ និង ត្រូវមានលិខិតបញ្ជាបេសកកម្ម ។*

*មន្ត្រីរដ្ឋបាលព្រៃឈើសច្ចាប្រណិធានបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌បាន លុះត្រាតែសាមីខ្លួនបានទទួលនីតិសម្បទាពីអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។*

*មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ត្រូវធ្វើ និង ចុះហត្ថលេខាលើកំណត់ហេតុបទល្មើសព្រៃឈើតាមដែនសមត្ថកិច្ចរបស់ខ្លួន ។*

*សំលៀកបំពាក់ឯកសណ្ឋាន សញ្ញាសំគាល់ និងឋានន្តរសក្តិរបស់មន្ត្រីរដ្ឋបាលព្រៃឈើត្រូវកំណត់ដោយអនុក្រឹត្យ ។*

- ***មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ ត្រូវធ្វើ និង ចុះហត្ថលេខាលើកំណត់ហេតុបទល្មើសព្រៃឈើតាមដែនសមត្ថកិច្ចរបស់ខ្លួន :***

មន្ត្រីរដ្ឋបាលព្រៃឈើមានភារកិច្ចតាមដាន ស្រាវជ្រាវ ទប់ស្កាត់ និង បង្ក្រាបបទល្មើសព្រៃឈើនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ប៉ុន្តែការចងក្រងសំណុំរឿងបទល្មើសព្រៃឈើ (កំណត់ហេតុនៃបទល្មើស) ជាសមត្ថកិច្ចរបស់មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ តាមប្រកាសលេខ ៥០៩ ប្រក.កសក ចុះថ្ងៃទី ១៧-

០៩-២០០៣ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ស្តីពី *ការរៀបចំ និង ការប្រព្រឹត្តទៅរបស់រដ្ឋបាលព្រៃឈើ* និង ប្រកាសរួមលេខ ០៩៧ ប្រក.កសក-កយ/០៦ ចុះថ្ងៃទី ០៦-០៣-២០០៦ របស់ក្រសួងយុត្តិធម៌ និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ស្តីពី *ទំរង់បែបបទនៃកំណត់ហេតុបទល្មើសព្រៃឈើ* ។

**មាត្រា ៧៨.-**

*អាជ្ញាធរដែនដីគ្រប់ថ្នាក់ កងកំលាំងប្រដាប់អាវុធ អាជ្ញាធរគយនិងរដ្ឋាករ អាជ្ញាធរព្រលានយន្តហោះ និងកំពង់ផែ និង អាជ្ញាធរពាក់ព័ន្ធដទៃទៀត ត្រូវបង្កភាពងាយស្រួល និង ជួយផ្តល់កំលាំងសហការក្នុងការស្រាវជ្រាវ ទប់ស្កាត់ និង បង្ក្រាបបទល្មើសព្រៃឈើ ឬ ថែរក្សាវត្ថុតាងបទល្មើសព្រៃឈើជាបណ្តោះអាសន្នក្នុងករណីមានការស្នើសុំពីមន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច ។*

*ក្នុងករណីដែលអាជ្ញាធរទាំងឡាយបានជួបប្រទះនូវបទល្មើសព្រៃឈើជាក់ស្តែង អាជ្ញាធរទាំងនោះ :*

*១- ត្រូវជូនពតិមានជាបន្ទាន់ដល់មន្ត្រីរដ្ឋបាលព្រៃឈើ ឬ ការិយាល័យរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច ដែលនៅជិតបំផុត ។*

*២- អាចឃាត់ខ្លួនជនប្រព្រឹត្តល្មើស និង ចាប់ឃាត់វត្ថុតាងបទល្មើសជាបណ្តោះអាសន្នរួចបញ្ជូនជាបន្ទាន់ទៅមន្ត្រីរដ្ឋបាលព្រៃឈើដែលទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ ដើម្បីចាត់ការតាមនីតិវិធី ។*

*៣- មិនត្រូវប្រមូលប្រាក់ពិន័យ ឬ រឹបអូសវត្ថុតាងបទល្មើសដោយផ្ទាល់ឡើយ ។*

- ***អាជ្ញាធរដែនដីគ្រប់ថ្នាក់ កងកំលាំងប្រដាប់អាវុធ អាជ្ញាធរគយនិងរដ្ឋាករ អាជ្ញាធរព្រលានយន្តហោះ និងកំពង់ផែ និង អាជ្ញាធរពាក់ព័ន្ធដទៃទៀត ត្រូវបង្កភាពងាយស្រួល និង ជួយផ្តល់កំលាំងសហការក្នុងការស្រាវជ្រាវ ទប់ស្កាត់ និង បង្ក្រាបបទល្មើសព្រៃឈើ ឬ ថែរក្សាវត្ថុតាងបទល្មើសព្រៃឈើជាបណ្តោះអាសន្នក្នុងករណីមានការស្នើសុំពីមន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច :***

ក្នុងការស្រាវជ្រាវ ទប់ស្កាត់ និង បង្ក្រាបបទល្មើសព្រៃឈើ ឬ ថែរក្សាវត្ថុតាងបទល្មើសព្រៃឈើ មន្ត្រីរដ្ឋបាលព្រៃឈើ ត្រូវការកិច្ចសហការពីស្ថាប័នពាក់ព័ន្ធ ព្រោះ:

- បទល្មើសព្រៃឈើខ្លះបង្កឡើងដោយជនប្រដាប់អាវុធ ដែលមានអាវុធនៅជាប់នឹងខ្លួន។ មន្ត្រីរដ្ឋបាលព្រៃឈើជាសមត្ថកិច្ចស៊ីវិល មិនមានអាវុធនោះទេ ដូចនេះដើម្បីការពារសុវត្ថិភាពក្នុងពេលប្រតិបត្តិការ ចាំបាច់ត្រូវមានកិច្ចសហការជាមួយអាជ្ញាធរដែនដី និង អង្គភាពពាក់ព័ន្ធ ពិសេសជាមួយនគរបាលជាតិ កងរាជអាវុធហត្ថ និង កងកំលាំងយោធា។
- ទីតាំងប្រព្រឹត្តបទល្មើសកើតឡើងក្នុងចំណុចសមត្ថកិច្ចផ្សេងទៀត ដូចជាក្នុងកំពង់ផែ ព្រលានយន្តហោះ ស្ថានីយ៍រថភ្លើង បន្ទាយកងកំលាំងប្រដាប់អាវុធ ។ល។
- បទល្មើសកើតឡើងនៅក្នុងតំបន់ព្រៃជ្រៅ តំបន់អសន្តិសុខ ដែលជាឧបសគ្គដល់មន្ត្រីចុះប្រតិបត្តិការ ។
- ងាយស្រួលកំណត់មុខសញ្ញាជនល្មើស និង វត្ថុតាងដែលបានកើតឡើងនៅក្នុងដែនគ្រប់គ្រងរបស់អាជ្ញាធរដែនដីនីមួយៗ ។
- ងាយស្រួលក្នុងការដឹកជញ្ជូនចេញ និង ថែរក្សាវត្ថុតាង។

- ***ត្រូវជូនពតិមានជាបន្ទាន់ដល់មន្ត្រីរដ្ឋបាលព្រៃឈើ ឬ ការិយាល័យរដ្ឋបាលព្រៃឈើមានសមត្ថកិច្ចដែលនៅជិតបំផុត :***

អាជ្ញាធរទាំងឡាយត្រូវរាយការណ៍បទល្មើសព្រៃឈើជាបន្ទាន់មកមន្ត្រី ឬ ស្នាក់ការរដ្ឋបាលព្រៃឈើដែលនៅជិតបំផុត ក្នុងករណីបានជួបប្រទះនូវបទល្មើសព្រៃឈើ ។ ជាទូទៅបទល្មើសព្រៃឈើមានទ្រង់ទ្រាយតូចៗ កើតមាននៅតំបន់ព្រៃជ្រៅ ចល័តពីកន្លែងមួយទៅកន្លែងមួយទៀត ដឹកជញ្ជូនតាមរថយន្តទេសចរណ៍ បង្កប់ក្នុងកសិផល ប្រព្រឹត្តនៅពេលយប់ ធ្វើឱ្យមានការលំបាកក្នុងការតាមដាន និង បង្ក្រាបរបស់សមត្ថកិច្ចរដ្ឋបាលព្រៃឈើ ។

- ***អាចឃាត់ខ្លួនជនប្រព្រឹត្តល្មើស និង ចាប់ឃាត់វត្ថុតាងបទល្មើសជាបណ្តោះអាសន្នរួចបញ្ជូនជាបន្ទាន់ទៅមន្ត្រីរដ្ឋបាលព្រៃឈើ ដែលទទួលនីតិសម្បទាជានគរបាលយុត្តិធមមិដើម្បីចាត់ការតាមនីតិវិធី :***

ក្នុងករណីអាជ្ញាធរទាំងឡាយដែលបានជួបប្រទះបទល្មើសជាក់ស្តែង គឺអាចធ្វើការឃាត់ខ្លួនជនល្មើស និង វត្ថុតាងជាបណ្តោះអាសន្ន (ព្រោះមិនមែនជាសមត្ថកិច្ចរបស់ខ្លួនទេ) រួចបញ្ជូនទៅមន្ត្រីរដ្ឋបាលព្រៃឈើដែលមានសមត្ថកិច្ចនៅជិតបំផុតដើម្បីចាត់ការតាមនីតិវិធី ព្រោះមានតែមន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធមិ ទើបមានសិទ្ធិឃាត់ខ្លួន និងវត្ថុតាងបទល្មើសព្រៃឈើទៅតាមនីតិវិធី ព្រោះបទល្មើសព្រៃឈើជាបទល្មើសដែលមានចរិកពិសេស និង មិនមានចែងក្នុងក្រមព្រហ្មទណ្ឌឡើយ ។

- ***មិនត្រូវប្រមូលប្រាក់ពិន័យ ឬ រឹបអូសវត្ថុតាងបទល្មើសដោយផ្ទាល់ឡើយ :***

អាជ្ញាធរទាំងឡាយមិនត្រូវរឹបអូសវត្ថុតាងបទល្មើសដោយផ្ទាល់ឡើយ ព្រោះមានតែរដ្ឋបាលព្រៃឈើ និង តុលាការទេ ដែលច្បាប់ស្តីពីព្រៃឈើបានផ្តល់សិទ្ធិអំណាចក្នុងការរឹបអូសវត្ថុតាងបទល្មើសព្រៃឈើទុកជាសម្បត្តិរដ្ឋ ឬ ដាក់លក់ដេញថ្លៃជាសាធារណៈយកប្រាក់បង់ចូលថវិការដ្ឋ ហើយអាជ្ញាធរទាំងឡាយក៏មិនត្រូវប្រមូលប្រាក់ពិន័យដោយផ្ទាល់ដែរ ព្រោះថា ការពិន័យអន្តរការណ៍ជាសមត្ថកិច្ចរបស់រដ្ឋបាលព្រៃឈើ រីឯការពិន័យដោយតុលាការជាសមត្ថកិច្ចរបស់តុលាការដែលមានចែងក្នុងច្បាប់ស្តីពីព្រៃឈើ ។

**មាត្រា ៧៩.-**

*ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួន មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធមិ មានសិទ្ធិដូចតទៅ :*

*១- អាចឱ្យបុគ្គលណាមួយឆ្លើយតបសំណួរ និង ផ្តល់ពត៌មានដែលពាក់ព័ន្ធដល់ការប្រព្រឹត្តបទល្មើសព្រៃឈើ ។*

*២- ចូលធ្វើការត្រួតពិនិត្យ ឬ ឆែកឆេរគ្រប់ទីកន្លែងរួមទាំងក្នុងព្រលានយន្តហោះ កំពង់ផែសមុទ្រ កំពង់ផែទន្លេ ផែស្ងួត ច្រកព្រំដែន ចំណតរថយន្ត ស្ថានីយ៍រថភ្លើង ក្នុងករណីបទល្មើសជាក់ស្តែងដោយមានកិច្ចសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធ ។*

*៣- ដកហូតជាបណ្តោះអាសន្ននូវអាជ្ញាប័ណ្ណ ឬ លិខិតអនុញ្ញាតគ្រប់ប្រភេទ ដែលកំណត់ដោយច្បាប់នេះបើសិនជាបុគ្គលទទួលអាជ្ញាប័ណ្ណ ឬ លិខិតអនុញ្ញាតនោះប្រព្រឹត្តល្មើសនឹងច្បាប់នេះ ។*

*ក្នុងករណីបទល្មើសជាក់ស្តែង មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធមិមានសិទ្ធិចូលឆែកឆេរ នៅក្នុងទីធ្លា អាគារ ឬ ក្នុងលំនៅដ្ឋានស្របតាមនីតិវិធីព្រហ្មទណ្ឌ ។ ការឆែកឆេរត្រូវធ្វើចំពោះមុខជនជាប់សង្ស័យ និង មានសាក្សីពីរ (២) នាក់ ដែលជាអ្នកជិតខាងឬអ្នកម្ចាស់ផ្ទះ ។*

- ***អាចឱ្យបុគ្គលណាមួយឆ្លើយតបសំណួរ និងផ្តល់ពត៌មានដែលពាក់ព័ន្ធ ដល់ការប្រព្រឹត្តបទល្មើសព្រៃឈើ :***

រាល់សំណួរ និង ពត៌មានត្រូវផ្តោតទៅលើចំនុចដូចខាងក្រោម :

- កំណត់ អត្តសញ្ញាណ និង សាវតារបស់ជនល្មើស និង ជនដែលពាក់ព័ន្ធ
- ទីតាំង និង ប្រភពនៃបទល្មើស
- ប្រភេទ និង ទំហំនៃបទល្មើស
- ចំនួនបទល្មើស
- លិខិតអនុញ្ញាតផ្សេងៗដែលពាក់ព័ន្ធដល់ការផ្តល់ពត៌មាន។

- ***ចូលធ្វើការត្រួតពិនិត្យ ឬ ឆែកឆេរគ្រប់ទីកន្លែង រួម ទាំងក្នុងព្រលានយន្តហោះ កំពង់ផែសមុទ្រ កំពង់ផែ ទន្លេ ផែស្ងួតច្រក ព្រំដែន ចំណតរថយន្ត ស្ថានីយ៍ រថភ្លើង ក្នុងករណីបទ ល្មើសជាក់ស្តែង ដោយ មានកិច្ចសហការជាមួយ សមត្ថកិច្ចពាក់ព័ន្ធ :***

បទល្មើសជាក់ស្តែង ជាអំពើរបស់ជនល្មើសស្ថិតក្នុងស្ថានភាព:

- ជនដែលគេទាន់ឃើញជាក់ស្តែងកំពុងប្រព្រឹត្តបទល្មើស
- ជនដែលគេកំពុងដេញប្រផាប់ចាប់ប្រភឹង ដោយមានសំរែកពីសាធារណជន
- ជនដែលបម្រុងរត់គេចចេញពីកន្លែងប្រព្រឹត្តបទល្មើស
- ជនដែលសាក្សី ឬ អ្នករងគ្រោះចង្អុលបង្ហាញនៅនឹងកន្លែងប្រព្រឹត្តបទល្មើសថាជាចារី សហចារី ឬ អ្នកសមគំនិត ។

ករណីបទល្មើសជាក់ស្តែង មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ មានសិទ្ធិចូលធ្វើការត្រួតពិនិត្យ ឬ ឆែកឆេរតាមបណ្តាទីតាំងខាងលើដោយសហការជាមួយបណ្តាសមត្ថកិច្ចពាក់ព័ន្ធ។ ក្នុងករណីមិនទទួលបានការសហការពីនីតិបុគ្គលដែលគ្រប់គ្រងនៅទីតាំងដែលពាក់ព័ន្ធនោះ ចាំបាច់ត្រូវសុំដីកាពីព្រះរាជអាជ្ញាជាបន្ទាន់ ដើម្បីអនុវត្តតាមនីតិវិធី ហើយជននោះត្រូវទទួលទោសដូចមានចែងក្នុងមាត្រា ១០០។

ប្រតិបត្តិការឆែកឆេរអាចប្រព្រឹត្តទៅបានចាប់ពីម៉ោង ៦ ព្រឹក ដល់ម៉ោង ៦ ល្ងាច ហើយការឆែកឆេរត្រូវធ្វើចំពោះមុខជនជាប់សង្ស័យ និង មានសាក្សីពីរ (២)នាក់ ដែលជាអ្នកជិតខាង ឬ ម្ចាស់ផ្ទះ។ ក្នុងករណីដែលខុសពីម៉ោងពេលខាងលើ ចាំបាច់ត្រូវហ៊ុមព័ទ្ធឃ្លាំមើលពីខាងក្រៅ។ ចំពោះបទល្មើសមិនជាក់ស្តែង ត្រូវស្រាវជ្រាវរកពត៌មាន រកធាតុផ្សំឱ្យបានគ្រប់គ្រាន់ ដើម្បីបញ្ជាក់ភស្តុតាងថាមានប្រាកដមែន នោះទើបសុំដីកាឆែកឆេរពីព្រះរាជអាជ្ញាជាបន្ទាន់ ដើម្បីអនុវត្តតាមនីតិវិធី។

- ***ដកហូតជាបណ្តោះអាសន្ននូវអាជ្ញាប័ណ្ណ ឬ លិខិតអនុញ្ញាតគ្រប់ប្រភេទដែលកំណត់ដោយច្បាប់នេះ បើសិនជាបុគ្គលទទួលអាជ្ញាប័ណ្ណ ឬ លិខិតអនុញ្ញាតនោះប្រព្រឹត្តល្មើសនឹងច្បាប់នេះ :***

បុគ្គលដែលបានទទួលអាជ្ញាប័ណ្ណ ឬ លិខិតអនុញ្ញាតប្រព្រឹត្តល្មើសនឹងច្បាប់មានជាអាទិ៍:

- ការអនុវត្តន៍ខុសពីខ្លឹមសារដែលបានចែងក្នុងលិខិត ឬ អាជ្ញាប័ណ្ណនោះ
- អនុវត្តខុសពីគោលការណ៍ណែនាំស្តីពីការអនុវត្តន៍ការប្រមូលផល
- ដឹកជញ្ជូនលើស ខុសទិសដៅ ហួសសុពលភាព ខុសយថាប្រភេទ ខុសមធ្យោបាយដឹកជញ្ជូន
- លិខិតអនុញ្ញាត អាជ្ញាប័ណ្ណក្លែងបន្លំ ។

**មាត្រា ៨០.-**

*មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ក្នុងករណីបទល្មើសជាក់ស្តែងត្រូវចាប់ឃាត់ជាបណ្តោះអាសន្ន :*

*១-រាល់ផល អនុផលព្រៃឈើ ឬ ផលប្រមាញ់ ដែលល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ។*

*២-សត្វពាហនៈដែលបានជួបប្រទះកំពុងបំផ្លិចបំផ្លាញដំណាំឈើ ។*

*៣-គ្រឿងចក្រ យានយន្ត ឧបករណ៍ព្រមទាំងសត្វពាហនៈដែលបានប្រើប្រាស់ជាមធ្យោបាយសម្រាប់ប្រព្រឹត្តបទល្មើសព្រៃឈើ និង សត្វព្រៃ ។*

*មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ត្រូវឃាត់ខ្លួនជនប្រព្រឹត្តបទល្មើសព្រៃឈើបានដល់៤៨ ម៉ោងយ៉ាងយូរដើម្បីបំពេញសំណុំរឿងបញ្ជូនទៅតុលាការ ។*

- ***ការចាប់ឃាត់ជាបណ្តោះអាសន្ន :***

មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនិតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ត្រូវចាប់ឃាត់ជនល្មើស វត្ថុតាង សំភារៈ និង មធ្យោបាយផ្សេងៗដែលបំរើឱ្យការប្រព្រឹត្តបទល្មើស ដើម្បីរៀបចំចងក្រងសំនុំរឿងស្របតាមនីតិវិធីច្បាប់ រហូតដល់មានការសំរេចពីថ្នាក់លើ និង តុលាការ។ ក្នុងរយៈពេលបណ្តោះអាសន្ននេះ គ្មានរូបវន្តបុគ្គល ឬ នីតិបុគ្គលណាមានសិទ្ធិយកវត្ថុតាងទាំងនេះទៅចាត់ចែងប្រើប្រាស់ ឬ លក់ដូរបានឡើយ។

- ***រាល់ផល អនុផលព្រៃឈើ ឬ ផលប្រមាញ់ដែលល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ :***

មន្ត្រីរដ្ឋបាលព្រៃឈើត្រូវធ្វើការឃាត់ទុកផល អនុផលព្រៃឈើ ឬ ផលប្រមាញ់ដែលជាវត្ថុតាងនៃបទល្មើស ហើយត្រូវចុះក្នុងសៀវភៅ ឬ លិខិតទទួលថែរក្សាវត្ថុតាង និង ត្រូវរៀបចំទុកដាក់ក្នុងកន្លែងមានសុវត្ថិភាព ដោយបង់លេខរៀង កាលបរិច្ឆេទ តាមសំនុំរឿងលំដាប់ថ្នាក់ប្រភេទចំនួនដោយចុះនិទ្ទេសឱ្យបានច្បាស់លាស់ ។

- ***សត្វពាហនៈដែលបានជួបប្រទះកំពុងបំផ្លិចបំផ្លាញដំណាំឈើ :***

ចំពោះសត្វពាហនៈទាំងឡាយណាដែលបានជួបប្រទះកំពុងបំផ្លាញដំណាំឈើ ថ្នាលបណ្តុះរុក្ខជាតិ ព្រៃដាំ ចំការឈើដាំ សួនឧទ្យាន ទីកន្លែងសាធារណៈ ។ល។ ត្រូវឃាត់ទុកជាបណ្តោះអាសន្ន ហើយត្រូវស្រាវជ្រាវរកម្ចាស់ដើម្បីចងក្រងសំនុំរឿងស្របតាមនីតិវិធីច្បាប់។ ដោយឡែកការចំណាយទៅលើការថែរក្សា ចំណីអាហារ និង ការថែរក្សាសត្វពាហនៈទាំងនេះគឺជាបន្ទុករបស់ម្ចាស់សត្វពាហនៈ ។

- ***គ្រឿងចក្រ យានយន្ត ឧបករណ៍ព្រមទាំងសត្វពាហនៈដែលបានប្រើប្រាស់ជាមធ្យោបាយសម្រាប់ប្រព្រឹត្តបទល្មើសព្រៃឈើ និង សត្វព្រៃ :***

ត្រូវបានចាប់ចាត់ទុកជាបណ្តោះអាសន្ន ដើម្បីរង់ចាំការសំរេចតាមនីតិវិធី ចំពោះគ្រឿងចក្រ យានយន្ត ឧបករណ៍ព្រមទាំងសត្វពាហនៈដែលបានប្រើប្រាស់ជាមធ្យោបាយសម្រាប់ប្រព្រឹត្តបទល្មើសព្រៃឈើ និង សត្វព្រៃ។ ដោយឡែកចំពោះរថយន្ត ឬ មធ្យោបាយរបស់កងទ័ព រថយន្តពេទ្យ (សង្គ្រោះបន្ទាន់) រថយន្តអគ្គីភ័យ ត្រូវបានដោះលែងជាបណ្តោះអាសន្ន ដោយមានកិច្ចសន្យាធានាអះអាងពីសាមីអង្គភាពថានឹងប្រគល់មករដ្ឋបាលព្រៃឈើ និង តុលាការដោយឥតលក្ខខណ្ឌនៅពេលត្រូវការពិនិត្យស្រាវជ្រាវ បន្ទាប់ពីបានចងក្រងសាវតាជាតិរបស់ជនល្មើសបានគ្រប់គ្រាន់ និង ចងក្រងសំនុំរឿងរួច ។

- ***មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ ត្រូវឃាត់ខ្លួនជនប្រព្រឹត្តបទល្មើសព្រៃឈើបានដល់ ៤៨ ម៉ោងយ៉ាងយូរ ដើម្បីបំពេញសំណុំរឿងបញ្ជូនទៅតុលាការ :***

មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ ត្រូវឃាត់ខ្លួនជនប្រព្រឹត្តបទល្មើសព្រៃឈើបានដល់ ៤៨ ម៉ោងយ៉ាងយូរ ដើម្បីបំពេញសំនុំរឿងបញ្ជូនទៅតុលាការ ។ ក្នុងចន្លោះពេលនោះ ត្រូវចាត់ចែងប្រមូលវត្ថុតាង រៀបចំកំណត់ហេតុកសាងសំនុំរឿង និង ត្រូវសួរចំលើយពីជនល្មើស ឬ សាក្សី ។ ក្នុងករណីមានការលំបាកក្នុងការធ្វើដំណើរ ឬ ដឹកជញ្ជូនជនល្មើស មន្ត្រីនគរបាលយុត្តិធម៌អាចស្នើសុំពន្យាពេលក្នុងការឃាត់ខ្លួនជនល្មើសជាបណ្តោះអាសន្នក្នុងរយៈពេល ២៤ ម៉ោង បន្តទៀត បន្ទាប់ពីមានការឯកភាពពីលោកព្រះរាជអាជ្ញា ។

**មាត្រា ៨១.-**

*ការកសាងសំណុំរឿងនៃបទល្មើសព្រៃឈើ ត្រូវអនុវត្តតាមច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។ ទំរង់បែបបទនៃកំណត់ហេតុបទល្មើសព្រៃឈើ ត្រូវកំណត់ដោយប្រកាសរួមរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង ក្រសួងយុត្តិធម៌ ។*

- ***ការកសាងសំណុំរឿងនៃបទល្មើសព្រៃឈើ ត្រូវអនុវត្តតាមច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ :***

មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ ត្រូវអនុវត្តតាមច្បាប់ស្តីពីនិតិវិធីព្រហ្មទណ្ឌ ជាពិសេសតាមមាត្រា ៣៦, ៣៧, ៣៨, ៣៩ និង ៤០ ។ ការឃាត់ខ្លួនជនប្រព្រឹត្តបទល្មើសព្រៃឈើបានដល់ ៤៨ ម៉ោងយ៉ាងយូរ ដើម្បីបំពេញសំណុំរឿងបញ្ជូនទៅតុលាការ ។ ក្នុងចន្លោះពេលនេះត្រូវចាត់ចែងប្រមូលវត្ថុតាង រៀបចំកំណត់ហេតុកសាងសំនុំរឿង និង សួរចំលើយពីជនល្មើស ឬ សាក្សី ។ ក្នុងករណីមានការលំបាកក្នុងការធ្វើដំណើរ ឬ ដឹកជញ្ជូនជនល្មើស មន្ត្រីនគរបាលយុត្តិធម៌អាចស្នើសុំពន្យាពេលក្នុងការឃាត់ខ្លួនជនល្មើសជាបណ្តោះអាសន្នក្នុងរយៈពេល ២៤ ម៉ោង បន្តទៀត បន្ទាប់ពីមានការឯកភាពពីលោកព្រះរាជអាជ្ញា ។

- ***ទំរង់បែបបទនៃកំណត់ហេតុបទល្មើសព្រៃឈើ ត្រូវកំណត់ដោយប្រកាសរួមរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង ក្រសួងយុត្តិធម៌ :***

គំរូសំណុំលិខិតនៃការចងក្រងសំណុំរឿងបទល្មើសព្រៃឈើ ត្រូវអនុវត្តតាមប្រកាសរួមលេខ ០៩៧ ប្រក.កសក-កយ/០៦ ចុះថ្ងៃទី ០៦-០៣-២០០៦ របស់ក្រសួងយុត្តិធម៌ និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ស្តីពី ***" ទំរង់បែបបទនៃកំណត់ហេតុបទល្មើសព្រៃឈើ "*** ហើយការកសាងសំណុំរឿងបទល្មើសព្រៃឈើត្រូវអនុវត្តតាមច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។ យោងតាមប្រកាសរួមនេះ គំរូសំណុំលិខិតសម្រាប់កសាងសំណុំរឿងបទល្មើសព្រៃឈើមានដូចខាងក្រោម:

១- កំណត់ហេតុនៃបទល្មើស

២- កំណត់ហេតុបទល្មើសជាក់ស្តែង

៣- កំណត់ហេតុឆែកឆេរ

៤- កំណត់ហេតុសួរចម្លើយ

៥- កំណត់ហេតុដកហូត ឃាត់ទុកវត្ថុតាងបណ្តោះអាសន្ន

៦- កំណត់ហេតុយកគំរូសំណាកផល អនុផលព្រៃឈើមកវិភាគ

៧- កំណត់ហេតុឃាត់ខ្លួនបណ្តោះអាសន្ន

៨- កំណត់ហេតុប្រគល់ ទទួលជនល្មើសដែលបានឃាត់ខ្លួន

៩- ព្រឹត្តិប័ត្រព័តិមាន

១០- សាលាកប័ត្រទោសទណ្ឌ

១១- លិខិតទទួលថែរក្សាវត្ថុតាង

១២-សេចក្តីសម្រេចស្តីពីការពិន័យអន្តរការណ៍លើបទល្មើសព្រៃឈើ

១៣- ដីកាអម

គំរូសំណុំលិខិតនៃការចងក្រងសំណុំរឿងបទល្មើសព្រៃឈើនេះ មិនតំរូវឱ្យបំពេញគ្រប់ទាំង ១៣ គំរូសំណុំលិខិតនោះទេ វាអាស្រ័យនឹងប្រភេទនៃបទល្មើស និង ទោសប្បញ្ញត្តិ (ទណ្ឌកម្ម) ដែលជនល្មើសត្រូវទទួល ហើយថាតើប្រភេទបទល្មើសព្រៃឈើណាដែលនីតិវិធីដោះស្រាយបទល្មើសជាសមត្ថកិច្ចរបស់រដ្ឋបាលព្រៃឈើ និង របស់តុលាការ (សាលាជំរះក្តី)។

សំណៅដើមកំណត់ហេតុនៃបទល្មើស ត្រូវសរសេរ និង ចុះហត្ថលេខាដោយដៃរបស់មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌មានសមត្ថកិច្ច។ ក្នុងករណីមន្ត្រីរដ្ឋបាលព្រៃឈើធ្វើកំណត់ហេតុនៃបទល្មើសមានឧបសគ្គពុំអាចសរសេរដោយដៃបាន សំណៅដើមនេះអាចវាយអង្គុលីលេខ ឬ កុំព្យូទ័របាន តែត្រូវមានសេចក្តីបញ្ជាក់អះអាងក្នុងកំណត់ហេតុពីព្រះរាជអាជ្ញាអមតុលាការខេត្ត ក្រុង ក្នុងដែនសមត្ថកិច្ចដែលមន្ត្រីរដ្ឋបាលព្រៃឈើបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌នោះតាំងនៅ ឬ បំពេញបេសកកម្មទើបចាត់ទុកជាស្របច្បាប់។

កំណត់ហេតុនៃបទល្មើសត្រូវសរសេរដោយដៃ មិនឱ្យខុស ហើយត្រូវសរសេរឱ្យបានស្អាត មិនត្រូវកោស លុប កែតំរូវ ជួសអក្សរឡើយ។ ក្នុងករណីចាំបាច់មានការកោស លុប ត្រូវតែធ្វើឡើងដោយប៉ិចទឹកក្រហម ព្រមទាំងចុះហត្ថលេខាសង្ខេបលើចំនុចខុសនោះ។ ការសរសេរកំណត់ហេតុនៃបទល្មើសត្រូវចាប់ធ្វើឡើងក្នុងរយៈពេល ០៤ថ្ងៃ ក្រោយពីថ្ងៃបានចុះទៅពិនិត្យវត្ថុតាងជាក់ស្តែង។ ត្រូវគូសបន្ទាត់ពីក្រោមឈ្មោះជនល្មើស និង គូសបន្ទាត់នៅដើមបន្ទាត់ និង ចុងនៃប្រយោគនីមួយៗ។ ត្រូវបញ្ជាក់ច្បាស់លាស់ពីកន្លែងចាប់ខ្លួនជនល្មើស (ភូមិ ឃុំ ស្រុក) ម៉្យាងទៀតត្រូវកត់ចំលើយឱ្យបានច្បាស់ពេលសួរជនល្មើស។

**មាត្រា ៨២.-**

*វត្ថុតាងនៃបទល្មើសព្រៃឈើ ត្រូវបានកំណត់ដូចខាងក្រោម :*

*១- ផល អនុផលព្រៃឈើ ឬ ផលប្រមាញ់ ដែលជាវត្ថុតាងពិតប្រាកដនៃបទល្មើស ។*

*២- សម្ភារៈបរិក្ខារ និងមធ្យោបាយដឹកជញ្ជូន ដែលប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស ។*

*វត្ថុតាងដូចមានចែងក្នុងកឋាខ័ណ្ឌទី ១ ខាងលើនេះត្រូវឃាត់ទុកជាបណ្តោះអាសន្នរហូតដល់សំណុំរឿងនៃបទល្មើសត្រូវបានដោះស្រាយរួចជាស្ថាពរ តាមការបង់ពិន័យអន្តរការណ៍ ឬ តាមការជំនុំជំរះរបស់តុលាការ ។*

*ក្នុងខណៈពេលកំពុងដឹកជញ្ជូនផល អនុផលព្រៃឈើល្មើស ឬ ផលប្រមាញ់ល្មើស អ្នកបើកបរ មធ្យោបាយដឹកជញ្ជូនដែលគ្មានម្ចាស់នៅជាមួយ ត្រូវឃាត់ខ្លួនជាបណ្តោះអាសន្ន ដើម្បីជាប្រយោជន៍នៃការស៊ើបអង្កេតរកជនល្មើស និង អ្នកសមគំនិត ។*

*ផលប្រមាញ់ស្រស់ជាអាទិ៍ សត្វរស់ និង សំណាកសត្វព្រៃដែលបានឃាត់ទុកហើយងាយខូចខាត ផ្នែករដ្ឋបាលព្រៃឈើមាន សិទ្ធិលែង ឬ បំផ្លាញចោល ឬ រក្សាទុកជាប្រយោជន៍សាធារណៈ ដោយមានកំណត់ហេតុត្រឹមត្រូវ ។*

- ***ផល អនុផលព្រៃឈើ ឬ ផលប្រមាញ់ ដែលជាវត្ថុតាងពិតប្រាកដនៃបទល្មើស :***

ផល អនុផលព្រៃឈើ ឬ ផលប្រមាញ់ ដែលជាវត្ថុតាងពិតប្រាកដនៃបទល្មើសមានដូចជា : ឈើហ៊ុបមូល និង ជ្រុង (គ្រប់ប្រភេទ) ឈើអារ (គ្រប់ប្រភេទ) ពកឈើ វល្លិ ជ័រ ផ្តៅ ខ្លឹម ឬស្សី ឱសថបុរាណ និង សត្វព្រៃគ្រប់ប្រភេទ។ល។

- ***សម្ភារៈបរិក្ខារ និង មធ្យោបាយដឹកជញ្ជូនដែលប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស :***

សំភារៈ បរិក្ខារ រួមមាន : រណារយន្តគ្រប់ប្រភេទ រណារដៃគ្រប់ប្រភេទ កាំបិត ពូថៅ អន្ទាក់ ស្នារ ព្រួញថ្នាំពុល សារធាតុគីមី អាវុធគ្រប់ប្រភេទ...។ មធ្យោបាយដឹកជញ្ជូនរួមមាន : យានយន្តគ្រប់ប្រភេទ ជលយាន្តគ្រប់ប្រភេទ រទេះដឹកគ្រប់ប្រភេទ...។

- ***វត្ថុតាងដូចមានចែងក្នុងកឋាខ័ណ្ឌទី១ខាងលើនេះ ត្រូវឃាត់ទុកជាបណ្តោះអាសន្ន រហូតដល់សំណុំរឿងនៃបទល្មើសត្រូវបានដោះស្រាយរួចជា ស្ថាពរតាមការបង់ពិន័យអន្តរការណ៍ ឬ តាមការជំនុំជំរះរបស់តុលាការ :***

មន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ចត្រូវឃាត់ទុកជាបណ្តោះអាសន្ននូវផល អនុផលព្រៃឈើ ឬ ផលប្រមាញ់ ដែលជាវត្ថុតាងពិតប្រាកដនៃបទល្មើស និង សម្ភារៈបរិក្ខារ និង មធ្យោបាយដឹកជញ្ជូនដែលប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើសព្រៃឈើ រហូតដល់សំណុំរឿងនៃបទល្មើសត្រូវបានដោះស្រាយរួចជាស្ថាពរ តាមការបង់ពិន័យអន្តរការណ៍ ឬ តាមការជំនុំជំរះរបស់តុលាការ។

ការពិន័យអន្តរការណ៍គឺ ជាការពិន័យដោយសំរុះសំរួលលើបណ្តឹងអាជ្ញាដែលអនុញ្ញាតឱ្យរដ្ឋបាលព្រៃឈើអាចអនុវត្តបានលើជនល្មើសណាដែលបានសារភាពទោសកំហុស និង សុំបង់ប្រាក់ពិន័យទៅតាមការកំណត់របស់រដ្ឋបាលព្រៃឈើ ដើម្បីឱ្យរួចផុតពីការចោទប្រកាន់ទោសទៅតុលាការ។ ការពិន័យអន្តរការណ៍ត្រូវបានធ្វើឡើងដោយរដ្ឋបាលព្រៃឈើថ្នាក់កណ្តាល និង តាមសំណើររបស់រដ្ឋបាលព្រៃឈើមូលដ្ឋាន។

ការពិន័យអន្តរការណ៍លើបទល្មើសព្រៃឈើ លុះត្រាតែជនល្មើសបានសារភាពទោសកំហុសជាលាយលក្ខណ៍អក្សរជូនរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច ដោយសុខចិត្តយល់ព្រមបង់ប្រាក់ពិន័យអន្តរការណ៍ស្របតាមបទប្បញ្ញត្តិនៃច្បាប់។ ក្រោយពេលបង់ ប្រាក់ពិន័យអន្តរការណ៍គ្រប់ចំនួន សាមីជនអាចរួចផុតពីការចោទប្រកាន់ទៅតុលាការ។ វត្ថុតាងពិតប្រាកដនៃបទល្មើសព្រៃឈើត្រូវបានរឹបអូសជាសម្បត្តិរដ្ឋ និង អាចប្រគល់ជូនសាមីជនវិញនូវវត្ថុតាងក្រៅពីផល អនុផលព្រៃឈើដែលពាក់ព័ន្ធនឹងការប្រព្រឹត្តបទល្មើស។ សាមីជនត្រូវចេញសោហ៊ុយចំណាយជាក់ស្តែងក្នុងការលើកដាក់ ដឹកជញ្ជូន និង ថែរក្សាវត្ថុ តាង។ រដ្ឋបាលព្រៃឈើមានសមត្ថកិច្ចត្រូវផ្ទេរប្រាក់ពិន័យអន្តរការណ៍ចូលរតនាគារខេត្ត ក្រុង ឬ រតនាគារជាតិ និង ត្រូវជូនដំណឹងមកកាន់រដ្ឋបាលព្រៃឈើថ្នាក់កណ្តាលដោយភ្ជាប់ មកនូវជាមួយសក្ខីប័ត្ររបស់រតនាគារព្រមទាំងសំណុំរឿងនៃបទល្មើសផង ។

សំណុំរឿងនៃបទល្មើសដែលជនល្មើសនោះមិនព្រមសារភាពទោសកំហុស និង បង់ពិន័យអន្តរការណ៍ទៅតាមការកំណត់របស់រដ្ឋបាលព្រៃឈើ មន្ត្រីរដ្ឋបាលព្រៃឈើត្រូវបញ្ជូនទៅតុលាការដើម្បីជំនុំជំរះ។ វត្ថុតាងល្មើសនេះ អាចចាត់ចែង ទៅបានលុះត្រាតែមានសាលក្រមស្ថាពរ។

- ***ក្នុងខណៈពេលកំពុងដឹកជញ្ជូនផល អនុផលព្រៃឈើល្មើស ឬ ផលប្រមាញ់ល្មើស អ្នកបើកបរមធ្យោបាយដឹកជញ្ជូនដែលគ្មានម្ចាស់នៅជាមួយ ត្រូវឃាត់ខ្លួនជាបណ្តោះអាសន្ន ដើម្បីជាប្រយោជន៍នៃការស៊ើបអង្កេតរកជនល្មើស និង អ្នកសមគំនិត :***

នៅពេលចាប់ឃាត់បទល្មើសព្រៃឈើដែលចរាចរនៅគ្រប់ទីកន្លែង ហើយដែលពុំមានម្ចាស់ចេញមុខមកទទួលខុសត្រូវចំពោះមុខរដ្ឋបាលព្រៃឈើ នោះរដ្ឋបាលព្រៃឈើមានសមត្ថកិច្ចអាចធ្វើការឃាត់ខ្លួនជាបណ្តោះអាសន្ន ចំពោះជនដែលមានការពាក់ព័ន្ធជាក់ស្តែងនៅពេលឃាត់ចាប់ ដូចជា អ្នកបើកបរ កម្មករ ស្របតាមនីតិវិធីព្រហ្មទណ្ឌ ជាប្រយោជន៍ក្នុងការស្រាវជ្រាវ ស៊ើបអង្កេត រកជនល្មើសពិតប្រាកដ ដើម្បីរៀបចំចងក្រងសំណុំរឿងទៅតុលាការ ។

- ***ផលប្រមាញ់ស្រស់ ជាអាទិ៍សត្វរស់ និង សំណាកសត្វព្រៃដែលបានឃាត់ទុក ហើយងាយខូចខាត ផ្នែករដ្ឋបាលព្រៃឈើមានសិទ្ធិលែង ឬ បំផ្លាញចោល ឬ រក្សាទុកជាប្រយោជន៍សាធារណៈដោយមានកំណត់ហេតុត្រឹមត្រូវ :***

មន្ត្រីរដ្ឋបាលព្រៃឈើត្រូវដោះលែងសត្វរស់មានសុខភាពល្អក្នុងតំបន់ព្រៃការពារ ឬ ឧទ្យានជាតិ ឬ មជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ ដែលមានលក្ខណៈជីវសាស្ត្រសមស្របតាមប្រភេទសត្វនីមួយៗ។ សត្វមួយចំនួនដែលមានសុខភាពទ្រុឌទ្រោម ត្រូវយកទៅថែរក្សា និង បំប៉ននៅមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃជាមុនសិន។ ចំណែកសំណាកសត្វ ឬ ផលប្រមាញ់ស្រស់ដែលងាយខូចខាត មន្ត្រីរដ្ឋបាលព្រៃឈើអាចកំទេចចោលបាន ដោយធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរភ្ជាប់ជាមួយនឹងរូបថតជាក់ស្តែង ដោយបញ្ជាក់ពីចំនួនប្រភេទ សំណាកសត្វ ទីកន្លែង ថ្ងៃ ខែ ឆ្នាំ ព្រមទាំងមានចុះហត្ថលេខាសមាសភាពក្រុមការងារដែលបានចូលរួម។

## មាត្រា ៨៣.-

*មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ត្រូវស្លៀកពាក់ឯកសណ្ឋាន ពាក់សញ្ញាសំគាល់ និង ពាក់ឋានន្តរសក្តិនៅពេលចូលរួមសវនាការរបស់តុលាការ ។*

- ***មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ត្រូវស្លៀកពាក់ឯកសណ្ឋាន ពាក់សញ្ញាសំគាល់ និង ពាក់ឋានន្តរសក្តិនៅពេលចូលរួមសវនាការរបស់តុលាការ :***

នៅពេលចូលរួមសវនាការ មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ត្រូវរៀបចំខ្លួនដោយគ្រងឯកសណ្ឋាន ពាក់សញ្ញាសំគាល់ និង ពាក់ឋានន្តរសក្តិ មានលិខិតបេសកកម្ម និង ត្រៀមរាល់សំណុំឯកសារដែលពាក់ព័ន្ធនឹងបទល្មើសសំរាប់ឆ្លើយបំភ្លឺ ឬ បង្ហាញនៅក្នុងតុលាការ។

## មាត្រា ៨៤.-

*នៅរាល់ពេលសវនាការ មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ពាក់ព័ន្ធទៅក្នុងសំណុំរឿងក្តី ត្រូវមានសិទ្ធិឆ្លើយបំភ្លឺអំពីលទ្ធផលនៃការស៊ើបអង្កេតបទល្មើសព្រៃឈើនោះជូនតុលាការ ។*

- ***នៅរាល់ពេលសវនាការ មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ពាក់ព័ន្ធទៅក្នុងសំណុំរឿងក្តី ត្រូវមានសិទ្ធិឆ្លើយបំភ្លឺអំពីលទ្ធផលនៃការស៊ើបអង្កេតបទល្មើសព្រៃឈើនោះជូនតុលាការ :***

មន្ត្រីរដ្ឋបាលព្រៃឈើដែលបានទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ពាក់ព័ន្ធនឹងសំណុំរឿងក្តី គឺមានមន្ត្រីចុះបេសកកម្ម និងមន្ត្រីបំពេញសំណុំរឿង។ ក្នុងពេលសវនាការ ចៅក្រមជំនុំជម្រះត្រូវស្តាប់ការឆ្លើយបំភ្លឺពីមូលហេតុ និង ដំណើររឿងក្តីពីសំណាក់ដើមចោទ (មន្ត្រីរដ្ឋបាលព្រៃឈើ)។ ក្នុងករណីដែលចៅក្រមជំនុំជម្រះបានសម្រេចផ្ទុយពីការពិតនៃដំណើររឿង ភ្លាមនោះមន្ត្រីរដ្ឋបាលព្រៃឈើត្រូវសំណូមពរឱ្យពិចារណាឡើងវិញពីការជំនុំជម្រះនេះ។ បើសិនជាចៅក្រមជំនុំជម្រះបានកាត់ក្តីខុសពីច្បាប់ស្តីពីព្រៃឈើ មន្ត្រីរដ្ឋបាលព្រៃឈើត្រូវប្តឹងទៅសាលាឧទ្ធរណ៍ក្នុងរយៈពេលពីរខែគិតពីថ្ងៃប្រកាសសាលក្រម។

**មាត្រា ៨៥.~**

*អាជ្ញាយុកាលនៃបណ្តឹងបទល្មើសព្រៃឈើមាន :*

*១-បទល្មើសព្រៃឈើថ្នាក់ទី ១ មានអាជ្ញាយុកាលដប់ប្រាំ (១៥) ឆ្នាំ គិតពីពេលប្រព្រឹត្តបទល្មើស ។*

*២-បទល្មើសព្រៃឈើថ្នាក់ទី ២ មានអាជ្ញាយុកាលប្រាំ (៥) ឆ្នាំ គិតពីពេលប្រព្រឹត្តបទល្មើស ។*

*៣-បទល្មើសព្រៃឈើថ្នាក់ទី ៣ មានអាជ្ញាយុកាលមួយ (១) ឆ្នាំ គិតពីពេលប្រព្រឹត្តបទល្មើស ។*

*ការអនុវត្តន៍អាជ្ញាយុកាលនៃបណ្តឹងបទល្មើសព្រៃឈើ ត្រូវស្របតាមនីតិវិធីព្រហ្មទណ្ឌ ។*

- ***អាជ្ញាយុកាលនៃបណ្តឹងបទល្មើសព្រៃឈើ:***

អាជ្ញាយុកាលនៃបណ្តឹងបទល្មើសជារយៈពេលដែលច្បាប់កំណត់ក្នុងការធ្វើបណ្តឹងអាជ្ញាមួយ មានន័យថា បើសិនជាគេមិនបានធ្វើបណ្តឹង ឬ បទចោទប្រកាន់ណាមួយក្នុងរយៈពេលមួយកំណត់ទេនោះ គេមិនអាចប្តឹងបានទៀតឡើយ ។ អាជ្ញាយុកាលគឺជាបទប្បញ្ញត្តិដែលកំណត់ពីរយៈពេលក្រោយពេលកើតហេតុ ដើម្បីបើកសិទ្ធិឱ្យភាគីដើមចោទ ឬ ដើមបណ្តឹងប្តឹងទៅតុលាការ ឬ ជារយៈពេលដែលជនល្មើសរួចផុតពីការទទួលខុសត្រូវតាមផ្លូវច្បាប់ ។ ការកំណត់អាជ្ញាយុកាលនៃបទល្មើសគឺផ្អែកទៅតាមទំហំ និង កំរិតនៃបទល្មើសនីមួយៗ ដែលបង្កឱ្យមានមហន្តរាយដល់ផលប្រយោជន៍បុគ្គល ប្រទេសជាតិ ឬ ស្ថាប័នរដ្ឋ សំដៅទុកពេលឱ្យមន្ត្រីរដ្ឋបាលព្រៃឈើស្រាវជ្រាវ ស៊ើបអង្កេត ចងក្រងសំណុំរឿងនៃបទល្មើសបានគ្រប់ជ្រុងជ្រោយ ដើម្បីមានមូលដ្ឋានភស្តុតាងគ្រប់គ្រាន់ធ្វើការចោទប្រកាន់ ។ ក្នុងករណីអាជ្ញាយុកាលនៃពាក្យបណ្តឹងខាងលើត្រូវបានបញ្ចប់ នោះរដ្ឋបាលព្រៃឈើមិនអាចធ្វើបណ្តឹងចោទប្រកាន់ជនល្មើសបានឡើយ ។

**មាត្រា ៨៦.~**

*បុគ្គលដែលប្រព្រឹត្តបទល្មើសព្រៃឈើដូចមានចែងក្នុងច្បាប់នេះ ត្រូវទទួលខុសត្រូវចំពោះសកម្មភាពដែលខ្លួនបានប្រព្រឹត្ត ។*

*បុគ្គលជាភ្នាក់ងារនៃអង្គភាពរដ្ឋ ឬ ឯកជនដែលប្រើប្រាស់មធ្យោបាយរបស់អង្គភាពដើម្បីប្រព្រឹត្តបទល្មើសព្រៃឈើ បុគ្គល ឬ ប្រធានអង្គភាពនោះ ត្រូវទទួលទោសតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។*

*បទល្មើសព្រៃឈើដែលប្រព្រឹត្តឡើងដោយបុគ្គល ឬ ក្រុមក្រោមការចាត់តាំងរបស់អង្គភាពណាមួយ ប្រធានអង្គភាពនោះត្រូវទទួលទោសតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។*

- ***គ្រប់សកម្មភាពល្មើស បុគ្គលដែលបានប្រព្រឹត្ត ផ្ទាល់ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ :***

ប្រសិនបើបុគ្គលណាមួយ យកមធ្យោបាយរបស់អង្គភាពទៅប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស បុគ្គលនោះជាអ្នកទទួលខុសត្រូវដោយផ្ទាល់ចំពោះមុខច្បាប់ ។ ក្នុងករណីជនប្រព្រឹត្តល្មើសគេចខ្លួនបាត់ មិនចូលមកសារភាពទោសកំហុស ឬ បង់ប្រាក់ពិន័យទេនោះ ប្រធានអង្គភាពត្រូវទទួលខុសត្រូវលើសំណុំរឿងដែលបានកំណត់ឡើងទៅតាមផ្លូវច្បាប់ ។ បុគ្គល ឬ ក្រុមនៃបុគ្គលក្រោមការចាត់តាំងរបស់អង្គភាពណាមួយឱ្យទៅប្រព្រឹត្តរាល់សកម្មភាពល្មើសពីច្បាប់ស្តីពីព្រៃឈើ ទោះក្រោមរូបភាពបំរើឱ្យផលប្រយោជន៍អង្គភាពក៏ដោយ ក៏បុគ្គល ក្រុម ឬ ប្រធានអង្គភាពនោះត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

**មាត្រា ៨៧.~**

*រូបវន្តបុគ្គលបរទេស ឬ នីតិបុគ្គលបរទេសដែលបានប្រព្រឹត្តបទល្មើសព្រៃឈើត្រូវស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ ។*

- *រូបវន្តបុគ្គលបរទេស ឬ នីតិបុគ្គលបរទេសដែលបានប្រព្រឹត្តបទល្មើសព្រៃឈើ :*

រូបវន្តបុគ្គលបរទេស ឬ នីតិបុគ្គលបរទេស គឺជាជនទាំងឡាយដែលគ្មានសញ្ជាតិជាខ្មែរ ដែលបានមករស់នៅដោយស្របច្បាប់ក្តី មិនស្របច្បាប់ក្តី ជាអ្នកទេសចរណ៍ ជាអ្នករកស៊ី ឬ បំពេញការងារផ្សេងៗនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយបានប្រព្រឹត្តបទល្មើសព្រៃឈើ ត្រូវទទួលទោសទៅតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីព្រៃឈើដូចប្រជាជនកម្ពុជាដែរ។

## មាត្រា ៨៨.-

*មន្ត្រីរដ្ឋបាលព្រៃឈើ ដែលមានសមត្ថកិច្ចមានសិទ្ធិអំណាចផ្អាកសកម្មភាពនៅក្នុងតំបន់ព្រៃសម្បទានទាំងមូលឬមួយផ្នែក មួយរយៈ ដើម្បីចាត់ការតាមនីតិវិធីក្នុងករណីព្រៃសម្បទានិកប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ឬ ល្មើសនឹងកិច្ចព្រមព្រៀងព្រៃសម្បទាន រហូតដល់ដំណោះស្រាយនៃវិវាទត្រូវបានបញ្ចប់ ។*

- ***មន្ត្រីរដ្ឋបាលព្រៃឈើដែលមានសមត្ថកិច្ច មានសិទ្ធិអំណាចផ្អាកសកម្មភាពនៅក្នុងតំបន់ព្រៃសម្បទានទាំងមូល ឬ មួយផ្នែកមួយរយៈ :***

ព្រៃសម្បទានិកដែលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ឬ ល្មើសនឹងកិច្ចព្រមព្រៀងព្រៃសម្បទានដូចជា :

- ការក្លែងបន្លំលិខិតអនុញ្ញាត ឬ អាជ្ញាប័ណ្ណផ្សេងៗ
- កាប់រំលំដើមឈើដែលគ្មានផ្លាកសញ្ញាសំគាល់អនុញ្ញាតឱ្យកាប់រំលំ
- ប្រមូលផល អនុផលព្រៃឈើក្រៅពីប្លុក ឬ គុបដែលអនុញ្ញាតឱ្យប្រមូលផលប្រចាំឆ្នាំ
- ក្លែងបន្លំញញួរត្រារបស់រដ្ឋបាលព្រៃឈើ
- គាស់កកាយយកថ្ម ដីខ្សាច់ រ៉ែ ដែលមាននៅក្នុងដែនព្រៃសម្បទាន
- មិនគោរពតាមបទដ្ឋានបច្ចេកទេសដែលបានកំណត់ក្នុងក្រមបច្ចេកទេសអនុវត្តគ្រប់គ្រងព្រៃឈើកម្ពុជា
- មិនគោរពផែនការគ្រប់គ្រង និងផែនការប្រមូលផល អនុផលព្រៃឈើប្រចាំឆ្នាំ
- យកលិខិតអនុញ្ញាតប្រើប្រាស់ព្រៃឈើទៅប្រមូលផល អនុផលព្រៃឈើ
- ប្រើប្រាស់គ្រឿងចក្រយានយន្តបម្រើឱ្យការប្រមូលផលអនុផលព្រៃឈើដោយគ្មានលិខិតអនុញ្ញាត ឬ គ្មានស្លាកសំគាល់
- គាស់កកាយយកថ្ម ដី ខ្សាច់ រ៉ែ ដែលមាននៅក្នុងដីនៃដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍
- ប្រើប្រាស់ដីព្រៃឈើលើសពីទំហំអនុញ្ញាត ឬ គ្មានលិខិតអនុញ្ញាតដើម្បីស្ថាបនាផ្លូវ សាធារណៈផ្លូវព្រៃឈើ ឬ ដាក់តាំងមូលដ្ឋានសំណង់ ឬ លំនៅដ្ឋានគ្រប់ប្រភេទតាមដងផ្លូវ
- ប្រមូលផល អនុផលព្រៃឈើដោយគ្មានលិខិតអនុញ្ញាត
- ប្រមូលផល អនុផលព្រៃឈើក្រៅដែនព្រៃគុបកំណត់ក្នុងលិខិតអនុញ្ញាត ឬ ក្រៅភូមិសាស្ត្រដែលកំណត់ក្នុងផែនការប្រមូលផល អនុផលព្រៃឈើប្រចាំឆ្នាំ
- ផ្ទេរសិទ្ធិ ឬ លក់អាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត

- ប្រើប្រាស់រណារយន្តគ្រប់ប្រភេទដែលបំរើការប្រមូលផល អនុផលព្រៃឈើដោយគ្មានការអនុញ្ញាតពីប្រធានរដ្ឋបាលព្រៃឈើ ។
- ការនាំចូលគ្រឿងចក្រ យានយន្ត និង រណារយន្តគ្រប់ប្រភេទសម្រាប់ការប្រមូលផល អនុផលព្រៃឈើដោយគ្មានការវាយតម្លៃភាពសមស្របពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បង្កើតមូលដ្ឋានឧស្សាហកម្មឈើ រោងចក្រអារឈើ សិប្បកម្មកែច្នៃផល អនុផលព្រៃឈើ ឬ ឡគ្រប់ប្រភេទដែលប្រើប្រាស់ ឬ មិនប្រើប្រាស់ផល អនុផលព្រៃឈើជាវត្ថុធាតុដើម ឬ ជាប្រភពថាមពលខុសពីទីតាំងកំណត់ដោយរដ្ឋបាលព្រៃឈើ ។

ក្នុងករណីដែលមានបទល្មើសខាងខាងលើនេះ មន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ចមានសិទ្ធិផ្អាកសកម្មភាពរបស់ព្រៃសម្បទានិក ហើយប្រមូលវត្ថុតាងនៃបទល្មើសដើម្បីចងក្រងសំណុំរឿងតាមនីតិវិធី។ ព្រៃសម្បទានិកអាចដំណើរការសកម្មភាពទាំងឡាយឡើងវិញបាន លុះត្រាតែសំណុំរឿងនៃបទល្មើសត្រូវបានដោះស្រាយឱ្យបានសព្វគ្រប់ ។

## មាត្រា ៨៩.-

*បុគ្គលណាដែលមិនពេញចិត្តចំពោះការសម្រេចណាមួយ ធ្វើឡើងដោយរដ្ឋបាលព្រៃឈើស្របតាមច្បាប់នេះ មានសិទ្ធិប្តឹង តវ៉ាក្នុងរយៈពេលសាមសិប(៣០) ថ្ងៃយ៉ាងយូរគិត ពីថ្ងៃទទួលសេចក្តីសម្រេចនេះមកប្រធានរដ្ឋបាលព្រៃឈើ ។*

*ប្រធានរដ្ឋបាលព្រៃឈើត្រូវសម្រេចលើបណ្តឹងតវ៉ានោះ ក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ យ៉ាងយូរ ។ ក្រោយពីបានទទួលសេចក្តីសម្រេចចុងក្រោយលើការពិនិត្យឡើងវិញដោយប្រធានរដ្ឋបាលព្រៃឈើ ក្នុងករណីមិនអាចទទួល យកបាន ជននោះអាចធ្វើបណ្តឹងតវ៉ាទៅតុលាការ ។*

*ការតវ៉ាក្រោមមាត្រានេះ នឹងមិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិអំណាចនិងដំណើរការអនុវត្តន៍ច្បាប់ របស់មន្ត្រីរដ្ឋបាលព្រៃឈើ មានសមត្ថកិច្ចក្រោមច្បាប់នេះឡើយ ។*

- ***រយៈពេលនៃសិទ្ធិប្តឹងតវ៉ា និង សេចក្តីសម្រេចលើបណ្តឹងតវ៉ារបស់ប្រធានរដ្ឋបាលព្រៃឈើ :***

នៅពេលជួបប្រទះបទល្មើសព្រៃឈើ មន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ចត្រូវធ្វើសេចក្តីរាយការណ៍ជាលាយលក្ខណ៍អក្សរមកថ្នាក់លើរបស់ខ្លួន។ បន្ទាប់មក ប្រធានរដ្ឋបាលព្រៃឈើ ឬ នាយផ្នែករដ្ឋបាលព្រៃឈើមានសមត្ថកិច្ច ត្រូវធ្វើសេចក្តីប្រកាសជូនដំណឹងជាសាធារណៈ ដើម្បីរកម្ចាស់វត្ថុតាងនៃបទល្មើសព្រៃឈើ ក្នុងរយៈពេល ៣០ថ្ងៃ គិតចាប់ពីថ្ងៃចុះហត្ថលេខា ដោយបិទផ្សាយនៅទីតាំងកើតហេតុ សាលាឃុំ-សង្កាត់ ទីប្រជុំជន ទីសាធារណៈ និង ស្នាក់ការរដ្ឋបាលព្រៃឈើ (សង្កាត់ ផ្នែក ខ័ណ្ឌ អធិការដ្ឋាន រដ្ឋបាលព្រៃឈើ) ហើយសេចក្តីប្រកាសជូនដំណឹងនេះ ត្រូវមានការបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន ។

- **ចំពោះវត្ថុតាងបទល្មើសព្រៃឈើមានម្ចាស់ចេញមកសារភាព ត្រូវអនុវត្តដូចតទៅ :**

  ១- ករណីជនល្មើសព្រមសារភាពទោសកំហុស និង យល់ព្រមបង់ពិន័យអន្តរការណ៍ : ខ័ណ្ឌរដ្ឋបាលព្រៃឈើត្រូវស្នើសុំសេចក្តីសំរេចពិន័យអន្តរការណ៍ពីរដ្ឋបាលព្រៃឈើ។ បន្ទាប់ពី ១៥ ថ្ងៃ គិតពីថ្ងៃចេញសេចក្តីសំរេច បើជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ទេ នោះខ័ណ្ឌ ឬ ផ្នែករដ្ឋបាលព្រៃឈើមានសមត្ថកិច្ចត្រូវបញ្ជូនសំណុំរឿងទៅតុលាការ។

២- ករណីជនល្មើសមិនព្រមសារភាពទោសកំហុស និង យល់ព្រមបង់ពិន័យអន្តរការណ៍ នោះរដ្ឋបាលព្រៃឈើ ឬ ខ័ណ្ឌ ឬ ផ្នែករដ្ឋបាលព្រៃឈើមានសមត្ថកិច្ច ត្រូវបញ្ជូនសំណុំរឿងទៅតុលាការ ។

- **ចំពោះវត្ថុតាងបទល្មើសជាផល អនុផលព្រៃឈើ គ្មានម្ចាស់ចេញមកសារភាព ហើយគ្មានមធ្យោបាយបំរើឱ្យការប្រព្រឹត្តបទល្មើស :** ខ័ណ្ឌរដ្ឋបាលព្រៃឈើត្រូវធ្វើលើកសំណើមករដ្ឋបាលព្រៃឈើដើម្បីស្នើសុំឱ្យគណៈកម្មការដេញថ្លៃលក់វត្ថុតាងបទល្មើសព្រៃឈើចុះពិនិត្យ និង វាយតំលៃវត្ថុតាង ដើម្បីប្រកាសដាក់លក់ដេញថ្លៃជាសាធារណៈយកប្រាក់បង់ចូលថវិការដ្ឋ ។
- **ចំពោះវត្ថុតាងបទល្មើសជាផល អនុផលព្រៃឈើ គ្មានម្ចាស់ចេញមកសារភាព ហើយមានមធ្យោបាយបំរើឱ្យការប្រព្រឹត្តបទល្មើស :** រដ្ឋបាលព្រៃឈើ ឬ ខ័ណ្ឌ ឬ ផ្នែករដ្ឋបាលព្រៃឈើមានសមត្ថកិច្ចត្រូវបញ្ជូនសំណុំរឿងទៅតុលាការ ។

# ជំពូកទី ១៥
# បទល្មើសព្រៃឈើ និង ទោសប្បញ្ញត្តិ

## មាត្រា ៩០.-

*ទណ្ឌកម្មក្នុងបទល្មើសព្រៃឈើមាន : ទោសជាប់ពន្ធនាគារ រឹបអូសវត្ថុតាង ពិន័យដោយតុលាការពិន័យអន្តរការណ៍ ការជួសជុលការខូចខាត ការព្រមាន ការដកហូត ឬ ការព្យួរកិច្ចព្រមព្រៀង ឬ លិខិតអនុញ្ញាត ។*

*ការពិន័យអន្តរការណ៍លើបទល្មើសព្រៃឈើ ការជួសជុលការខូចខាត និង ការព្រមានជាសមត្ថកិច្ចរបស់រដ្ឋបាលព្រៃឈើ ។ ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ឬ ជួសជុលការខូចខាត រដ្ឋបាលព្រៃឈើអាចបញ្ជូនសំណុំរឿងបទល្មើសទៅតុលាការ ។*

*ចំពោះមន្ត្រីរាជការដែលប្រព្រឹត្តបទល្មើសព្រៃឈើ ត្រូវទទួលទោសរដ្ឋបាលបន្ថែមលើទោសទណ្ឌដែលកំណត់ក្នុងច្បាប់នេះ ។*

- ***ទណ្ឌកម្ម :***

គឺជាការដាក់ទោស ឬ ផ្តន្ទាទោសទៅលើជនល្មើស ។

- ***ពិន័យអន្តរការណ៍ :***

គឺជាការពិន័យជាប្រាក់ចំពោះបទល្មើសព្រៃឈើណាមួយ ដែលបំពានទៅនឹងមាត្រានានានៃច្បាប់ស្តីពីព្រៃឈើ ។ ការពិន័យអន្តរការណ៍លើបទល្មើសព្រៃឈើជាសមត្ថកិច្ចរបស់រដ្ឋបាលព្រៃឈើដែលច្បាប់ស្តីពីព្រៃឈើបានផ្តល់អំណាចឱ្យ ។ ក្នុងករណីជនល្មើសបានសារភាពទោសកំហុស និង យល់ព្រមទទួលយកការសម្រុះសម្រួលដោយការពិន័យអន្តរការណ៍ នោះជនល្មើសនឹងរួចផុតពីការចោទប្រកាន់ទៅតុលាការតាមរយៈបណ្តឹងអាជ្ញារបស់រដ្ឋបាលព្រៃឈើ ។

- ***ទោសជាប់ពន្ធនាគារ :***

គឺជាទណ្ឌកម្មចំពោះជនដែលប្រព្រឹត្តល្មើសនឹងច្បាប់ ដោយបំបាត់សេរីភាព ចូលមន្ទីរឃុំឃាំង តាមពេលកំណត់មួយ ដែលតុលាការបានសម្រេចដាក់ទោស ។

- ***រឹបអូសវត្ថុតាង :***

គឺជាការរឹបអូសផល អនុផលព្រៃឈើ សំភារៈ ឧបករណ៍ និងមធ្យោបាយផ្សេងៗដែលបំរើឱ្យសកម្មភាពល្មើស។

- ***ការជួសជុលការខូតខាត :***

គឺតំរូវឱ្យជនល្មើសដែលបានធ្វើឱ្យប៉ះពាល់ដល់និរន្តរភាពនៃធនធានព្រៃឈើ ផលប្រយោជន៍សេដ្ឋកិច្ច សង្គម និង បរិស្ថាន ការអភិរក្សជីវសាស្ត្រចំរុះ និង មរតកវប្បធម៌ ធ្វើការជួសជុល ឬ ស្តាបនា ឬ ដាំ ឬ បំពេញ ឬ ស្តារ ឬ សងឱ្យមានសភាពលក្ខណៈទ្រង់ទ្រាយប្រហាក់ប្រហែលដើមវិញ។

- ***ការព្រមាន :***

គឺជាការបន្ទោសដោយផ្ទាល់ ឬលិខិតជាលាយលក្ខណ៍អក្សរដោយរដ្ឋបាលព្រៃឈើចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គល ណាដែលបានប្រព្រឹត្តខុសឆ្គងទៅនឹងការអនុវត្ត ដែលមិនសមស្របតាមផែនការ និង គោលការណ៍បច្ចេកទេស ក្នុងទំហំ ពុំទាន់ដល់កំរិតជាកពិន័យ ។

- ***ការដកហូតលិខិតអនុញ្ញាត :***

គឺការយកវិញដោយរដ្ឋបាលព្រៃឈើនូវលិខិតអនុញ្ញាតដែលប្រគល់ឱ្យរូបវន្តបុគ្គល ឬ នីតិបុគ្គលដែលប្រើប្រាស់ លិខិតអនុញ្ញាតផ្ទុយពីខ្លឹមសារដែលមានចែងក្នុងលិខិតអនុញ្ញាត។

- ***ការព្យួរកិច្ចព្រមព្រៀង :***

គឺការដកហូតជាបណ្តោះអាសន្ននូវកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខាកន្លងមក ដោយសាររូបវន្តបុគ្គល ឬ នីតិ បុគ្គលដែលជាម្ចាស់កិច្ចព្រមព្រៀងបានអនុវត្តខុសពីកិច្ចព្រមព្រៀង ហើយតម្រូវឱ្យត្រូវធ្វើការកែប្រែកំហុសឆ្គង ឬ ជួសជុល ឬ សងការខូតខាតឡើងវិញ ស្របតាមខ្លឹមសារដែលមានចែងនៅក្នុងកិច្ចព្រមព្រៀង។

- ***ការដកហូតកិច្ចព្រមព្រៀង :***

គឺការលុបចោលជាស្ថាពរនូវកិច្ចព្រមព្រៀងដោយសាររូបវន្តបុគ្គល ឬ នីតិបុគ្គល បានប្រព្រឹត្តខុសធ្ងន់ធ្ងរពីកិច្ចព្រម ព្រៀង ដែលមិនអាចកែប្រែបាន។

| **ប្រភេទទណ្ឌកម្ម** | **សិទ្ធិសម្រេច** |
|---|---|
| - ទោសជាប់ពន្ធនាគារ<br>- រឹបអូសដោយតុលាការ<br>- ពិន័យដោយតុលាការ | តុលាការ |
| - ពិន័យអន្តរការណ៍<br>- ការជួសជុលការខូតខាត<br>- ការព្រមាន | រដ្ឋបាលព្រៃឈើ |
| - ការដកហូតលិខិតអនុញ្ញាត<br>- ការព្យួរលិខិតអនុញ្ញាត | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬ រដ្ឋបាលព្រៃឈើ |
| - ការដកហូតកិច្ចព្រមព្រៀង<br>- ការព្យួរកិច្ចព្រមព្រៀង | រាជរដ្ឋាភិបាល |

**មាត្រា ៩១.-**

*រដ្ឋបាលព្រៃឈើមានសិទ្ធិសម្រេចពីការពិន័យអន្តរការណ៍លើបទល្មើសព្រៃឈើ ដូចមានចែងក្នុងមាត្រា ៩៦ នៃច្បាប់នេះ ។ ការពិន័យអន្តរការណ៍លើបទល្មើសព្រៃឈើ អាចធ្វើបានតែក្នុងករណីជនល្មើសសារភាពទោសកំហុស និង យល់ព្រមបង់ប្រាក់ពិន័យ ស្របតាមទោសប្បញ្ញត្តិនៃច្បាប់នេះ ក្នុងរយៈពេលមិនឱ្យលើសពីដប់ប្រាំ (១៥) ថ្ងៃ គិតពីថ្ងៃចេញសេចក្តីសម្រេច ។*

*បែបបទ និង សិទ្ធិសម្រេចពិន័យអន្តរការណ៍ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។*

*ក្នុងការកំណត់បរិមាណទឹកប្រាក់ពិន័យអន្តរការណ៍ ត្រូវពិចារណាលើកត្តាដូចតទៅ :*

*១- ផលប្រយោជន៍សេដ្ឋកិច្ចជាក់ស្តែងពីលទ្ធផលនៃបទល្មើស ។*

*២- ការខូចខាតដល់បរិស្ថាន ។*

*៣- ចំនួននៃការប្រព្រឹត្តល្មើស ។*

*៤- បរិមាណប្រាក់ពិន័យដែលធ្វើឱ្យរាងចាល ។*

*៥- ការប្រព្រឹត្តល្មើសដោយចេតនា ។*

- ***ការពិន័យអន្តរការណ៍លើបទល្មើសព្រៃឈើ :***

ការពិន័យអន្តរកាណ៍អាចអនុវត្តទៅបានតែក្នុងករណីជនល្មើសបានសារភាពទោសកំហុស និង យល់ព្រមបង់ប្រាក់ពិន័យជាលាយលក្ខណ៍អក្សរ តាមនីតិវិធីរបស់រដ្ឋបាលព្រៃឈើ។ ជនល្មើសត្រូវចូលខ្លួនមកបង់ប្រាក់ពិន័យអន្តរការណ៍ឱ្យបានគ្រប់ចំនួនយ៉ាងយូរ ១៥ ថ្ងៃ បន្ទាប់ពីការចេញសេចក្តីសំរេច។ នៅពេលជនល្មើសបានបង់ប្រាក់ពិន័យអន្តរការណ៍រួច រដ្ឋបាលព្រៃឈើអាចអនុញ្ញាតប្រគល់វត្ថុតាងផ្សេងៗទៅឱ្យម្ចាស់ដើមវិញ លើកលែងតែវត្ថុតាងពិតប្រាកដជាផល អនុផលព្រៃឈើ។ ទន្ទឹមនឹងនោះ ជនល្មើសត្រូវទទួលចេញសោហ៊ុយចំណាយលើការដឹកជញ្ជូន និង ការថែរក្សាវត្ថុតាងទាំងអស់តាមការជាក់ស្តែង។ ទឹកប្រាក់ពិន័យអន្តរការណ៍ត្រូវបង់ចូលថវិកាជាតិតាមរយៈរដ្ឋបាលព្រៃឈើ។

ក្រោយរយៈពេល១៥ថ្ងៃ នៃការចេញសេចក្តីសំរេច បើជនល្មើសមិនបានមកបង់ប្រាក់ពិន័យអន្តរការណ៍ទេនោះ រដ្ឋបាលព្រៃឈើ ឬ ខ័ណ្ឌ ឬ ផ្នែករដ្ឋបាលព្រៃឈើមានសមត្ថកិច្ច ត្រូវបញ្ជូនសំណុំរឿងទៅតុលាការ។

- ***ក្នុងការកំណត់បរិមាណទឹកប្រាក់ពិន័យអន្តរការណ៍ត្រូវពិចារណាទៅលើកត្តាដូចខាងក្រោម :***
    - **ផលប្រយោជន៍សេដ្ឋកិច្ចជាក់ស្តែងពីលទ្ធផលនៃបទល្មើស :** គឺការពិន័យតាមតំលៃផល អនុផលព្រៃឈើដែលកំណត់តាមតំលៃទីផ្សារជាមូលដ្ឋាន ហើយមានចែងនៅក្នុងសេចក្តីប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ (ប្រកាសនេះកំពុងស្ថិតនៅក្នុងការពិនិត្យ និង សំរេចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ នៅឡើយ) ។
    - **ការខូចខាតដល់បរិស្ថាន :** គឺជាតំលៃត្រូវបូកបន្ថែមនូវការបង្កឱ្យខូចខាតដល់ប្រភពទឹក បំពុលដី ខ្យល់ ផលិតផលកសិកម្ម សុខភាពមនុស្ស សត្វ ។ល។ ដែលជនល្មើសត្រូវសង ឬ ជួសជុលការខូចខាតនោះ បន្ថែមលើទឹកប្រាក់ពិន័យជាមូលដ្ឋានក្នុងចំនុចទី១ខាងលើ ។
    - **ចំនួននៃការប្រព្រឹត្តល្មើស :** ជាការពិន័យដែលពិចារណាទៅលើចំនួនដងដែលជនល្មើសបានប្រព្រឹត្តល្មើស និង ភាពមិនរាងចាលរបស់ជនល្មើស។ ឧទាហរណ៍ : បើជនល្មើសបានប្រព្រឹត្តបទល្មើសជាលើកទី ១ នោះ

ត្រូវទទួលការពិន័យអន្តរការណ៍ពីរដ្ឋបាលព្រៃឈើចំនួនពីពីរ (២) ទៅបី (៣) ដង នៃតំលៃវត្ថុតាងពិតប្រាកដនៃទីផ្សារ។ បើជនល្មើសត្រូវបានពិន័យអន្តរការណ៍ម្តងរួចហើយៗបានប្រព្រឹត្តបទល្មើសទៀតក្នុងរយៈពេលមួយខែបន្ទាប់ពីការពិន័យលើកទី១ នោះត្រូវទទួលការពិន័យអន្តរការណ៍ពីរដ្ឋបាលព្រៃឈើចំនួនពីពីរ (២) ទៅបួន (៤) ដង នៃតំលៃវត្ថុតាងពិត ប្រាកដនៃទីផ្សារ។

- **បរិមាណប្រាក់ពិន័យដែលធ្វើឱ្យរាងចាល :** គឺជាទឹកប្រាក់ពិន័យជាអតិបរិមាចំពោះជនណាដែលប្រព្រឹត្តបទល្មើសច្រើនលើកច្រើនសារដោយមិនព្រមរាងចាលចំពោះអំពើរបស់ខ្លួន ហើយទឹកប្រាក់ដែលត្រូវពិន័យនេះ អាចរួមបញ្ចូលការពិន័យក្នុងចំនុចទាំង ៣ ខាងលើ។
- **ការប្រព្រឹត្តល្មើសដោយចេតនា :** គឺជាការប្រព្រឹត្តល្មើសដោយគ្រោងទុកជាមុន ឬ មានបំណងច្បាស់លាស់។ ដូចនេះទឹកប្រាក់ពិន័យអន្តរការណ៍ត្រូវគិតក្នុងកំរិតអតិបរិមា។ ឧទាហរណ៍ : ការពិន័យអន្តរការណ៍ក្នុងកំរិតបី (៣) ដង នៃតំលៃវត្ថុតាងពិតប្រាកដនៃទីផ្សារ។

## មាត្រា ៩២.-

*ប្រាក់ពិន័យអន្តរការណ៍ ប្រាក់ពិន័យតាមសាលក្រមតុលាការ ឬប្រាក់បានមកពីការលក់វត្ថុតាង ត្រូវបង់ចូលថវិកាជាតិ ។ រាជរដ្ឋាភិបាលអាចសម្រេចផ្តល់រង្វាន់លើកទឹកចិត្តដល់ប្រជាពលរដ្ឋ និង មន្ត្រីដែលបានចូលរួមក្នុងករណីបង្ក្រាបបទល្មើសព្រៃឈើជាក់លាក់ណាមួយ ។*

- ***វត្ថុតាងនៃបទល្មើសដែលត្រូវលក់យកប្រាក់បង់ចូលថវិកាជាតិ :*** វត្ថុតាងនៃបទល្មើសរួមមាន វត្ថុតាងដែលបានប្រមូលដោយរដ្ឋបាលព្រៃឈើ វត្ថុតាងដែលបានដកហូតក្រោយការពិន័យអន្តរការណ៍ និង វត្ថុតាងដែលបានរឹបអូសដោយតុលាការ។
- ***ការផ្តល់រង្វាន់លើកទឹកចិត្តដល់ប្រជាពលរដ្ឋ និងមន្ត្រីដែលបានចូលរួមក្នុងការបង្ក្រាបបទល្មើសព្រៃឈើ :***

  រង្វាន់លើកទឹកចិត្តអាចផ្តល់ដល់ប្រជាពលរដ្ឋ និង មន្ត្រីដែលបានចូលរួមក្នុងការបង្ក្រាបបទល្មើសព្រៃឈើ មាន :
  - ការផ្តល់ប្រាក់រង្វាន់បានមកពីការពិន័យអន្តរការណ៍ និង ការរឹបអូសវត្ថុតាង ការផ្តល់មេដាយ ប័ណ្ណសរសើរ លិខិតសរសើរ ឬ សំភារៈផ្សេងៗ ។
  - ការតម្លើងតួនាទី និង ឋានន្តរសក្តិដល់មន្ត្រី។
- ***ប្រាក់ពិន័យតាមសាលក្រមតុលាការ :***

  គឺជាទឹកប្រាក់ពិន័យដែលតុលាការបានសម្រេចក្នុងពេលជំនុំជំរះក្តី ដោយតម្រូវឱ្យជនល្មើសបង់តាមសាលក្រមដែលបានកំណត់ ។

## មាត្រា ៩៣.-

*រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវទទួលទណ្ឌកម្មដូចតទៅ :*

*១-ចំពោះបទល្មើសព្រៃឈើថ្នាក់ទី ១ ត្រូវជាប់ពន្ធនាគារពីប្រាំ (៥) ឆ្នាំ ទៅដប់ (១០) ឆ្នាំ និងត្រូវរឹបអូសវត្ថុតាងទាំងអស់មកជាសម្បត្តិរដ្ឋ ។*

*២- ចំពោះបទល្មើសព្រៃឈើថ្នាក់ទី ២ ត្រូវជាប់ពន្ធនាគារពីមួយ (១)ឆ្នាំ ទៅប្រាំ (៥)ឆ្នាំ និង/ឬត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពីដប់លាន (១០.០០០.០០០)រៀល ទៅមួយរយលាន (១០០.០០០.០០០)រៀល។ វត្ថុតាងទាំងអស់ត្រូវរឹបអូសមកជាសម្បត្តិរដ្ឋ ។*

*៣- ចំពោះបទល្មើសព្រៃឈើថ្នាក់ទី ៣ ត្រូវជាប់ពន្ធនាគារពីមួយ (១)ខែ ទៅមួយ (១)ឆ្នាំ ឬ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលាន (១.០០០.០០០)រៀល ទៅដប់លាន (១០.០០០.០០០)រៀល ។ វត្ថុតាងទាំងអស់អាចត្រូវរឹបអូសមកជាសម្បត្តិរដ្ឋ ។*

*៤- ការព្រមាន ការជួសជុលការខូចខាត ការពិន័យអន្តរការណ៍ ការដកហូត ឬការព្យួរកិច្ចព្រមព្រៀង ឬ លិខិតអនុញ្ញាត ។*

*តម្លៃទីផ្សារជាមូលដ្ឋាននៃផល អនុផលព្រៃឈើត្រូវកំណត់ដោយប្រកាសក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីអនុវត្តឯកភាពទូទាំងប្រទេស ។*

- ***បទល្មើសព្រៃឈើថ្នាក់ទី ១ :***

ជាប្រភេទបទល្មើសកំរិតធ្ងន់ធ្ងរជាងគេ ដែលជាប្រភេទបទល្មើសធ្វើឱ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិរដ្ឋ សេដ្ឋកិច្ច បរិស្ថាន សង្គម និង ធនធានធម្មជាតិ។ ជនល្មើសត្រូវជាប់ពន្ធនាគារដោយពុំអាចបង់ប្រាក់ពិន័យជំនួសសកម្មភាពល្មើសដែលខ្លួនបានប្រព្រឹត្តបានឡើយ។ ការផ្តន្ទាទោសនេះ ជាសមត្ថកិច្ចរបស់តុលាការ។

- ***បទល្មើសព្រៃឈើថ្នាក់ទី ២ :***

ជាប្រភេទបទល្មើសថ្នាក់មធ្យម ដែលជនល្មើសអាចត្រូវបានផ្តន្ទាទោសដោយជាប់ពន្ធនាគារ និង ពិន័យជាប្រាក់ ឬ គ្រាន់តែជាប់ពន្ធនាគារ ឬ គ្រាន់តែពិន័យជាប្រាក់។ ការផ្តន្ទាទោសក្នុងកំរិតណាមួយនេះ អាស្រ័យលើការវិនិច្ឆ័យសេចក្តីរបស់តុលាការ យោងតាមទំហំ និង ប្រភេទនៃបទល្មើស។

- ***បទល្មើសព្រៃឈើថ្នាក់ទី ៣ :***

ជាប្រភេទបទល្មើសកំរិតទាប ដែលជនល្មើសអាចត្រូវជាប់ពន្ធនាគារ ឬគ្រាន់តែពិន័យជាប្រាក់។ ការផ្តន្ទាទោសណាមួយនេះអាស្រ័យលើការវិនិច្ឆ័យសេចក្តីរបស់តុលាការ យោងតាមទំហំ និង ប្រភេទនៃបទល្មើស។

- ***ការព្រមាន ការជួសជុលការខូចខាត ការពិន័យអន្តរការណ៍ ការដកហូត ឬការព្យួរកិច្ចព្រមព្រៀង ឬលិខិតអនុញ្ញាត :***

ជាប្រភេទបទល្មើសកំរិតទាបជាងគេ ហើយនីតិវិធីនៃការដោះស្រាយបទល្មើសព្រៃឈើគឺជាសមត្ថកិច្ចរបស់រដ្ឋបាលព្រៃឈើ ឬ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ឬ រាជរដ្ឋាភិបាល អាស្រ័យលើដែនសមត្ថកិច្ច។

## មាត្រា ៩៤.-

*បុគ្គលណាដែលបានប្រព្រឹត្តបទល្មើសព្រៃឈើធ្វើឱ្យប៉ះពាល់ខូចខាតដល់មជ្ឈដ្ឋានព្រៃឈើ ត្រូវចេញថ្លៃស្តារ ឬជួសជុលការខូចខាតឱ្យមានលក្ខខណ្ឌដូចដើមឡើងវិញ ។*

- ***មជ្ឈដ្ឋានព្រៃឈើ :***

គឺជាអន្តរអំពើចំរុះនៅលើផ្ទៃដីមួយជាក់លាក់រវាងបណ្តាភាវៈមានជីវិត (សារពាង្គរុក្ខជាតិ សត្វ មីក្រូសរីរាង្គ) ជាមួយនឹងមជ្ឈដ្ឋានគ្មានជីវិត (អាកាសធាតុ មីក្រូអាកាស ធាតុទឹក ដី) ដែលបង្កនូវស្ថាបនកម្មរបស់ព្រៃឈើ និង ជាឯកតា

បំពេញមុខងារមួយនៅលើសំបកផែនដី ។ មនុស្សរួមជាមួយតម្រូវការផ្នែកសេដ្ឋកិច្ច ប្រពៃណី វប្បធម៌ និង បរិស្ថាន ក៏ជាផ្នែកចំរុះរួមមួយនៃបណ្តាប្រព័ន្ធមជ្ឈដ្ឋានព្រៃឈើដែរ ។

**មាត្រា ៩៥.-**

*រដ្ឋបាលព្រៃឈើអាចចេញលិខិតព្រមាន និង តម្រូវឱ្យជួសជុលការខូចខាតចំពោះសកម្មភាពល្មើសនៅក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ដូចខាងក្រោម :*

*១- ប្រើប្រាស់មធ្យោបាយផ្សេងៗ លែង ឬ ចងសត្វពាហនៈក្នុងតំបន់ព្រៃបម្រុងទុកអចិន្ត្រៃយ៍ ចំការឈើ ឬ ថ្នាលកូនឈើរបស់រដ្ឋ ដោយបំផ្លាញឈើ ឬ កូនឈើនៅទីនោះ ។*

*២- ធ្វើឱ្យរបួស ឬ ធ្វើឱ្យខូចខាតដល់ដើមឈើ ឬ រុក្ខជាតិផ្សេងទៀតដែលកំពុងថែរក្សា ឬ ដែលបានដាំ ។*

*៣- លួច ឬ ធ្វើឱ្យខូចខាតដល់របង បង្គោល ឬ ស្លាកសញ្ញាក្នុងថ្នាលបណ្តុះកូនឈើ ឬ ក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ។*

- ***រដ្ឋបាលព្រៃឈើអាចចេញលិខិតព្រមាន និង តម្រូវឱ្យជួសជុលការខូចខាតចំពោះសកម្មភាពល្មើសនៅក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ :***

ជនគ្រប់រូប ទោះជាសហគមន៍មូលដ្ឋាន ជនជាតិដើមក្តី ត្រូវតែទទួលលិខិតព្រមាន និង តម្រូវឱ្យជួសជុលការខូចខាត ចំពោះសកម្មភាពល្មើសនៅក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ដូចមានចែងក្នុងចំណុចទាំងបីនៃមាត្រា៩៥នេះ ហើយត្រូវទទួលការព្រមាន និង បង់ថ្លៃជួសជុលការខូចខាត ទៅតាមទំហំដែលបានប្រព្រឹត្តដូចមានចែងក្នុងច្បាប់នេះដែរ ។

**មាត្រា ៩៦.-**

*ត្រូវទទួលពិន័យអន្តរការណ៍ពីរដ្ឋបាលព្រៃឈើជាប្រាក់ចំនួនពីពីរ (២) ទៅបី (៣) ដងនៃតម្លៃវត្ថុតាងពិតប្រាកដនៃទីផ្សារចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសណាមួយ ដូចខាងក្រោម :*

*១- កាប់ដើមឈើដែលគ្មានស្លាកសញ្ញាសំគាល់អនុញ្ញាតឱ្យកាប់រំលំ ។*

*២- ដឹកជញ្ជូនផល អនុផលព្រៃឈើដោយគ្មានលិខិតអនុញ្ញាត ។*

*៣- ធ្វើសន្និធិផល អនុផលព្រៃឈើដោយគ្មានលិខិតអនុញ្ញាត ។*

*៤-ដឹកជញ្ជូនផល អនុផលព្រៃឈើខុសទិសដៅ លើសបរិមាណកំណត់ក្នុងលិខិតអនុញ្ញាតដឹកជញ្ជូន ។*

*៥- ប្រើប្រាស់លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើហួសសុពលភាព ។*

*៦- មានយថាប្រភេទផល អនុផលព្រៃឈើខុសពីការកំណត់ក្នុងលិខិតអនុញ្ញាតដឹកជញ្ជូន ។*

*៧- ធ្វើសន្និធិផល អនុផលព្រៃឈើលើសពីលិខិតអនុញ្ញាត ។*

*៨- នាំចេញផល អនុផលព្រៃឈើ គ្រាប់ពូជ និងប្រភេទរុក្ខជាតិព្រៃដែលលើសពីការកំណត់ក្នុងអាជ្ញាប័ណ្ណ ។*

*៩- កាប់រំលំ អារ ច្រៀក និង ចាំងឈើមូលក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ឬ ប្រើរណារយន្តជាមធ្យោបាយប្រមូលផលព្រៃឈើដោយគ្មានលិខិតអនុញ្ញាត ឬ គ្មានស្លាកសញ្ញា ។*

*១០- ប្រមូលផល អនុផលព្រៃឈើក្រៅម៉ោងអនុញ្ញាត ។*

*១១- ដឹកជញ្ជូនផល អនុផលព្រៃឈើដែលកាប់រំលំ ឬប្រមូលយកមកដោយផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ។*

*១២- ផល អនុផលព្រៃឈើដែលយកមកកែច្នៃ ត្រូវបានកាប់ ឬ ប្រមូលដោយផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ។*

*១៣- ផល អនុផលព្រៃឈើគ្រប់ប្រភេទដែលលក់ដូរ ចែកចាយបានមកពីការកាប់ ឬ រុករក ដឹកជញ្ជូន កែច្នៃ ដែលផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ។*

*១៤-ផល អនុផលព្រៃឈើគ្រប់ប្រភេទដែលបានមកពីការប្រមូលផល ដឹកជញ្ជូន កែច្នៃ ដែលផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ។*

*១៥-នាំចេញផល អនុផលព្រៃឈើដែលអាជ្ញាប័ណ្ណគ្មានចុះទិដ្ឋាការដោយប្រធានរដ្ឋបាលព្រៃឈើ ។*

*១៦- ចិញ្ចឹម បង្កាត់ពូជប្រភេទសត្វព្រៃក្នុងក្រុមជិតផុតពូជ ។*

*១៧- យកធ្វើជាកម្មសិទ្ធិ កែច្នៃសំណាក សន្និធិ ដឹកជញ្ជូន ឬ នាំចូលសត្វព្រៃរស់ និង សំណាកក្នុងក្រុមមានដោយកម្រ ។*

*១៨- ចិញ្ចឹម បង្កាត់ពូជប្រភេទសត្វព្រៃក្នុងក្រុមមានដោយកម្រ ។*

*១៩- ដឹកជញ្ជូន ធ្វើពាណិជ្ជកម្ម សន្និធិ កែច្នៃសំណាក ឬ នាំចូលសត្វព្រៃរស់ និង សំណាកក្នុងក្រុមមានដោយបង្គួរដោយគ្មានលិខិតអនុញ្ញាត ។*

*២០- បរបាញ់ក្នុងទីសាធារណៈ ។*

*ជនណាប្រព្រឹត្តបទល្មើសដូចមានចែងក្នុងកឋាខ័ណ្ឌទី ១ នៃមាត្រានេះមិនរាងចាលក្នុងរយៈពេលមួយ (១)ខែ ត្រូវទទួលការពិន័យអន្តរការណ៍ពីរដ្ឋបាលព្រៃឈើជាប្រាក់ចំនួនពីពីរ(២) ទៅបួន (៤)ដង នៃតម្លៃវត្ថុតាងពិតប្រាកដនៃទីផ្សារ ។ វត្ថុតាងពិតប្រាកដនៃបទល្មើសព្រៃឈើ ត្រូវរឹបអូសជាសម្បត្តិរដ្ឋស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។ វត្ថុតាងផ្សេងទៀតក្រៅពីផល អនុផលព្រៃឈើអាចប្រគល់ឱ្យសាមីជនវិញតែក្នុងករណីប្រព្រឹត្តល្មើសនឹងមាត្រា ៩៦ នៃច្បាប់នេះ ។*

- ***កាប់ដើមឈើដែលគ្មានស្លាកសញ្ញាសំគាល់អនុញ្ញាតឱ្យកាប់រំលំ :***

ក្នុងការធ្វើអាជីវកម្មឈើនៅក្នុងព្រៃសម្បទាន ឬ ព្រៃគុបរបស់ខ្លួន ព្រៃសម្បទានិក ឬ ម្ចាស់ព្រៃគុបត្រូវកាប់ដើមឈើណាដែលមន្ត្រីរដ្ឋបាលព្រៃឈើដៅឱ្យកាប់ (មានស្លាកសញ្ញាសំគាល់ឱ្យកាប់)។ ការកាប់ដើមឈើដែលគ្មានស្លាកសញ្ញាសំគាល់ឱ្យកាប់ ឬ ការកាប់ឈើដែលដាក់ស្លាកសញ្ញាសំគាល់បន្សល់ទុកពូជ ជាអំពើល្មើស ហើយម្ចាស់ព្រៃសម្បទាន ឬ ម្ចាស់ព្រៃគុប ត្រូវទទួលការពិន័យអន្តរការណ៍ពីរដ្ឋបាលព្រៃឈើ ហើយឈើដែលបានកាប់រំលំទាំងនោះត្រូវដកហូតជាសម្បត្តិរដ្ឋ ដោយប្រកាសលក់ដេញថ្លៃជាសាធារណៈយកប្រាក់ បង់ចូលថវិការដ្ឋ។

- ***ដឹកជញ្ជូនផល អនុផលព្រៃឈើដោយគ្មានលិខិតអនុញ្ញាត :***

ផល អនុផលព្រៃឈើគ្រប់ប្រភេទដែលចរាចរក្នុងទូទាំងប្រទេស ត្រូវមានលិខិតអនុញ្ញាតដឹកជញ្ជូនចេញដោយរដ្ឋបាលព្រៃឈើ។ ដូចនេះ ការដឹកជញ្ជូនផល អនុផលព្រៃឈើពីទីតាំងមួយទៅកាន់ទីតាំងមួយទៀត ត្រូវមានលិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើចេញដោយផ្នែករដ្ឋបាលព្រៃឈើដែលមានដែនសមត្ថកិច្ចនៅទីនោះ។ ការដឹកជញ្ជូនដោយគ្មានលិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើ ត្រូវទទួលការពិន័យអន្តរការណ៍ពីរដ្ឋបាលព្រៃឈើ ហើយផល អនុផលព្រៃឈើដែលបានដឹកជញ្ជូនដោយគ្មានលិខិតអនុញ្ញាតនោះ ត្រូវដកហូតជាសម្បត្តិរដ្ឋ ដោយប្រកាសលក់ដេញថ្លៃជាសាធារណៈយកប្រាក់បង់ចូលថវិការដ្ឋ។

- ***ធ្វើសន្និធិផល អនុផលព្រៃឈើដោយគ្មានលិខិតអនុញ្ញាត :***

ផល អនុផលព្រៃឈើគ្រប់ប្រភេទដែលជាសន្និធិ ទោះជានៅទីណាក៏ដោយ ក៏ត្រូវអមដោយលិខិតអនុញ្ញាតដឹកជញ្ជូន ឬ លិខិតអនុញ្ញាតសន្និធិចេញឱ្យដោយរដ្ឋបាលព្រៃឈើ។ ការសន្និធិដោយគ្មានលិខិតអនុញ្ញាតដឹកជញ្ជូនផល អនុ

ផលព្រៃឈើ ឬ លិខិតអនុញ្ញាតឱ្យសន្និធិ ត្រូវទទួលការពិន័យអន្តរការណ៍ពីរដ្ឋបាលព្រៃឈើ ហើយផល អនុផលព្រៃឈើដែលបានសន្និធិនោះ ត្រូវប្រមូលទុកជាសម្បត្តិរដ្ឋ ដោយប្រកាសលក់ដេញថ្លៃជាសាធារណៈយកប្រាក់បង់ចូលថវិការដ្ឋ។

- ***ដឹកជញ្ជូនផល អនុផលព្រៃឈើខុសទិសដៅ លើសបរិមាណកំណត់ក្នុងលិខិតអនុញ្ញាតដឹកជញ្ជូន :***

ការដឹកជញ្ជូនផល អនុផលព្រៃឈើគ្រប់ប្រភេទខុសទិសដៅក្នុងលិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើ ត្រូវទទួលការពិន័យអន្តរការណ៍ពីរដ្ឋបាលព្រៃឈើ ហើយផល អនុផលព្រៃឈើ ដែលបានដឹកជញ្ជូនខុសទិសដៅនោះ ត្រូវដកហូតជាសម្បត្តិរដ្ឋ ដោយប្រកាសលក់ដេញថ្លៃជាសាធារណៈយកប្រាក់បង់ចូលថវិការដ្ឋ។

ការដឹកជញ្ជូនផល អនុផលព្រៃឈើគ្រប់ប្រភេទលើសបរិមាណកំណត់ក្នុងលិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើ មន្ត្រីរដ្ឋបាលព្រៃឈើត្រូវចាប់ឃាត់ទាំងផល អនុផលព្រៃឈើដែលមានក្នុងលិខិតអនុញ្ញាត ទាំងផល អនុផលព្រៃឈើលើសពីលិខិតអនុញ្ញាត ព្រមទាំងមធ្យោបាយដឹកជញ្ជូន។ ផល អនុផលព្រៃឈើដែលដឹកលើសពីលិខិតអនុញ្ញាត ត្រូវទទួលការពិន័យអន្តរការណ៍ពីរដ្ឋបាលព្រៃឈើ ហើយផល អនុផលព្រៃឈើដែលបានដឹកលើសនោះត្រូវដកហូតជាសម្បត្តិរដ្ឋ ដោយប្រកាសលក់ដេញថ្លៃជាសាធារណៈយកប្រាក់បង់ចូលថវិការដ្ឋ។ រីឯផល អនុផលព្រៃឈើដែលមានក្នុងលិខិតអនុញ្ញាតត្រូវប្រគល់ឱ្យវិញ បន្ទាប់ពីជនល្មើសបានបង់ប្រាក់ពិន័យអន្តរការណ៍លើបរិមាណផល អនុផលព្រៃឈើដែលបានដឹកលើសរួចមក។

- ***ប្រើប្រាស់លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើហួសសុពលភាព :***

ការដឹកជញ្ជូនផល អនុផលព្រៃឈើគ្រប់ប្រភេទហួសរយៈពេលកំណត់អនុញ្ញាតឱ្យដឹកជញ្ជូន ត្រូវទទួលការពិន័យអន្តរការណ៍ពីរដ្ឋបាលព្រៃឈើ ហើយផល អនុផលព្រៃឈើដែលបានដឹកជញ្ជូននោះ ត្រូវដកហូតជាសម្បត្តិរដ្ឋ ដោយប្រកាសលក់ដេញថ្លៃជាសាធារណៈ។

- ***មានយថាប្រភេទផល អនុផលព្រៃឈើខុសពីការកំណត់ក្នុងលិខិតអនុញ្ញាតដឹកជញ្ជូន :***

ការដឹកជញ្ជូនផល អនុផលព្រៃឈើគ្រប់ប្រភេទដែលមានយថាប្រភេទផល អនុផលព្រៃឈើខុសពីការកំណត់ក្នុងលិខិតអនុញ្ញាត ត្រូវទទួលការពិន័យអន្តរការណ៍ពីរដ្ឋបាលព្រៃឈើ ហើយផល អនុផលព្រៃឈើដែលបានដឹកជញ្ជូននោះ ត្រូវដកហូតជាសម្បត្តិរដ្ឋ ដោយប្រកាសលក់ដេញថ្លៃជាសាធារណៈ។ ឧទាហរណ៍ : ក្នុងលិខិតអនុញ្ញាត គឺដឹកជញ្ជូនឈើអារប្រភេទលេខ២ (ឈើទាល) ប៉ុន្តែនៅពេលដឹកជញ្ជូនពិនិត្យឃើញឈើអារប្រភេទប្រណិត (បេង) ទៅវិញ។

- ***ធ្វើសន្និធិផល អនុផលព្រៃឈើលើសពីលិខិតអនុញ្ញាត :***

ការសន្និធិផល អនុផលព្រៃឈើគ្រប់ប្រភេទលើសបរិមាណកំណត់ក្នុងលិខិតអនុញ្ញាតឱ្យសន្និធិ ត្រូវទទួលការពិន័យអន្តរការណ៍ពីរដ្ឋបាលព្រៃឈើ ហើយផល អនុផលព្រៃឈើដែលបានសន្និធិលើសនោះត្រូវដកហូតជាសម្បត្តិរដ្ឋ ដោយប្រកាសលក់ដេញថ្លៃជាសាធារណៈ។

- ***នាំចេញផល អនុផលព្រៃឈើ គ្រាប់ពូជ និង ប្រភេទរុក្ខជាតិព្រៃដែលលើសពីការកំណត់ក្នុងអាជ្ញាប័ណ្ណ :***

ការនាំចេញផល អនុផលព្រៃឈើ គ្រាប់ពូជ និង ប្រភេទរុក្ខជាតិព្រៃ ដែលលើសបរិមាណកំណត់ក្នុងអាជ្ញាប័ណ្ណនាំចេញ (អាជ្ញាប័ណ្ណចេញដោយក្រសួងពាណិជ្ជកម្ម ដោយមានការចុះទិដ្ឋាការរបស់ប្រធានរដ្ឋបាលព្រៃឈើ) ត្រូវទទួលការពិន័យអន្តរការណ៍ពីរដ្ឋបាលព្រៃឈើ ហើយផល អនុផលព្រៃឈើ គ្រាប់ពូជ និង ប្រភេទរុក្ខជាតិព្រៃដែលនាំចេញលើសនោះ ត្រូវដកហូតជាសម្បត្តិរដ្ឋ ដោយប្រកាសលក់ដេញថ្លៃជាសាធារណៈយកប្រាក់បង់ចូលថវិការដ្ឋ។

- ***កាប់រំលំ អារ ច្រៀក និង ចាំងឈើមូលក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ឬ ប្រើរណារយន្តជាមធ្យោបាយប្រមូលផលព្រៃឈើដោយគ្មានលិខិតអនុញ្ញាត ឬ គ្មានស្លាកសញ្ញា :***

រូបវន្តបុគ្គល ឬ នីតិបុគ្គល រួមទាំងម្ចាស់ព្រៃគុប ម្ចាស់ព្រៃសម្បទាន ដែលបានកាប់រំលំ អារ ច្រៀក និង ចាំងឈើមូលក្នុងដែនព្រៃបំរុងទុកអចិន្ត្រៃយ៍ដោយគ្មានលិខិតអនុញ្ញាត ឬ គ្មានស្លាកសញ្ញាសំគាល់ឱ្យកាប់រំលំពីរដ្ឋបាលព្រៃឈើ ត្រូវទទួលការពិន័យអន្តរការណ៍ពីរដ្ឋបាលព្រៃឈើចំពោះឈើដែលបានកាប់រំលំ អារ ច្រៀក និង ចាំងនោះ ហើយឈើដែលបានកាប់រំលំ អារ ច្រៀក និង ចាំងដឹកជញ្ជូននោះ ត្រូវប្រមូលទុកជាសម្បត្តិរដ្ឋ ដោយប្រកាសលក់ដេញថ្លៃជាសាធារណៈយកប្រាក់បង់ចូលថវិការដ្ឋ។

រូបវន្តបុគ្គល ឬ នីតិបុគ្គល រួមទាំងម្ចាស់ព្រៃគុប ម្ចាស់ព្រៃសម្បទាន ដែលបានប្រើប្រាស់រណារយន្តជាមធ្យោបាយប្រមូលផលព្រៃឈើក្នុងដែនព្រៃបំរុងទុកអចិន្ត្រៃយ៍ដោយគ្មានលិខិតអនុញ្ញាត ឬ គ្មានស្លាកសញ្ញាសំគាល់ពីរដ្ឋបាលព្រៃឈើត្រូវទទួលការពិន័យអន្តរការណ៍ពីរដ្ឋបាលព្រៃឈើចំពោះផលព្រៃឈើដែលបានប្រមូល ហើយផលព្រៃឈើដែលបានប្រមូលនោះ ត្រូវដកហូតទុកជាសម្បត្តិរដ្ឋ ដោយប្រកាសលក់ដេញថ្លៃជាសាធារណៈយកប្រាក់បង់ចូលថវិការដ្ឋ។ ចំណែករណារយន្តដែលបានប្រើប្រាស់ជាមធ្យោបាយបំរើឱ្យការប្រមូលផលព្រៃឈើ ត្រូវដកហូតដើម្បីធ្វើការបំផ្លាញចោល តាមបទបញ្ជាលេខ ០១ បប ចុះថ្ងៃទី ០៩-០៦-២០០៤ និង បទបញ្ជាលេខ ០២ ចុះថ្ងៃទី ២២-០៩-២០០៦ របស់រាជរដ្ឋាភិបាល។

- ***ប្រមូលផល អនុផលព្រៃឈើក្រៅម៉ោងអនុញ្ញាត :***

ម្ចាស់ព្រៃគុប ឬ ម្ចាស់ព្រៃសម្បទាន ដែលបានប្រមូលផល អនុផលព្រៃឈើក្នុងព្រៃគុប ឬ ព្រៃសម្បទានរបស់ខ្លួន ក្រៅម៉ោងអនុញ្ញាត (ម៉ោងអនុញ្ញាតឱ្យប្រមូលផល អនុផលព្រៃឈើ ចាប់ពីម៉ោង ៦ ព្រឹក ដល់ម៉ោង ៦ ល្ងាច) ត្រូវទទួលការពិន័យអន្តរការណ៍ពីរដ្ឋបាលព្រៃឈើចំពោះផល អនុផលព្រៃឈើដែលបានប្រមូលក្រៅម៉ោងអនុញ្ញាត ហើយផល អនុផលព្រៃឈើដែលបានប្រមូលនោះ ត្រូវដកហូតទុកជាសម្បត្តិរដ្ឋ ដោយប្រកាសលក់ដេញថ្លៃជាសាធារណៈយកប្រាក់បង់ចូលថវិការដ្ឋ។

- ***ដឹកជញ្ជូនផល អនុផលព្រៃឈើដែលកាប់រំលំ ឬ ប្រមូលយកមកដោយផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ :***

ការដឹកជញ្ជូនផល អនុផលព្រៃឈើដែលបានកាប់រំលំ ឬ ប្រមូលផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់ស្តីពីព្រៃឈើ ត្រូវហាមឃាត់។ ការដឹកជញ្ជូនផល អនុផលព្រៃឈើក្នុងករណីនេះ ត្រូវទទួលការពិន័យអន្តរការណ៍ពីរដ្ឋបាលព្រៃឈើ ហើយផល អនុផលព្រៃឈើដែលបានដឹកជញ្ជូន ត្រូវដកហូតទុកជាសម្បត្តិរដ្ឋ ដោយប្រកាសលក់ដេញថ្លៃជាសាធារណៈយកប្រាក់បង់ចូលថវិការដ្ឋ។

- ***ផល អនុផលព្រៃឈើដែលយកមកកែច្នៃ ត្រូវបានកាប់ ឬ ប្រមូលដោយផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ :***

ផល អនុផលព្រៃឈើដែលយកមកកែច្នៃនៅតាមរោងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើ ដេប៉ូទិញ-លក់ រោងអារឈើ ។ល។ ត្រូវបានមកពីប្រភពស្របច្បាប់ (ផល អនុផលព្រៃឈើពីព្រៃគុប ព្រៃសម្បទាន ការដេញថ្លៃលក់ជាសាធារណៈតាមរយៈការប្រមូលដោយរដ្ឋបាលព្រៃឈើ ការដកហូតដោយការពិន័យអន្តរការណ៍ ការរឹបអូសដោយតុលាការ)។ ផល អនុផលព្រៃឈើដែលមានប្រភពមិនស្របច្បាប់ ហើយត្រូវបានយកមកធ្វើការកែច្នៃ ត្រូវទទួលការពិន័យអន្តរការណ៍ពីរដ្ឋបាលព្រៃឈើ ហើយផល អនុផលព្រៃឈើនោះ ត្រូវដកហូតទុកជាសម្បត្តិរដ្ឋ ដោយប្រកាសលក់ដេញថ្លៃជាសាធារណៈយកប្រាក់បង់ចូលថវិការដ្ឋ។

- ***ផល អនុផលព្រៃឈើគ្រប់ប្រភេទដែលលក់ដូរ ចែកចាយ បានមកពីការកាប់ ឬ រុករក ដឹកជញ្ជូន កែច្នៃ ដែលផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ :***

ផល អនុផលព្រៃឈើដែលដាក់លក់នៅតាមដេប៉ូឈើ រោងសិប្បកម្មផល អនុផលព្រៃឈើ រោងអារឈើ ។ល។ ត្រូវបានមកពីប្រភពស្របច្បាប់ (ផល អនុផលព្រៃឈើពីព្រៃគុប ព្រៃសម្បទាន ការដេញថ្លៃលក់ជាសាធារណៈតាមរយៈ

ការប្រមូលដោយរដ្ឋបាលព្រៃឈើ ការដកហូតដោយការពិន័យអន្តរការណ៍ ការរឹបអូសដោយតុលាការ) ។ ផល អនុផលព្រៃឈើដែលមានប្រភពមិនស្របច្បាប់ ហើយត្រូវបានយកមកលក់ និង ចែកចាយ ត្រូវទទួលការពិន័យអន្តរការណ៍ពីរដ្ឋបាលព្រៃឈើ ហើយផល អនុផលព្រៃឈើនោះ ត្រូវដកហូតទុកជាសម្បត្តិរដ្ឋ ដោយប្រកាសលក់ដេញថ្លៃជាសាធារណៈយកប្រាក់បង់ចូលថវិការដ្ឋ ។

- ***ផល អនុផលព្រៃឈើគ្រប់ប្រភេទដែលបានមកពីការប្រមូលផល ដឹកជញ្ជូន កែច្នៃដែលផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ :***

ផល អនុផលព្រៃឈើគ្រប់ប្រភេទដែលបានមកពីការប្រមូលផល ដឹកជញ្ជូន កែច្នៃ ដែលផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់ស្តីពីព្រៃឈើ ត្រូវទទួលការពិន័យអន្តរការណ៍ពីរដ្ឋបាលព្រៃឈើ ហើយផល អនុផលព្រៃឈើនោះ ត្រូវដកហូតទុកជាសម្បត្តិរដ្ឋ ដោយប្រកាសលក់ដេញថ្លៃជាសាធារណៈយកប្រាក់បង់ចូលថវិការដ្ឋ ។

- ***នាំចេញផល អនុផលព្រៃឈើដែលអាជ្ញាប័ណ្ណគ្មានចុះទិដ្ឋាការដោយប្រធានរដ្ឋបាលព្រៃឈើ :***

ការនាំចេញផល អនុផលព្រៃឈើ ត្រូវមានអាជ្ញាប័ណ្ណនាំចេញ ដែលចេញដោយក្រសួងពាណិជ្ជកម្ម ដោយមានការចុះទិដ្ឋាការរបស់ប្រធានរដ្ឋបាលព្រៃឈើលើអាជ្ញាប័ណ្ណនាំចេញនោះ ។ អាជ្ញាប័ណ្ណនាំចេញផល អនុផលព្រៃឈើដែលគ្មានចុះទិដ្ឋាការដោយប្រធានរដ្ឋបាលព្រៃឈើ ត្រូវទទួលការពិន័យអន្តរការណ៍ពីរដ្ឋបាលព្រៃឈើ ហើយផល អនុផលព្រៃឈើដែលធ្វើការនាំចេញនោះត្រូវដកហូតជាសម្បត្តិរដ្ឋ ដោយប្រកាសលក់ដេញថ្លៃជាសាធារណៈយកប្រាក់បង់ចូលរដ្ឋ ។

- ***ចិញ្ចឹម បង្កាត់ពូជប្រភេទសត្វព្រៃក្នុងក្រុមជិតផុតពូជ ឬ ក្រុមមានដោយកម្រ :***

ការចិញ្ចឹម ការបង្កាត់ពូជប្រភេទសត្វព្រៃក្នុងក្រុមជិតផុតពូជ ឬ ក្រុមមានដោយកម្រ ត្រូវហាមឃាត់ និង ត្រូវទទួលការពិន័យអន្តរការណ៍ពីរដ្ឋបាលព្រៃឈើ ហើយសត្វព្រៃដែលបានចិញ្ចឹម ឬ បង្កាត់ពូជនោះ ត្រូវដកហូត ដោយយកទៅដោះលែងក្នុងព្រៃធម្មជាតិ ឬ យកទៅអភិរក្សនៅមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ ឬ សួនសត្វ ។

- ***យកធ្វើជាកម្មសិទ្ធិ កែច្នៃសំណាក សន្និធិ ដឹកជញ្ជូន ឬ នាំចូលសត្វព្រៃរស់ និង សំណាកក្នុងក្រុមមានដោយកម្រ :***

ការយកធ្វើជាកម្មសិទ្ធិ កែច្នៃសំណាក សន្និធិ ដឹកជញ្ជូន ឬ នាំចូលសត្វព្រៃរស់ និង សំណាកក្នុងក្រុមមានដោយកំរត្រូវហាមឃាត់ និងត្រូវទទួលការពិន័យអន្តរការណ៍ពីរដ្ឋបាលព្រៃឈើ ហើយវត្ថុតាងពិតប្រាកដនៃបទល្មើសត្រូវដកហូតដោយយកទៅបំផ្លាញចោល ដោះលែងក្នុងព្រៃធម្មជាតិ ឬ យកទៅអភិរក្សនៅមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ ឬ សួនសត្វ ។

- ***ដឹកជញ្ជូន ធ្វើពាណិជ្ជកម្ម សន្និធិ កែច្នៃសំណាក ឬ នាំចូលសត្វព្រៃរស់ និង សំណាកក្នុងក្រុមមានដោយបង្គួរ ដោយគ្មានលិខិតអនុញ្ញាត :***

ការដឹកជញ្ជូន ធ្វើពាណិជ្ជកម្ម សន្និធិ កែច្នៃសំណាក ឬ នាំចូលសត្វព្រៃរស់ និង សំណាកក្នុងក្រុមមានដោយបង្គួរត្រូវមានលិខិតអនុញ្ញាតពីរដ្ឋបាលព្រៃឈើ ។ ក្នុងករណីគ្មានលិខិតអនុញ្ញាតពីរដ្ឋបាលព្រៃឈើទេ ត្រូវទទួលការពិន័យអន្តរការណ៍ពីរដ្ឋបាលព្រៃឈើ ហើយវត្ថុតាងពិតប្រាកដនៃបទល្មើសត្រូវដកហូត ដោយយកទៅបំផ្លាញចោល ដោះលែងក្នុងព្រៃធម្មជាតិ ឬ យកទៅអភិរក្សនៅមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ ឬ សួនសត្វ ។

- ***បរបាញ់ក្នុងទីសាធារណៈ :***

ការបរបាញ់សត្វព្រៃក្នុងទីសាធារណៈត្រូវហាមឃាត់ និង ត្រូវទទួលការពិន័យអន្តរការណ៍ពីរដ្ឋបាលព្រៃឈើ ហើយវត្ថុតាងពិតប្រាកដនៃបទល្មើសត្រូវដកហូត ដោយយកទៅបំផ្លាញចោល ដោះលែងក្នុងព្រៃធម្មជាតិ ឬ យកទៅអភិរក្សនៅមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃ ឬ សួនសត្វ ។

- ***ការទទួលពិន័យអន្តរការណ៍ពីរដ្ឋបាលព្រៃឈើ :***

ជនណាដែលបានប្រព្រឹត្តបទល្មើសណាមួយក្នុងកឋាខ័ណ្ឌទី១ នៃមាត្រា ៩៦ នេះ ត្រូវទទួលការពិន័យអន្តរការណ៍ពីរដ្ឋបាលព្រៃឈើ នូវទឹកប្រាក់ចំនួនពីពីរ (២) ទៅបី (៣) ដង នៃតំលៃវត្ថុតាងពិតប្រាកដនៃទីផ្សារជាមូលដ្ឋាន ដូចមានកំណត់នៅក្នុងប្រកាសស្តីពីតម្លៃទីផ្សារមូលដ្ឋាននៃផលអនុផលព្រៃឈើសំរាប់ពិន័យអន្តរការណ៍លើបទល្មើសព្រៃឈើ បើមិនរាងចាលក្នុងរយៈពេលមួយ (១)ខែ ត្រូវទទួលការពិន័យអន្តរការណ៍ពីរដ្ឋបាលព្រៃឈើជាប្រាក់ចំនួនពីពីរ (២) ទៅបួន (៤) ដង នៃតម្លៃវត្ថុតាងពិតប្រាកដនៃទីផ្សារជាមូលដ្ឋាន។

វត្ថុតាងពិតប្រាកដនៃបទល្មើសព្រៃឈើ (ផល អនុផលព្រៃឈើ) ត្រូវរឹបអូសជាសម្បត្តិរដ្ឋ។ រីឯវត្ថុតាងផ្សេងទៀតក្រៅពីផល អនុផលព្រៃឈើអាចប្រគល់ឱ្យសាមីជនវិញ។

**មាត្រា ៩៧.-**

*ត្រូវផ្តន្ទាទោសក្រោមបទល្មើសព្រៃឈើថ្នាក់ទី ១ ដែលត្រូវជាប់ពន្ធនាគារពីប្រាំ (៥)ឆ្នាំ ទៅដប់ (១០)ឆ្នាំ និង ត្រូវរឹបអូសវត្ថុតាងទាំងអស់មកជាសម្បត្តិរដ្ឋ ដកហូតកិច្ចព្រមព្រៀង អាជ្ញាប័ណ្ណ លិខិតអនុញ្ញាត និង កំទេចចោលវត្ថុតាងក្លែង ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម :*

*១- ក្លែងញញួរត្រា ឬប្រើញញួរត្រាក្លែង ឬបំផ្លាញស្នាមញញួរត្រារដ្ឋបាលព្រៃឈើដែលវាយលើឈើហ៊ុប ។*

*២- ក្លែងបន្លំដោយស្លៀកពាក់ឯកសណ្ឋានពាក់សញ្ញាសម្គាល់ ឬ ពាក់ឋានន្តរសក្តិរបស់មន្ត្រីរដ្ឋបាលព្រៃឈើ ។*

*៣- ក្លែងបន្លំលិខិតសាធារណៈដែលពាក់ព័ន្ធនឹងវិស័យព្រៃឈើ ឬ សត្វព្រៃ។*

*៤- បំផ្លាញ លាក់បាំង លក់ ឬ លួចវត្ថុតាងព្រៃឈើ ។*

*៥- កំទេច ផ្លាស់ប្តូរ លុបបំបាត់ ឬធ្វើឱ្យខូចខាតដល់ព្រំសីមានៃតំបន់ព្រៃឈើ ។*

*៦- កាប់រានព្រៃ ឈូសឆាយដីព្រៃ ហ៊ុំព័ទ្ធកាន់កាប់ដីព្រៃ ។*

*៧- បង្កឱ្យភ្លើងឆេះព្រៃដោយចេតនា ។*

*៨- គ្រៀវ បំពុល កាប់បំផ្លាញ ផ្តួលរំលំដើមឈើ ឬ គាស់រំលើងប្រមូលគល់ឈើ ។*

*៩- បង្កើតមូលដ្ឋានកែច្នៃរល្លីរមៀត ឬ មូលដ្ឋានសិប្បកម្មអនុផលព្រៃឈើផ្សេងទៀត ដែលនាំមកនូវការបំផ្លាញព្រៃឈើ និង មជ្ឈដ្ឋានព្រៃឈើ ។*

*១០- បរបាញ់ សម្លាប់ ធ្វើពាណិជ្ជកម្ម ឬ នាំចេញប្រភេទសត្វក្នុងក្រុមជិតផុតពូជ ។*

*ជនណាប្រព្រឹត្តបទល្មើសព្រៃឈើថ្នាក់ទី១មិនរាងចាល ត្រូវផ្តន្ទាទោសទ្វេដងនៃបទល្មើសព្រៃឈើថ្នាក់ទី១នៃច្បាប់នេះ ។*

ខ្លឹមសារនៃមាត្រា ៩៧ នេះ គឺសំដៅដាក់ទោសទណ្ឌលើរូបវន្តបុគ្គល ឬ នីតិបុគ្គលដែលបានប្រព្រឹត្តបទល្មើសណាមួយដូចមានចែងក្នុងមាត្រានេះ។ ចំពោះសកម្មភាពដែលបានប្រព្រឹត្តឡើងដោយមន្ត្រីរដ្ឋបាលព្រៃឈើត្រូវផ្តន្ទាទោសតាមមាត្រា ១០១ ។

- ***ក្លែងញញួរត្រា ឬ ប្រើញញួរត្រាក្លែង ឬ បំផ្លាញស្នាមញញួរត្រារដ្ឋបាលព្រៃឈើ ដែលវាយលើឈើហ៊ុប :***
  - **ក្លែងញញួរត្រា :** ជាការបង្កើតញញួរត្រាដូច ឬ ស្រដៀងញញួរត្រារដ្ឋបាលព្រៃឈើដើម្បីវាយលើឈើហ៊ុប។
  - **ប្រើញញួរត្រាក្លែង :** ជាការប្រើប្រាស់ញញួរត្រាក្លែង ដើម្បីយកទៅវាយលើឈើហ៊ុប។

- **បំផ្លាញស្នាមញញួរត្រារដ្ឋបាលព្រៃឈើ :** ជាការចាំង កាត់ ឬ កំទេចចោលនូវស្នាមញញួរត្រាដែលមន្ត្រីរដ្ឋបាលព្រៃឈើបានវាយលើឈើហ៊ុបរួចហើយ ។

- ***ក្លែងបន្លំដោយស្លៀកពាក់ឯកសណ្ឋាន ពាក់សញ្ញាសម្គាល់ ឬ ពាក់ឋានន្តរសក្តិរបស់មន្ត្រីរដ្ឋបាលព្រៃឈើ :***

មន្ត្រីរដ្ឋបាលព្រៃឈើ ត្រូវគ្រងឯកសណ្ឋាន ពាក់ស្លាកសញ្ញាសំគាល់ និង ឋានន្តរសក្តិឱ្យបានត្រឹមត្រូវតាមតួនាទី និង ភារកិច្ចដូចមានចែងនៅក្នុងអនុក្រឹត្យស្តីពី *សំលៀកបំពាក់ឯកសណ្ឋាន សញ្ញាសំគាល់ និង ឋានន្តរសក្តិរបស់មន្ត្រីរដ្ឋបាលព្រៃឈើ* ។ ក្រៅពីមន្ត្រីរដ្ឋបាលព្រៃឈើ ពុំមានជនណាមានសិទ្ធិគ្រងឯកសណ្ឋាន សញ្ញាសំគាល់ និង ឋានន្តរសក្តិរបស់មន្ត្រីរដ្ឋបាលព្រៃឈើបានឡើយ ។ ជនណាដែលក្លែងបន្លំស្លៀកពាក់ឯកសណ្ឋាន ពាក់សញ្ញាសំគាល់ ឬ ពាក់ឋានន្តរសក្តិរបស់មន្ត្រីរដ្ឋបាលព្រៃឈើដើម្បីធ្វើសកម្មភាពណាមួយទាំងស្របច្បាប់ក្តី ទាំងខុសច្បាប់ក្តី ត្រូវផ្តន្ទាទោសតាមមាត្រានេះ ។

- ***ក្លែងបន្លំលិខិតសាធារណៈដែលពាក់ព័ន្ធនឹងវិស័យព្រៃឈើ ឬ សត្វព្រៃ :***

ជាការក្លែងបន្លំខ្លឹមសារ ហត្ថលេខា និង ត្រា លើលិខិតបទដ្ឋានបច្ចេកទេស ច្បាប់ ឬ លិខិតបទដ្ឋានក្រោមច្បាប់ផ្សេងៗក្នុងវិស័យព្រៃឈើ ដើម្បីប្រព្រឹត្តបទល្មើសព្រៃឈើ ឬ អន្តរាគមន៍ក្នុងការដោះលែងវត្ថុតាងបទល្មើសព្រៃឈើ ។

- ***បំផ្លាញ លាក់បាំង លក់ ឬ លួចវត្ថុតាងព្រៃឈើ :***
  - **ការបំផ្លាញវត្ថុតាងព្រៃឈើ :** ជាការបំផ្លាញវត្ថុតាងបទល្មើសព្រៃឈើ (ផល អនុផលព្រៃឈើ សំភារៈ និងមធ្យោបាយបំរើឱ្យការប្រព្រឹត្តបទល្មើសព្រៃឈើ) ដែលត្រូវបានមន្ត្រីរដ្ឋបាលព្រៃឈើធ្វើការចាប់ឃាត់ ប្រមូល និង ដកហូតយកមករក្សាទុកជាបណ្តោះអាសន្ន ដើម្បីរង់ចាំការសំរេចពីរដ្ឋបាលព្រៃឈើ ឬ ពីតុលាការជាសមត្ថកិច្ច ។
  - **ការលាក់បាំងវត្ថុតាងព្រៃឈើ :** សំដៅដល់ម្ចាស់ព្រៃសម្បទាន ឬម្ចាស់ព្រៃគុបដែលបានធ្វើអាជីវកម្មប្រមូលផល អនុផលព្រៃឈើ ឬ អ្នកប្រកបរបរអាជីវកម្មណាមួយដែលពាក់ព័ន្ធនឹងវិស័យព្រៃឈើ ហើយនៅពេលដែលមន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ចបានរកឃើញវត្ថុតាងបទល្មើសព្រៃឈើនៅទីកន្លែងកើតហេតុ ដែលអាចសន្និដ្ឋានបានថា វត្ថុតាងបទល្មើសព្រៃឈើទាំងនោះជាប់ពាក់ព័ន្ធនឹងម្ចាស់ព្រៃសម្បទាន ឬ ម្ចាស់ព្រៃគុប ម្ចាស់រោងចក្រអារឈើ ម្ចាស់សិប្បកម្មកែច្នៃផល អនុផលព្រៃឈើ ឬ ម្ចាស់រោងសន្និធិផល អនុផលព្រៃឈើ ហើយវត្ថុតាងបទល្មើសព្រៃឈើទាំងនោះត្រូវបានជនល្មើសប្រើគ្រប់មធ្យោបាយដើម្បីបិទបាំងបទល្មើសព្រៃឈើដែលខ្លួនបានប្រព្រឹត្ត ឬ បំភាន់ភ្នែកសមត្ថកិច្ចរដ្ឋបាលព្រៃឈើ ។ ឧទាហរណ៍ : ម្ចាស់ព្រៃសម្បទាន ឬ ម្ចាស់ព្រៃគុបបានគាស់ ឬ ដុតបំផ្លាញគល់ឈើ ឬ ប្រើប្រាស់មធ្យោបាយផ្សេងៗដើម្បីបំបាត់ដាន ឬកែប្រែសភាពដើមរបស់គល់ឈើនៅពេលដែលពួកគេបានធ្វើអាជីវកម្មឈើខុសពីបែបបទបច្ចេកទេសប្រមូលផល អនុផលព្រៃឈើ ។
  - **លក់វត្ថុតាងព្រៃឈើ :** ជាការលក់វត្ថុតាងបទល្មើសព្រៃឈើ (ផល អនុផលព្រៃឈើ សំភារៈ និង មធ្យោបាយបំរើឱ្យការប្រព្រឹត្តបទល្មើសព្រៃឈើ) ដែលត្រូវបានមន្ត្រីរដ្ឋបាលព្រៃឈើធ្វើការចាប់ឃាត់ ប្រមូល និង ដកហូតយកមករក្សាទុកជាបណ្តោះអាសន្ន ដើម្បីរង់ចាំការសំរេចពីរដ្ឋបាលព្រៃឈើ ឬ ពីតុលាការជាសមត្ថកិច្ច ។ ឧទាហរណ៍ : មន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ចបានធ្វើការចាប់ឃាត់រថយន្តដឹកឈើ ០១ គ្រឿង ដឹកឈើប្រភេទប្រណិត (នាងនួន) ចំនួន ២ម$^{៣}$ ៣៥០ ដោយគ្មានលិខិតអនុញ្ញាតពីរដ្ឋបាលព្រៃឈើ ហើយបានយករថយន្ត និងឈើទាំងនោះមករក្សាទុកជាបណ្តោះអាសន្ននៅប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ ដោយ

មានលោកនាយប៉ុស្តិនគរបាលរដ្ឋបាលឃុំជាអ្នកទទួលថែរក្សា ដើម្បីរង់ចាំការសំរេចពីរដ្ឋបាលព្រៃឈើ ។ ប៉ុន្តែឈើទាំងនេះត្រូវបានលោកនាយប៉ុស្តិយកទៅលក់ ។

- **លួចវត្ថុតាងព្រៃឈើ :** ជាការលួចវត្ថុតាងបទល្មើសព្រៃឈើ (ផល អនុផលព្រៃឈើ សំភារៈ និង មធ្យោបាយបំរើឱ្យការប្រព្រឹត្តបទល្មើសព្រៃឈើ) ដែលត្រូវបានមន្ត្រីរដ្ឋបាលព្រៃឈើធ្វើការចាប់ឃាត់ ប្រមូល និង ដកហូតយកមករក្សាទុកជាបណ្តោះអាសន្ន ដើម្បីរង់ចាំការសំរេចពីរដ្ឋបាលព្រៃឈើ ឬ ពីតុលាការជាសមត្ថកិច្ច ។

- ***កំទេច ផ្លាស់ប្តូរ លុបបំបាត់ ឬ ធ្វើឱ្យខូចខាត ដល់ព្រំសីមានៃតំបន់ព្រៃឈើ :***
  - **កំទេចព្រំសីមានៃតំបន់ព្រៃឈើ :** ជាការបំផ្លិចបំផ្លាញចោលនូវបង្គោល ឬ ស្លាកសញ្ញាសំគាល់ដែលរដ្ឋបាលព្រៃឈើបានបោះដើម្បីសំគាល់ព្រំប្រទល់ដីព្រៃឈើ ។
  - **ផ្លាស់ប្តូរព្រំសីមានៃតំបន់ព្រៃឈើ :** ជាការដកបង្ខិតបង្គោលព្រំប្រទល់ដីព្រៃ ឬ ផ្លាស់ប្តូរបង្គោលថ្មីខុសពីទ្រង់ទ្រាយដើម ក្នុងបំណងដើម្បីយកដីព្រៃ ។
  - **លុបបំបាត់ព្រំសីមានៃតំបន់ព្រៃឈើ :** ជាការធ្វើឱ្យបាត់បង្គោល ឬ ស្លាកសញ្ញាសំគាល់ព្រំប្រទល់ដីព្រៃឈើ តាមរយៈការចាក់ដីលុប ការដកយកចេញ ។ល ។
  - **ធ្វើឱ្យខូចខាតព្រំសីមានៃតំបន់ព្រៃឈើ :** ជាការធ្វើឱ្យបាក់ ប្រេះ ខូចបង្គោល ឬ ស្លាកសញ្ញាសំគាល់ព្រំប្រទល់ដីព្រៃឈើ ។

- ***កាប់រានព្រៃ ឈូសឆាយដីព្រៃ ហ៊ុំព័ទ្ធកាន់កាប់ដីព្រៃ :***

ដីព្រៃទាំងអស់គឺជាសម្បត្តិរដ្ឋ ។ ដើម្បីគ្រប់គ្រងអភិវឌ្ឍន៍ដីព្រៃទាំងនេះប្រកបដោយនិរន្តរភាព រដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ មិនអនុញ្ញាតឱ្យរូបវន្តបុគ្គល ឬ នីតិបុគ្គល ធ្វើការកាប់រាន ឈូសឆាយដីព្រៃ ហ៊ុំព័ទ្ធកាន់កាប់ដីព្រៃតាមគ្រប់រូបភាពក្នុងគោលបំណងកាន់កាប់ធ្វើជាកម្មសិទ្ធិ ផ្ទេរ លក់ ជួល ឬ ធ្វើអំណោយបានឡើយ ។

- ***បង្កឱ្យភ្លើងឆេះព្រៃដោយចេតនា :***

ជាការប្រព្រឹត្តដែលបានគ្រោងទុកជាមុន ដែលនាំឱ្យមានភ្លើងឆេះព្រៃ ដូចជាការដុតព្រៃដើម្បីចាប់យកសត្វ ការដុតព្រៃដើម្បីធ្វើកសិកម្មពនេចរ ការដុតព្រៃដើម្បីយកល្បះខ្ចីធ្វើចំណីសត្វ ការដុតព្រៃដើម្បីយកដី ការប្រើប្រាស់ភ្លើងដើម្បីយកឃ្មុំ និង ការប្រើប្រាស់ភ្លើងក្នុងគោលបំណងផ្សេងៗទៀត ។

គ្រៀវ បំពុល កាប់បំផ្លាញ ផ្តួល រំលំដើមឈើ ឬគាស់ រំលើងប្រមូលគល់ឈើ ។

- ***គ្រៀវ បំពុល កាប់បំផ្លាញ ផ្តួលរំលំដើមឈើ ឬ គាស់រំលើងប្រមូលគល់ឈើ :***
  - **គ្រៀវដើមឈើ :** ការចាំងក្រឡឹងសំបក បកសំបកឈើ ដើម្បីទុកឱ្យឈើងាប់ ។
  - **ការបំពុលដើមឈើ :** ការប្រើសារធាតុគីមី ដើម្បីធ្វើឱ្យដើមឈើងាប់ ។
  - **ការកាប់បំផ្លាញដើមឈើ :** ការកាប់រានដីព្រៃធ្វើកម្មសិទ្ធិ ការឈូសឆាយដីព្រៃដើម្បីបំលែងជាដីកសិកម្ម ឬ ដើម្បីគោលបំណងអភិវឌ្ឍន៍ផ្សេងទៀតដោយគ្មានការអនុញ្ញាត ។
  - **ផ្តួលរំលំដើមឈើ :** ការកាប់រំលំដើមឈើដោយគ្មានការអនុញ្ញាត ។
  - **គាស់រំលើងប្រមូលគល់ឈើ :** ការគាស់យកគល់ឈើដើម្បីយកមកកែច្នៃធ្វើជាគ្រឿងសង្ហារឹម ឬ ប្រើប្រាស់ផ្សេងៗ ទោះបីជាគល់ឈើនោះបានមកពីឈើដែលគេបានកាប់រួចក្តី ឬ ពីឈើងាប់ដោយធម្មជាតិក្តី ឬ ការ

កាប់ឈើដើម្បីយកគល់ក្តី។ សកម្មភាពនេះត្រូវហាមខាត់ដាច់ខាតព្រោះវាជាការគំរាមកំហែង និង បំផ្លាញទាំងស្រុងដល់ការលូតលាស់របស់ឈើ ដំណុះកូនឈើ និង ប្រព័ន្ធជីវសាស្ត្រចំរុះនៃធនធានព្រៃឈើ ។

- ***បង្កើតមូលដ្ឋានកែច្នៃវល្លិរមៀត ឬ មូលដ្ឋានសិប្បកម្មអនុផលព្រៃឈើផ្សេងទៀត ដែលនាំមកនូវការបំផ្លាញព្រៃឈើ និង មជ្ឈដ្ឋានព្រៃឈើ :***
  - **មូលដ្ឋានកែច្នៃវល្លិរមៀត :** ជាទីតាំងផលិត ឬ កែច្នៃវល្លិរមៀតដើម្បីចំរាញ់យកម្សៅមកប្រើប្រាស់។ ការផលិត ឬ កែច្នៃវល្លិរមៀតនេះ ត្រូវបានហាមឃាត់ ព្រោះកាកសំណល់នៃវល្លិរមៀត និង សារធាតុគីមីដែលប្រើប្រាស់ បានបំផ្លាញព្រៃឈើ និង ធនធានធម្មជាតិ។ ឧទាហរណ៍ : កាកសំណល់នៃវល្លិរមៀត និង សារធាតុគីមីដែលបង្ហូរចូលទៅក្នុងទឹក ធ្វើឱ្យមច្ឆាជាតិងាប់បាន។
  - **មូលដ្ឋានកែច្នៃផល អនុផលព្រៃឈើផ្សេងៗទៀត :** គឺជាទីតាំងផលិត ឬ កែច្នៃផល អនុផលព្រៃឈើដែលនាំដល់ការបំផ្លាញព្រៃឈើ និង មជ្ឈដ្ឋានព្រៃឈើ ដូចជាមូលដ្ឋានផលិត និង កែច្នៃប្រេងម្រះព្រៅ ខ្លឹមចន្ទក្រស្នា ផ្តៅ ឬស្សី ជ័រគ្រប់ប្រភេទ និង ប្រេងគ្រប់ប្រភេទ ។ មូលដ្ឋានផលិត និង កែច្នៃផល អនុផលព្រៃឈើទាំងអស់ត្រូវមានលិខិតអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ឬ ពីរដ្ឋបាលព្រៃឈើស្របតាមច្បាប់ស្តីពីព្រៃឈើ និង លិខិតបទដ្ឋានក្រោមច្បាប់ផ្សេងទៀត។ រាល់សកម្មភាពទាំងនេះត្រូវជៀសវាងការបំផ្លាញព្រៃឈើ ឬ មជ្ឈដ្ឋានព្រៃឈើ ដែលបណ្តាលមកពី :
    - ការកាប់ដើមឈើដើម្បីយកអនុផលព្រៃឈើ។
    - ការប្រើប្រាស់ជាតិគីមីផ្សេងៗក្នុងការផលិត កែច្នៃ មានដូចជា ទឹកអាស៊ីត អំបិល... ហើយការបង្ហូរកាកសំណល់ផ្សេងៗ ដែលមានជាតិពុលខ្លាំងធ្វើឱ្យប៉ះពាល់ដល់ប្រភពទឹក ដី ស្រែចំការ សុខភាព និង ជីវិតមនុស្ស សត្វ ។ល។

  តាមការសិក្សាស្រាវជ្រាវឃើញថា ប្រេងម្រះព្រៅភ្នំមានសារធាតុសាហ្វ្រូខ្ពស់រហូតដល់ ៩៥% ដែលអាចយកទៅផលិតជាសារធាតុគ្រឿងញៀន។ ដូចនេះការផលិត ការដឹកជញ្ជូន ការប្រើប្រាស់ និង ការនាំចេញប្រេងម្រះព្រៅភ្នំ ត្រូវបានហាមឃាត់។

- ***បរបាញ់ សម្លាប់ ធ្វើពាណិជ្ជកម្ម ឬ នាំចេញប្រភេទសត្វក្នុងក្រុមជិតផុតពូជ :***

ពពួកសត្វព្រៃគ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាសម្បត្តិរដ្ឋ និងជាសមាសភាគនៃធនធានព្រៃឈើ ។ ពពួកសត្វព្រៃទាំងអស់នេះស្ថិតនៅក្រោមការគ្រប់គ្រង ការសិក្សា ស្រាវជ្រាវ និង អភិរក្សដោយរដ្ឋបាលព្រៃឈើ ។ ចំពោះប្រភេទសត្វក្នុងក្រុមជិតផុតពូជត្រូវ ហាមឃាត់ដាច់ខាតចំពោះការបរបាញ់ ការសំលាប់ ការធ្វើពាណិជ្ជកម្ម ឬ ការនាំចេញ។

## មាត្រា ៩៨.-

*ត្រូវផ្តន្ទាទោសក្រោមបទល្មើសព្រៃឈើថ្នាក់ទី ២ ដែលត្រូវជាប់ពន្ធនាគារពីមួយ (១) ឆ្នាំ ទៅប្រាំ (៥) ឆ្នាំ និង ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីដប់លាន (១០.០០០.០០០) រៀល ទៅមួយរយលាន (១០០.០០០.០០០) រៀល ឬផ្តន្ទាទោសណាមួយនៃទោសទាំងពីរ វត្ថុតាងទាំងអស់ត្រូវរឹបអូសមកជាសម្បត្តិរដ្ឋ ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម :*

*១-មិនគោរពតាមបទបញ្ញាបច្ចេកទេស ដែលបានកំណត់ក្នុងក្រមបច្ចេកទេសអនុវត្តគ្រប់គ្រងព្រៃឈើកម្ពុជា ។*

២- មិនគោរពផែនការគ្រប់គ្រង និងផែនការប្រមូលផល អនុផលព្រៃឈើប្រចាំឆ្នាំ ។

៣- យកលិខិតអនុញ្ញាតប្រើប្រាស់ព្រៃឈើទៅប្រមូលផល អនុផលព្រៃឈើ ។

៤- ប្រើប្រាស់គ្រឿងចក្រ យានយន្តបម្រើឱ្យការប្រមូលផល អនុផលព្រៃឈើដោយគ្មានលិខិតអនុញ្ញាត ឬ គ្មានស្លាកសំគាល់ ។

៥- គាស់កកាយយកថ្ម ដី ខ្សាច់ រ៉ែ ដែលមាននៅក្នុងដីនៃដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ។

៦- ប្រើប្រាស់ដីព្រៃឈើលើសពីទំហំអនុញ្ញាត ឬគ្មានលិខិតអនុញ្ញាតដើម្បីស្ថាបនាផ្លូវសាធារណៈ ផ្លូវព្រៃឈើ ឬ ដាក់តាំងមូលដ្ឋានសំណង់ ឬលំនៅដ្ឋានគ្រប់ប្រភេទតាមដងផ្លូវ ។

៧- បង្កើតមូលដ្ឋានឧស្សាហកម្មឈើ រោងចក្រអារឈើ សិប្បកម្មកែច្នៃផល អនុផលព្រៃឈើប្រភេទធំ និង មធ្យមដោយគ្មានប្រកាស ។

៨- បង្កើតឡគ្រប់ប្រភេទ ដែលប្រើប្រាស់ផល អនុផលព្រៃឈើជាវត្ថុធាតុដើមដោយគ្មានលិខិតអនុញ្ញាត ។

៩- បរបាញ់ក្នុងរដូវកាលហាមឃាត់ ឬ ក្នុងតំបន់ការពារ ។

១០- បរបាញ់ សម្លាប់ ធ្វើពាណិជ្ជកម្ម ឬ នាំចេញប្រភេទសត្វក្នុងក្រុមមានដោយកម្រ ។

១១- បរបាញ់សត្វព្រៃដោយប្រើមធ្យោបាយដែលបង្កគ្រោះថ្នាក់ដល់ជីវសាស្ត្រសត្វ ។

១២- យកធ្វើជាកម្មសិទ្ធិ កែច្នៃសំណាក សន្និធិ ដឹកជញ្ជូន ឬ នាំចូលប្រភេទសត្វរស់ និង សំណាកក្នុងក្រុម ជិតផុតពូជ ។

ត្រូវផ្តន្ទាទោសក្រោមបទល្មើសព្រៃឈើថ្នាក់ទី ២ ដែលត្រូវជាប់ពន្ធនាគារពីមួយ (១) ឆ្នាំ ទៅប្រាំ (៥) ឆ្នាំ និង ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពីដប់លាន (១០.០០០.០០០) រៀល ទៅមួយរយលាន (១០០.០០០.០០០) រៀល វត្ថុតាងទាំងអស់ត្រូវរឹបអូសមកជាសម្បត្តិរដ្ឋ ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម :

១- ប្រមូលផល អនុផលព្រៃឈើដោយគ្មានលិខិតអនុញ្ញាត ។

២- ប្រមូលផល អនុផលព្រៃឈើក្រៅដែនព្រៃគុបកំណត់ក្នុងលិខិតអនុញ្ញាត ឬ ក្រៅភូមិសាស្ត្រដែលកំណត់ក្នុង ផែនការប្រមូលផល អនុផលព្រៃឈើប្រចាំឆ្នាំ ។

៣- ផ្ទេរសិទ្ធិ ឬលក់អាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត ។

៤- កាប់ដើមឈើក្នុងចំការដាំឈើរបស់រដ្ឋ ។

៥- ប្រមូលផល អនុផលព្រៃឈើ ចំពោះប្រភេទឈើជាប់លំដាប់ថ្នាក់ដែលមិនទាន់ដល់ទំហំអប្បបរមាអនុញ្ញាត ឱ្យកាប់រំលំ ប្រភេទឈើដែលមានដោយកម្រ ប្រភេទឈើដែលប្រជាជនចោះយកជ័រតាមប្រពៃណី និង ប្រភេទ ឈើផ្តល់ជ័រមានតម្លៃ ។

៦- នាំចូលគ្រាប់ពូជរុក្ខជាតិព្រៃគ្រប់ប្រភេទ ដោយគ្មានទិដ្ឋាការពីអាជ្ញាធរវិទ្យាសាស្ត្ររបស់ប្រទេសនាំចេញ និង គ្មានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

៧- នាំចេញផល អនុផលព្រៃឈើដែលគ្មានអាជ្ញាប័ណ្ណ ។

ជនណាដែលប្រព្រឹត្តបទល្មើសថ្នាក់ទី២មិនរាងចាលត្រូវផ្តន្ទាទោសក្រោមបទល្មើសព្រៃឈើថ្នាក់ទី១នៃច្បាប់នេះ ។

- ***មិនគោរពតាមបទបញ្ជាបច្ចេកទេសដែលបានកំណត់ក្នុងក្រមបច្ចេកទេសអនុវត្តគ្រប់គ្រងព្រៃឈើកម្ពុជា :***

មិនគោរពតាមគោលការណ៍ណែនាំបទបញ្ជាបច្ចេកទេសចាំបាច់ផ្សេងៗដែលមានចែងដូចជា:

- គោលការណ៍ណែនាំសំរាប់ប្រព័ន្ធនៃការធ្វើផែនការគ្រប់គ្រងព្រៃសម្បទាន
- គោលការណ៍ណែនាំសំរាប់ធ្វើសារពើភ័ណ្ឌនៅក្នុងវដ្តរៀបចំគ្រប់គ្រងព្រៃឈើ
- គោលការណ៍ណែនាំសំរាប់ការស្ថាបនាការងារវិស្វកម្មព្រៃឈើ
- គោលការណ៍ណែនាំសំរាប់ការគ្រប់គ្រងការទប់ស្កាត់ការលួចឈើ
- ក្រមបច្ចេកទេសអនុវត្តសំរាប់ប្រមូលផលនៅកម្ពុជា
- គោលការណ៍ណែនាំសំរាប់គ្រប់គ្រងតំបន់ពិសេស
- គោលការណ៍ណែនាំការអភិរក្សជីវៈចំរុះសំរាប់គ្រប់គ្រងព្រៃឈើ
- គោលការណ៍ណែនាំសំរាប់ការអង្កេតសិក្សាសង្គម សេដ្ឋកិច្ចនៃសហគមន៍នៅជុំវិញ តំបន់ព្រៃសម្បទាន
- គោលការណ៍ណែនាំអំពីការប៉ាន់ស្មានផលប៉ះពាល់សង្គម បរិស្ថានព្រៃសម្បទាន
- គោលការណ៍ណែនាំសំរាប់ធ្វើការវាយតំលៃផលប៉ះពាល់សង្គម បរិស្ថានសំរាប់ព្រៃសម្បទាន
- ការជ្រើសរើសប្រព័ន្ធវុក្ខវប្បកម្មព្រៃឈើ សុរុំឡកម្មព្រៃឈើ ការថែរក្សា និងបន្តពូជព្រៃឈើ
- ការរៀបចំគ្រប់គ្រងជំរកសត្វព្រៃ ការការពារផ្លូវទឹក និង តាមដានត្រួតពិនិត្យព្រៃឈើ...។

- ***មិនគោរពតាមផែនការគ្រប់គ្រង និង ផែនការប្រមូលផលប្រចាំឆ្នាំ :***

មិនគោរពតាមបទបញ្ញត្តិ ដែលមានចែងក្នុងការងារនីមួយៗដូចជា : ការងារសារពើភ័ណ្ឌ ការកំណត់ទិន្នផល ការប្រមូលព្រៃឈើ វុក្ខវប្បកម្ម ការអភិរក្សជីវៈចំរុះ និង ទីជំរាល ការការពារផលប្រយោជន៍សហគមន៍ ការតាមដានត្រួតពិនិត្យ និង ប្រតិបត្តិការព្រៃឈើផ្សេងទៀតដែលបានបញ្ជាក់ច្បាស់លាស់ក្នុងផែនការប្រចាំឆ្នាំ។

- ***យកលិខិតអនុញ្ញាតប្រើប្រាស់ព្រៃឈើទៅប្រមូលផល អនុផលព្រៃឈើ :***

លិខិតអនុញ្ញាតប្រើប្រាស់ព្រៃឈើ គឺអាចផ្តល់ជូនដល់បុគ្គលដែលមានបំណងធ្វើសកម្មភាពលើព្រៃឈើរបស់រដ្ឋក្នុងគោលបំណងសំខាន់សំរាប់ការសិក្សាស្រាវជ្រាវ លំហែកំសាន្ត។ល។ ក្នុងន័យនេះ ទោះជាការប្រើប្រាស់ព្រៃឈើក្នុងរូបភាពណាក៏ដោយក៏ត្រូវគ្រប់គ្រងដោយច្បាប់ដែរ ដើម្បីធានាការការពារព្រៃឈើរបស់រដ្ឋឱ្យបានគង់វង្ស ។ លិខិតអនុញ្ញាតប្រភេទនេះ មិនអាចយកទៅប្រើប្រាស់ដើម្បីប្រមូលផល អនុផលព្រៃឈើបានឡើយ លើកលែងតែក្នុងគោលបំណងដែលមានចែងនៅក្នុងមាត្រា ២៧ នៃច្បាប់ស្តីពីព្រៃឈើនេះ។

- ***ប្រើប្រាស់គ្រឿងចក្រ យានយន្ត បម្រើឱ្យការប្រមូលផល អនុផលព្រៃឈើដោយគ្មានលិខិតអនុញ្ញាត ឬ គ្មានស្លាកសំគាល់:***

រាល់គ្រឿងចក្រ រណារយន្ត យានយន្តគ្រប់ប្រភេទសំរាប់បំរើឱ្យការប្រមូលផល អនុផលព្រៃឈើ ត្រូវមានការអនុញ្ញាតពីរដ្ឋបាលព្រៃឈើ ដោយមានបិទស្លាកសញ្ញាសំគាល់ និង ចុះបញ្ជីកាត្រឹមត្រូវ ងាយស្រួលដល់សមត្ថកិច្ចរដ្ឋបាលព្រៃឈើក្នុងការគ្រប់គ្រង ក៏ដូចជាការត្រួតពិនិត្យ ចៀសវាងមានជនខិលខូចឆ្លៀតឱកាសប្រើប្រាស់មធ្យោបាយគ្រឿងចក្រ រណារយន្ត ឬ យានយន្តទាំងនេះ ដើម្បីប្រព្រឹត្តបទល្មើសព្រៃឈើ។

- ***គាស់កកាយយកថ្ម ដី ខ្សាច់ រ៉ែ ដែលមាននៅក្នុងដីនៃដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ :***

ការគាស់កកាយយក ថ្ម ដីខ្សាច់ រ៉ែ ដែលមាននៅក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ បណ្តាលឱ្យមានហេតុប៉ះពាល់ទៅលើធនធានធម្មជាតិដូចជា បាត់បង់ ឬ រំខានដល់ជម្រកសត្វព្រៃ បង្កឱ្យមានការហូរច្រោះដី ខូតខាតស្រទាប់ដី និងមីក្រូសរីរាង្គ ឬ ជីវចម្រុះ ខូតខាតប្រភពទឹក និង ប្រព័ន្ធអេកូឡូស៊ី ។ ដូចនេះត្រូវមានការសិក្សាវាយតំលៃជាមុនពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង ទទួលការអនុញ្ញាតពីរាជរដ្ឋាភិបាល។

- ***ប្រើប្រាស់ដីព្រៃឈើលើសពីទំហំអនុញ្ញាត ឬ គ្មានលិខិតអនុញ្ញាតដើម្បីស្ថាបនាផ្លូវសាធារណៈ ផ្លូវព្រៃឈើ ឬ ដាក់តាំងមូលដ្ឋានសំណង់ ឬ លំនៅដ្ឋានគ្រប់ប្រភេទតាមដងផ្លូវ :***
  - ការប្រើប្រាស់ដីព្រៃដើម្បីស្ថាបនាផ្លូវសាធារណៈ ត្រូវមានការសម្រេចពីរាជរដ្ឋាភិបាលតាមសំណើរបស់ក្រសួងសាធារណការ និង ដឹកជញ្ជូន ដោយមានការពិគ្រោះយោបល់ជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។
  - ការប្រើប្រាស់ដីព្រៃដើម្បីស្ថាបនាផ្លូវព្រៃ ត្រូវមានការសម្រេចពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រោយពីបានត្រួតពិនិត្យ និង វាយតំលៃដោយរដ្ឋបាលព្រៃឈើ ។
  - ការដាក់តាំងមូលដ្ឋានសំណង់ ឬ លំនៅដ្ឋានគ្រប់ប្រភេទតាមផ្លូវទាំងពីរប្រភេទខាងលើ ដែលកាត់តាមដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ត្រូវមានការសម្រេចពីរាជរដ្ឋាភិបាលបន្ទាប់ពីមានការពិគ្រោះយោបល់ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដោយមានការសិក្សាវាយតំលៃពីរដ្ឋបាលព្រៃឈើ ។
- ***បង្កើតមូលដ្ឋានឧស្សាហកម្មឈើ រោងចក្រអារឈើ សិប្បកម្មកែច្នៃផល អនុផលព្រៃឈើប្រភេទធំ និង មធ្យម ដោយគ្មានប្រកាស :***

មូលដ្ឋានឧស្សាហកម្មឈើ រោងអារឈើ សិប្បកម្មកែច្នៃផល អនុផលព្រៃឈើប្រភេទធំ និង មធ្យម ត្រូវមានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ (ប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ) ដូចមានចែងក្នុងមាត្រា ២៦ នៃច្បាប់ស្តីពីព្រៃឈើ ។

- ***បង្កើតឡគ្រប់ប្រភេទដែលប្រើប្រាស់ផល អនុផលព្រៃឈើជាវត្ថុធាតុដើមដោយគ្មានលិខិតអនុញ្ញាត :***

ឡគ្រប់ប្រភេទដែលប្រើប្រាស់ផល អនុផលព្រៃឈើជាវត្ថុធាតុដើមដូចជា ឡធ្យូង ឡខ្លឹមច័ន្ទន៍ ឡទេពីរូ ។ល។ ត្រូវមានការអនុញ្ញាតពីរដ្ឋបាលព្រៃឈើ ។ ដោយឡែកចំពោះឡគ្រប់ប្រភេទដែលប្រើប្រាស់ផល អនុផលព្រៃឈើជាប្រភពថាមពលមានជាអាទិ៍ ឡពាង ឡចាន ឡឥដ្ឋ ឡកំបោរ ឡថ្នាំជក់ ។ល។ ពុំតម្រូវឱ្យសុំលិខិតអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ឬ រដ្ឋបាលព្រៃឈើឡើយ ក៏ប៉ុន្តែមន្ត្រីរដ្ឋបាលព្រៃឈើមានសិទ្ធិធ្វើការត្រួតពិនិត្យឡទាំងនោះ ។

- ***បរបាញ់ក្នុងរដូវកាលហាមឃាត់ការប្រមាញ់ ឬ ក្នុងតំបន់ការពារ :***

ការបរបាញ់ក្នុងរដូវការហាមឃាត់ការប្រមាញ់ ឬ ក្នុងតំបន់ការពារ ត្រូវហាមឃាត់។ រដូវការហាមឃាត់ការប្រមាញ់ ជារយៈពេលបន្តពូជ ឬ ដំណាក់កាលដែលសត្វកំពុងចិញ្ចឹមកូន។ រដូវនេះខុសផ្លែកពីគ្នា ទៅតាមទីតាំងភូមិសាស្ត្រ និង លក្ខណៈជីវសាស្ត្ររបស់ប្រភេទសត្វនីមួយៗ។ តំបន់ការពារមានដូចជា តំបន់អភិរក្សសត្វព្រៃ តំបន់អភិរក្សប្រភពសេនេទិច តំបន់បេតិកភ័ណ្ឌជាតិ ព្រៃជំនឿសាសនា វត្តអារាម សាលារៀន សួនច្បារសាធារណៈ មណ្ឌលសំរាកកំសាន្ត ។ល។

- ***បរបាញ់ សម្លាប់ ធ្វើពាណិជ្ជកម្ម ឬ នាំចេញប្រភេទសត្វក្នុងក្រុមមានដោយកម្រ :***

ក្រុមប្រភេទសត្វមានដោយកម្រ ជាប្រភេទសត្វទាំងឡាយនៅក្នុងធម្មជាតិដែលចំពោះមុខដង់ស៊ីតេនៃសារព័ន្ធរបស់វាមានកំរិតទាប កម្រជួបប្រទះ អាចជួបប្រទះតែនៅក្នុងលំនៅដ្ឋានណាមួយជាក់លាក់ និង អាចប្រឈមមុខចំពោះការគំរាមកំហែង ឈានទៅរកការផុតពូជនៅក្នុងធម្មជាតិ ។ ដូចនេះ ការបរបាញ់ សម្លាប់ ធ្វើពាណិជ្ជកម្ម ឬ នាំចេញ ត្រូវបានហាមឃាត់ ។

- ***បរបាញ់សត្វព្រៃដោយប្រើមធ្យោបាយបង្កគ្រោះថ្នាក់ដល់ជីវសាស្ត្រសត្វ :***

មធ្យោបាយបង្កអោយមានគ្រោះថ្នាក់គ្រប់ប្រភេទ មានជាអាទិ៍ :

- ការប្រើប្រាស់ថ្នាំពុល ជាតិគីមី ឬ អាវុធជីវសាស្ត្រ ។
- ការប្រើប្រាស់កាំភ្លើងគ្រប់ប្រភេទ កាំភ្លើងកែច្នៃ មិនកែច្នៃ ឬ គ្រឿងផ្ទុះផ្សេងៗ ។
- ការប្រើប្រាស់ពន្លឺសិប្បនិម្មិត ចរន្តអគ្គិសនី ឬ ឧបករណ៍បន្លឺសំលេង ដើម្បីទាក់ចាប់សត្វព្រៃ ។
- ការប្រើយានយន្តបន្លឺសំលេងខ្លាំងក្នុងតំបន់ព្រៃការពារ ឬ តំបន់អភិរក្សសត្វព្រៃ ។
- ការបរបាញ់ ការប្រមូលពងកូនសត្វព្រៃគ្រប់ប្រភេទក្នុងរដូវកាលបន្តពូជ ។
- ការប្រើអន្ទាក់ ជីកអន្លង់ ឬ សំណាញ់ ដែលមានទ្រង់ទ្រាយ និង លក្ខណៈអាចសម្លាប់ជីវិតសត្វព្រៃគ្រប់ប្រភេទ ។

♦ ***ការយកធ្វើជាកម្មសិទ្ធិ កែច្នៃសំណាក សន្និធិ ដឹកជញ្ជូន ឬ នាំចូលប្រភេទសត្វរស់ និង សំណាកក្នុងក្រុមជិតផុតពូជ :***

ការចាប់សត្វក្នុងក្រុមប្រភេទជិតផុតពូជ និង ក្រុមប្រភេទមានដោយកម្រ មកធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន ឬ រក្សាប្រមូលផ្តុំសត្វរស់ សំណាក បំណែកសាច់ ឬ ថែរក្សាក្នុងសួនសត្វ ឬ សួនគ្រួសារត្រូវហាមឃាត់។ ប៉ុន្តែ ដោយមានការឯកភាពពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង រដ្ឋបាលព្រៃឈើមានសិទ្ធិចេញលិខិតអនុញ្ញាតចំពោះប្រភេទសត្វក្នុងក្រុមជិតផុតពូជ និង ក្រុមមានដោយកម្រ សំរាប់គោលបំណងដូចខាងក្រោមៈ

- ការសិក្សាអប់រំ ឬការស្រាវជ្រាវវិទ្យាសាស្ត្រ ។
- ការគាំទ្រដល់កម្មវិធីនៃការចាប់បង្កាត់ពូជ ។
- ការផ្លាស់ប្តូរប្រភេទសត្វអនុលោមតាមកិច្ចព្រមព្រៀងសហប្រតិបត្តិការអន្តរជាតិ ។

♦ ***ប្រមូលផល អនុផលព្រៃឈើដោយគ្មានលិខិតអនុញ្ញាត :***

ការប្រមូលផល អនុផលព្រៃឈើដោយគ្មានលិខិតអនុញ្ញាតត្រូវបានហាមឃាត់ ទោះបីរូបវន្តបុគ្គល ឬ នីតិបុគ្គលបានទទួល ឬ មិនទាន់បានទទួលសិទ្ធិគ្រប់គ្រង និង ប្រើប្រាស់ព្រៃសម្បទាន ឬ ព្រៃផ្តល់ផលក្រៅពីព្រៃសម្បទាន ឬ ព្រៃសហគមន៍។

♦ ***ប្រមូលផល អនុផលព្រៃឈើក្រៅដែនព្រៃគុបកំណត់ក្នុងលិខិតអនុញ្ញាត ឬ ក្រៅភូមិសាស្ត្រដែលកំណត់ក្នុងផែនការប្រមូលផល អនុផលព្រៃឈើប្រចាំឆ្នាំ :***

រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលបានទទួលសិទ្ធិ និង លិខិតអនុញ្ញាតឱ្យធ្វើការប្រមូលផល អនុផលព្រៃឈើក្នុងព្រៃគុបផ្តល់ផលក្រៅព្រៃសម្បទាន ឬ ក្នុងព្រៃសម្បទាន ត្រូវធ្វើការប្រមូលផល អនុផលព្រៃឈើក្នុងទីតាំងដែលបានកំណត់ក្នុងផែនការប្រមូលផល អនុផលព្រៃឈើប្រចាំឆ្នាំ។

♦ ***ផ្ទេរសិទ្ធិ ឬ លក់អាជ្ញាប័ណ្ណ ឬ លិខិតអនុញ្ញាតគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត :***

រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលមានអាជ្ញាប័ណ្ណ ឬ លិខិតអនុញ្ញាតគ្រប់ប្រភេទ មិនអាចផ្ទេរ ឬ លក់ទៅឱ្យរូបវន្តបុគ្គល ឬ នីតិបុគ្គលផ្សេងទៀតដោយគ្មានការអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ចបានឡើយ ។

♦ ***កាប់ដើមឈើក្នុងចំការដាំ ឈើរបស់រដ្ឋ :***

ចំការឈើដាំរបស់រដ្ឋស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលព្រៃឈើ។ ជនគ្រប់រូបគ្មានសិទ្ធិកាប់ដើមឈើក្នុងចំការឈើរបស់រដ្ឋឡើយ។ ក្នុងករណីមានការសិក្សាវាយតំលៃដោយរដ្ឋបាលព្រៃឈើ ការកាប់ដើមឈើក្នុងចំការរដ្ឋអាចប្រព្រឹត្តទៅបានសំរាប់គោលបំណងស្រាវជ្រាវវិទ្យាសាស្ត្រ កិច្ចការរុក្ខវប្បកម្ម ឬ ការធ្វើអាជីវកម្មព្រៃដាំដោយរដ្ឋបាលព្រៃឈើ។

- ***ប្រមូលផល អនុផលព្រៃឈើចំពោះប្រភេទឈើជាប់លំដាប់ថ្នាក់ដែលមិនទាន់ដល់ទំហំអប្បបរមាអនុញ្ញាតឱ្យកាប់រំលំ ប្រភេទឈើដែលមានដោយកម្រ ប្រភេទឈើដែលប្រជាជនចោះយកជ័រតាមប្រពៃណី និង ប្រភេទឈើផ្តល់ជ័រមានតម្លៃ :***

ក្នុងការប្រមូលផល អនុផលព្រៃឈើត្រូវអនុវត្តតាមគោលការណ៍បច្ចេកទេស គឺមិនអនុញ្ញាតឱ្យធ្វើការកាប់រំលំនូវបណ្តាប្រភេទឈើ ដែលមានអង្កត់ផ្ចិតមិនទាន់ដល់ទំហំអប្បបរមា ប្រភេទឈើមានដោយកម្រ ប្រភេទឈើដែលប្រជាជន ច្បោះយកជ័រ ប្រភេទឈើផ្តល់ជ័រមានតម្លៃ ដូចមានកំណត់ក្នុងប្រកាស ស្តីពីផល អនុផលព្រៃឈើដែលត្រូវហាមឃាត់ការប្រមូលផល និង ផែនការប្រមូលផល អនុផលព្រៃឈើ ។

**មាត្រា ៩៩.-**

*ត្រូវផ្តន្ទាទោសក្រោមបទល្មើសព្រៃឈើថ្នាក់ទី ៣ ដែលត្រូវជាប់ពន្ធនាគារពីមួយ (១)ខែ ទៅមួយ (១)ឆ្នាំ ឬ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលាន (១.០០០.០០០)រៀល ទៅដប់លាន (១០.០០០.០០០)រៀល វត្ថុតាងទាំងអស់អាចត្រូវរឹបអូសមកជាសម្បត្តិរដ្ឋចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម :*

*១- ប្រើប្រាស់រណារយន្តគ្រប់ប្រភេទដែលបំរើការប្រមូលផល អនុផលព្រៃឈើដោយគ្មានការអនុញ្ញាតពីប្រធានរដ្ឋបាលព្រៃឈើ ។*

*២- នាំចូលគ្រឿងចក្រ យានយន្ត និង រណារយន្តគ្រប់ប្រភេទសម្រាប់ការប្រមូលផល អនុផលព្រៃឈើដោយគ្មានការវាយតម្លៃភាពសមស្របពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។*

*៣- នាំចេញផល អនុផលព្រៃឈើដែលគ្មានសំណាបិទភ្ជិតរបស់រដ្ឋបាលព្រៃឈើលើខ្លួនផែនហឹ ។*

*៤- យាយី ធ្វើឱ្យរបួស ប្រមូលពង កូននៃប្រភេទសត្វក្នុងក្រុមជិតផុតពូជ ឬ ក្រុមមានដោយកម្រ ឬ បំផ្លាញជម្រករបស់វា ។*

*៥- បង្កើតរោងសន្និធិ លក់ដុំ រាយ នូវផល អនុផលព្រៃឈើ និង សិប្បកម្មកែច្នៃផល អនុផលព្រៃឈើប្រភេទតូចដោយគ្មានលិខិតអនុញ្ញាត ឬ ផ្ទុយពីការកំណត់ ។*

*៦- បង្កើតមូលដ្ឋានឧស្សាហកម្មឈើ រោងចក្រអារឈើ សិប្បកម្មកែច្នៃផល អនុផលព្រៃឈើ ឬ ឡគ្រប់ប្រភេទដែលប្រើប្រាស់ ឬ មិនប្រើប្រាស់ផល អនុផលព្រៃឈើ ជាវត្ថុធាតុដើម ឬ ជាប្រភពថាមពល ខុសពីទីតាំងកំណត់ដោយរដ្ឋបាលព្រៃឈើ ។*

*ជនណាប្រព្រឹត្តបទល្មើសព្រៃឈើថ្នាក់ទី ៣ មិនរាងចាលត្រូវផ្តន្ទាទោសក្រោមបទល្មើសព្រៃឈើថ្នាក់ទី ២ នៃច្បាប់នេះ ។*

- ***ប្រើប្រាស់រណារយន្តគ្រប់ប្រភេទដែលបំរើការប្រមូលផល អនុផលព្រៃឈើដោយគ្មានការអនុញ្ញាតពីប្រធានរដ្ឋបាលព្រៃឈើ :***

ម្ចាស់ព្រៃសម្បទាន ម្ចាស់ព្រៃគុប ឬ សហគមន៍ព្រៃឈើដែលមានលិខិតអនុញ្ញាតឱ្យប្រមូលផល អនុផលព្រៃឈើត្រូវស្នើសុំរដ្ឋបាលព្រៃឈើដើម្បីប្រើប្រាស់រណារយន្តដើម្បីប្រមូលផល អនុផលព្រៃឈើ។ រណារយន្តដែលបានអនុញ្ញាតឱ្យប្រើប្រាស់នេះត្រូវមានបិទស្លាកសញ្ញាសំគាល់ និង ចុះបញ្ជិកា ដោយរដ្ឋបាលព្រៃឈើទើបអាចយកទៅប្រើប្រាស់បាន។

- ***នាំចូលគ្រឿងចក្រ យានយន្ត និង រណារយន្តគ្រប់ប្រភេទ :***

ម្ចាស់ព្រៃសម្បទាន ម្ចាស់ព្រៃគុប ឬ សហគមន៍ព្រៃឈើ ដែលមានគំរោងនាំចូលគ្រឿងចក្រ យានយន្ត និង រណារយន្តគ្រប់ប្រភេទសម្រាប់បំរើឱ្យការប្រមូលផល អនុផលព្រៃឈើ ត្រូវមានការវាយតម្លៃជាមុនពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ តាមរយៈរដ្ឋបាលព្រៃឈើ អំពីបរិមាណ គុណភាព និង សមត្ថភាពនៃគ្រឿងចក្រ ឱ្យសមស្រប ទៅតាមស្ថានភាពភូមិសាស្ត្រ លក្ខណៈបច្ចេកទេស និង តម្រូវការជាក់ស្តែង។ ឧទាហរណ៍ : លក្ខខណ្ឌបរិស្ថាន និង បច្ចេកទេសនៃគ្រឿងចក្រមានដូចជា គ្រឿងចក្រធ្ងន់ពេកបណ្តាលឱ្យដីហាប់ខ្លាំង ខូចផ្លូវ ធ្វើឱ្យមានការហូរច្រោះ ធ្វើឱ្យប៉ះពាល់ខ្លាំងដល់ព្រៃឈើ គ្រឿងចក្រចាស់ពេកបណ្តាលឱ្យមានការបំពុលបរិយាកាស បន្សល់កាកសំណល់ច្រើន មានការប៉ះពាល់ខ្លាំងដល់ធនធានធម្មជាតិ និង បន្សល់សាច់ឈើច្រើន។

- ***នាំចេញផល អនុផលព្រៃឈើដែលគ្មានសំណាបិទភ្ជិតរបស់រដ្ឋបាលព្រៃឈើលើខ្ទនថែនឈើ :***

ការនាំចេញផល អនុផលព្រៃឈើដោយគ្មានសំណាបិទភ្ជិតសំគាល់ដោយរដ្ឋបាលព្រៃឈើលើខ្ទនថែនឈើ គឺជាអំពើល្មើសច្បាប់ ព្រោះរាល់ផល អនុផលព្រៃឈើទាំងនោះពុំទាន់បានត្រួតពិនិត្យពីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច នូវយថាប្រភេទ បរិមាណជាក់លាក់នៅឡើយ។

- ***យាយី ធ្វើឱ្យរបួស ប្រមូលពង កូននៃប្រភេទសត្វក្នុងក្រុមជិតផុតពូជឬក្រុមមានដោយកម្រ ឬបំផ្លាញជម្រករបស់វា :***

ការយាយី ធ្វើឱ្យរបួស ប្រមូលពង កូននៃប្រភេទសត្វក្នុងក្រុមជិតផុតពូជ ឬ ក្រុមមានដោយកម្រ ឬ បំផ្លាញជម្រករបស់វាមានដូចជា : បរបាញ់ ប្រមូលពង កូននៅរដូវបន្តពូជ បំផ្លាញទីជម្រក ប្រភពចំណី ប្រើប្រាស់មធ្យោបាយបង្កគ្រោះថ្នាក់ ឬ របួសដល់សត្វព្រៃ អន្ទាក់ អន្លង់ សំណាញ់ ពន្លឺសិប្បនិម្មិត ចរន្តអគ្គីសនី ឧបករណ៍បន្លឺសំលេង សំរាប់ចាប់ដែលមានលក្ខណៈអាចសម្លាប់ជីវិតហ្វូងសត្វព្រៃ ហើយសកម្មភាពទាំងនោះអាចបង្កឱ្យសត្វព្រៃ (ក្រុមមានដោយកម្រ និង ក្រុមជិតផុតពូជ) បាត់បង់នូវលទ្ធភាពបន្តពូជ ឬ បង្កកំណើត រត់ភៀសខ្លួនទៅប្រទេសដទៃទៀត ឬ ពីទីកន្លែងជម្រកធម្មជាតិរបស់វា។

- ***បង្កើតរោងសន្និធិ លក់ដុំ រាយ នូវផល អនុផលព្រៃឈើ និង សិប្បកម្មកែច្នៃផល អនុផលព្រៃឈើប្រភេទតូច ដោយគ្មានលិខិតអនុញ្ញាត ឬ ផ្ទុយពីការកំណត់ :***

ការបង្កើតរោងសន្និធិ ដេប៉ូលក់ដុំ រាយ នូវផល អនុផលព្រៃឈើ និង រោងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើប្រភេទតូច ត្រូវមានលិខិតអនុញ្ញាតពីខ័ណ្ឌរដ្ឋបាលព្រៃឈើ។ នៅក្នុងលិខិតអនុញ្ញាតឱ្យបង្កើតរោងសន្និធិ ដេប៉ូលក់-ទិញ ឬ រោងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើប្រភេទតូចនេះ បានកំណត់អំពីទីតាំង បរិមាណផល អនុផលព្រៃឈើយកមកកែច្នៃ គ្រឿងចក្រ ការណែនាំបច្ចេកទេស និង រយៈពេលអនុញ្ញាត។ល។ ដូចនេះ ម្ចាស់រោងសិប្បកម្ម រោងសន្និធិ និង ដេប៉ូទាំងអស់ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមការណែក្នុងលិខិតអនុញ្ញាត។

- ***បង្កើតមូលដ្ឋានឧស្សាហកម្មឈើ រោងចក្រអារឈើ សិប្បកម្មកែច្នៃផល អនុផលព្រៃឈើ ឬ ឡគ្រប់ប្រភេទ ដែលប្រើប្រាស់ ឬ មិនប្រើប្រាស់ផល អនុផលព្រៃឈើជាវត្ថុធាតុដើម ឬ ជាប្រភពថាមពល ខុសពីទីតាំងកំណត់ដោយរដ្ឋបាលព្រៃឈើ :***

រាល់លិខិតអនុញ្ញាតឱ្យបង្កើតមូលដ្ឋានឧស្សាហកម្មឈើ រោងចក្រអារឈើ សិប្បកម្មកែច្នៃផល អនុផលព្រៃឈើ ឬ ឡគ្រប់ប្រភេទដែលប្រើប្រាស់ ឬមិនប្រើប្រាស់ផល អនុផលព្រៃឈើជាវត្ថុធាតុដើម ឬជាប្រភពថាមពល ដែលអនុញ្ញាតឱ្យដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ឬខ័ណ្ឌរដ្ឋបាលព្រៃឈើ (សមត្ថកិច្ចនៃការចេញលិខិតអនុញ្ញាតអនុញ្ញាតមានចែងក្នុងមាត្រា ២៦ នៃច្បាប់ស្តីពីព្រៃឈើ ហើយការចេញលិខិតអនុញ្ញាតនេះផ្អែកលើរបាយការណ៍របស់មន្ត្រីរដ្ឋបាលព្រៃឈើដែលបានចុះសិក្សា វាយតំលៃ និង កំណត់ទីតាំងជាក់ស្តែងរួច) បានកំណត់អំពីទីតាំងដែលអនុញ្ញាតឱ្យបង្កើត។

**មាត្រា ១០០.-**

*សកម្មភាពទាំងឡាយណាដែលធ្វើឡើងដោយមន្ត្រីអាជ្ញាធរដែនដី មន្ត្រីនគរបាល មន្ត្រីនៃកងយោធពលខេមរភូមិន្ទ ឬមន្ត្រីអាជ្ញាធរផ្សេងទៀតដើម្បីធ្វើអន្តរាគមន៍ផ្តល់ការអនុញ្ញាតដោយផ្ទាល់ ឬ ដោយប្រយោលជួយដល់អាជីវកម្មព្រៃឈើ និង ធ្វើសកម្មភាពគ្រប់យ៉ាងផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ឬ ធ្វើការគំរាមកំហែងដល់មន្ត្រីរដ្ឋបាលព្រៃឈើ ឬ រាំងស្ទះដល់ការបំពេញភារកិច្ច និង កិច្ចប្រតិបត្តិការរបស់មន្ត្រីរដ្ឋបាលព្រៃឈើត្រូវចាត់ទុកជាបទល្មើសដែលត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពីមួយ (១)ឆ្នាំ ទៅប្រាំ (៥) ឆ្នាំ និង ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពីដប់លាន (១០.០០០.០០០) រៀលទៅមួយរយលាន (១០០.០០០.០០០) រៀល ។*

- ***អាជ្ញាធរដែនដី :***

អាជ្ញាធរដែនដី គឺជារដ្ឋអំណាចគ្រប់គ្រងរដ្ឋបាលភូមិ ឃុំ-សង្កាត់ ស្រុក-ខ័ណ្ឌ ខេត្ត-ក្រុង។ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ បានចែងថា រដ្ឋបាលឃុំ-សង្កាត់គ្មានអំណាចមកលើវិស័យព្រៃឈើទេ។

- ***អាជ្ញាធរផ្សេងទៀត :***

ជាស្ថាប័ន ឬ អង្គភាពរបស់រាជរដ្ឋាភិបាល ដូចជា ទីចាត់ការគយ និង រដ្ឋាករ នាយកដ្ឋានកាំកុងត្រូល ក្រសួងបរិស្ថាន ព្រលានយន្តហោះ កំពង់ផែ ស្ថានីយរថភ្លើង ។ល។

- ***ផ្តល់ការអនុញ្ញាតដោយផ្ទាល់ :***

ជាការចេញលិខិតអនុញ្ញាត ឬ ចំណារផ្សេងៗ ឱ្យរូបវន្តបុគ្គល ឬ នីតិបុគ្គលយកទៅធ្វើសកម្មភាពណាមួយ ការផ្តល់មធ្យោបាយ សម្ភារៈ ឬ កំលាំងសំរាប់ធ្វើសកម្មភាពសំដៅការពារ ផ្តល់ការគាំទ្រ ជួយលាក់បាំងជនល្មើស លាក់បាំងវត្ថុតាង ឬ ដោះលែងវត្ថុតាងបទល្មើសព្រៃឈើ ។ល។ ដែលច្បាប់មិនបានផ្តល់សិទ្ធិអំណាចឱ្យ ឬ ផ្ទុយពីច្បាប់ស្តីពីព្រៃឈើ។ ឧទាហរណ៍ : ចេញលិខិតអនុញ្ញាតឱ្យក្រុមហ៊ុនមួយចូលទៅក្នុងដែនព្រៃបំរុងទុកអចិន្ត្រៃយ៍ដើម្បីជីកយកដី ខ្សាច់ ថ្ម រ៉ែ ដែលច្បាប់មិនបានផ្តល់សិទ្ធិអំណាចឱ្យ។ បញ្ជាឱ្យសមត្ថកិច្ចរដ្ឋបាលព្រៃឈើដោះលែងវត្ថុតាងបទល្មើសព្រៃឈើ។

- ***ផ្តល់ការអនុញ្ញាតដោយប្រយោល :***

ជាការផ្តល់ពតិមានឱ្យជនល្មើស មិនចូលរួមសហការជាមួយមន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច ប្រើឈ្មោះសិទ្ធិអំណាច ឋានន្តរសក្តិ មុខងារ តួនាទី ជាខ្នងបង្អែកឱ្យជនល្មើស។

- ***ធ្វើការគំរាមកំហែងដល់មន្ត្រីរដ្ឋបាលព្រៃឈើ ឬ រាំងស្ទះដល់ការបំពេញភារកិច្ច និង កិច្ចប្រតិបត្តិការរបស់មន្ត្រីរដ្ឋបាលព្រៃឈើ :***

ជាការគំរាម សម្លុតបំបាក់ស្មារតី ឬ រារាំង ដោយប្រើប្រាស់អំណាចរបស់ខ្លួនដើម្បីការពារការប្រព្រឹត្តខុសច្បាប់របស់ជនល្មើស។

**<u>ឧទាហរណ៍ទី ១</u> :** អភិបាលខេត្តមួយរូបបានបញ្ជាឱ្យសមត្ថកិច្ចរដ្ឋបាលព្រៃឈើដែលបានចុះចាត់វិធានការតាមច្បាប់លើក្រុមហ៊ុនមួយដែលបានឈូសឆាយដីព្រៃដោយខុសច្បាប់ ត្រូវតែដកកំលាំងរបស់ខ្លួនជាបន្ទាន់ចេញពីទីតាំងឈូសឆាយដីព្រៃនោះ បើពុំនោះទេគាត់នឹងប្រើប្រាស់កំលាំងរបស់គាត់ដើម្បីចាប់ខ្លួនមន្ត្រីរដ្ឋបាលព្រៃឈើវិញ។

**<u>ឧទាហរណ៍ទី ២</u> :** នៅពេលដែលសមត្ថកិច្ចរដ្ឋបាលព្រៃឈើស្នើសុំកិច្ចសហការ និង កំលាំងប្រដាប់អាវុធស្រុកចុះអនុវត្តការរុះរើរបង និង ខ្ទម ដែលជនល្មើសបានកាប់បំផ្លាញព្រៃដាំដើម្បីហ៊ុំព័ទ្ធយកដីធ្វើកម្មសិទ្ធិ លោកអភិបាលស្រុក

ដែលជាប្រធានគណៈបញ្ជាការឯកភាពស្រុក មិនបានផ្តល់កិច្ចសហការ និង ផ្តល់កំលាំងប្រដាប់អាវុធតាមការស្នើសុំនោះទេ ដោយលើកហេតុផលផ្សេងៗទៅវិញ ។

**មាត្រា ១០១.-**

*ចំពោះសកម្មភាពដូចខាងក្រោម ដែលប្រព្រឹត្តឡើងដោយមន្ត្រីរដ្ឋបាលព្រៃឈើត្រូវចាត់ទុកជាបទល្មើស និង ត្រូវផ្តន្ទាទោសជាប់ពន្ធនាគារពីមួយ (១)ឆ្នាំ ទៅប្រាំ (៥)ឆ្នាំ និង ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីដប់លាន (១០.០០០.០០០) រៀល ទៅមួយរយលាន(១០០.០០០.០០០)រៀល :*

*១- ផ្តល់ការអនុញ្ញាតណាមួយដែលផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ។*

*២- ចូលរួមទាំងស្រុង ឬ ដោយផ្នែក និង ដោយផ្ទាល់ ក្នុងសកម្មភាពណាមួយនៃអាជីវកម្មព្រៃឈើដែលផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ។*

*៣- អនុគ្រោះចំពោះបទល្មើសព្រៃឈើណាមួយ ។*

*៤- ប្រកបរបរអាជីវកម្មណាមួយពាក់ព័ន្ធនឹងវិស័យព្រៃឈើ ទោះធ្វើជាម្ចាស់ទាំងស្រុងក្តី ជាម្ចាស់ភាគហ៊ុនក្តី ឬ ធ្វើជានិយោជិក ឬ អ្នកធានាឱ្យអ្នកដទៃក្តី ក្នុងអំឡុងពេលកំពុងកាន់តំណែង ឬ ក្នុងអំឡុងពេលមួយ (១)ឆ្នាំ ក្រោយពីការឈប់កាន់តំណែងដោយប្រការណាក៏ដោយ ។*

*៥- មិនបានរាយការណ៍ ឬ មិនបានដាក់ពាក្យបណ្តឹងចំពោះបទល្មើសព្រៃឈើថ្នាក់ទី ១ ដែលបានកើតក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួនទាន់ពេលវេលា ។*

*៦- ធ្វេសប្រហែសដោយចេតនាក្នុងការបំពេញភារកិច្ច ឬ ផ្តល់ពត៌មានឬរបាយការណ៍ក្លែងបន្លំជាលាយលក្ខណ៍អក្សរដែលជាមូលហេតុបង្កឱ្យកើតមានបទល្មើសព្រៃឈើថ្នាក់ទី ១ ។*

ដើម្បីឱ្យមានសមភាព និង សម្ធាភាពក្នុងការអនុវត្តច្បាប់ ច្បាប់ស្តីពីព្រៃឈើក៏បានកំណត់ទោសទណ្ឌដល់មន្ត្រីរដ្ឋបាលព្រៃឈើដែលបានប្រព្រឹត្តខុសដូចមានចែងក្នុងមាត្រានេះ មិនអាចយកមាត្រាណាផ្សេងក្រៅពីមាត្រានេះក្នុងច្បាប់ស្តីពីព្រៃឈើ មកផ្តន្ទាទោសចំពោះមន្ត្រីរដ្ឋបាលព្រៃឈើដែលបានអនុវត្តខុសបានទេ។ ប៉ុន្តែ ការផ្តន្ទាទោសណាមួយចំពោះមន្ត្រីរដ្ឋបាលព្រៃឈើត្រូវពិចារណាផងដែរអំពីហេតុផល និង ទំហំនៃការប្រព្រឹត្ត ដោយសារមាត្រានេះ មានន័យទូលាយពេក ពុំបានលំអិតអំពីសកម្មភាពណាខ្លះ និង ការប្រព្រឹត្តខុសក្នុងករណីណាដែលត្រូវផ្តន្ទាទោសដល់មន្ត្រីរដ្ឋបាលព្រៃឈើ ។

- ***ផ្តល់ការអនុញ្ញាតណាមួយដែលផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ :***

ក្នុងច្បាប់ស្តីពីព្រៃឈើបានកំណត់អំពីសិទ្ធិអំណាចរបស់មន្ត្រីរដ្ឋបាលព្រៃឈើ ។ ដូចនេះការអនុញ្ញាតណាមួយដែលច្បាប់មិនបានផ្តល់អំណាចឱ្យឬការអនុញ្ញាតណាមួយដែលខុសច្បាប់ស្តីពីព្រៃឈើ មន្ត្រីរដ្ឋបាលព្រៃឈើនោះត្រូវទទួលទោសដូចមានចែងក្នុងមាត្រានេះ។

- ***អនុគ្រោះចំពោះបទល្មើសព្រៃឈើណាមួយ :***

ចំណុចនេះមានន័យទូលំទូលាយពេក មិនបានចែងលំអិតថាតើការអនុគ្រោះចំពោះបទល្មើសព្រៃឈើក្នុងករណីណាដែលមន្ត្រីរដ្ឋបាលព្រៃឈើត្រូវទទួលទោសតាមមាត្រានេះ។ ដូចនេះគួរពិចារណាលើទំហំបទល្មើសព្រៃឈើដែលមន្ត្រីរដ្ឋបាលព្រៃឈើបានអនុគ្រោះ។

ឧទាហរណ៍ : មន្ត្រីរដ្ឋបាលព្រៃឈើបានជួបប្រទះរទេះគោដឹកឈើចំនួន ០៣ គ្រឿង មានម្ចាស់ចំនួន ០៣នាក់) ដឹកឈើមូលប្រមាណ ០ម៣៥០០ ក្នុងមួយគ្រឿង ចេញពីព្រៃបំរុងទុកអចិន្ត្រៃយ៍ ពួកគាត់ទាំងបីនាក់មិនមែនរស់នៅក្បែរតំបន់ព្រៃទេ) ។ ដោយសារការអង្កេត និង ពិនិត្យឃើញថា ពួកគាត់មានភាពក្រីក្រ មន្ត្រីរដ្ឋបាលព្រៃឈើក៏បានអនុញ្ញាតឱ្យពួកគាត់ដឹកឈើនោះចេញទៅ ។ តើកំហុសនេះអាចយកមាត្រានេះមកដាក់ទោសមន្ត្រីរដ្ឋបាលព្រៃឈើដែរឬទេ?

- ***ប្រកបរបរអាជីវកម្មណាមួយពាក់ព័ន្ធនឹងវិស័យព្រៃឈើ ទោះធ្វើជាម្ចាស់ទាំងស្រុងក្តី ជាម្ចាស់ភាគហ៊ុនក្តី ឬ ធ្វើជានិយោជិក ឬ អ្នកធានាឱ្យអ្នកដទៃក្តី ក្នុងអំឡុងពេលកំពុងកាន់តំណែង ឬ ក្នុងអំឡុងពេលមួយ (១)ឆ្នាំ ក្រោយពីការឈប់កាន់តំណែងដោយប្រការណាក៏ដោយ :***

ក្នុងចំណុចនេះមានន័យថា មន្ត្រីរដ្ឋបាលព្រៃឈើគ្រប់រូបដែលកំពុងបំរើការងាររដ្ឋ ឬ ក៏បានឈប់ធ្វើការរដ្ឋ ឬ ត្រូវបានបញ្ឈប់ពីការងាររដ្ឋរយៈពេលមួយឆ្នាំមិនអាចទៅប្រកបរបររកស៊ីណាមួយដែលពាក់ព័ន្ធនឹងវិស័យព្រៃឈើទេ ទោះបីធ្វើជាម្ចាស់ ឬ ចូលភាគហ៊ុនជាមួយគេ ឬ ធ្វើជាកម្មករ បុគ្គលិកនៃព្រៃសម្បទាន ព្រៃគុបក្រៅព្រៃសម្បទាន រោងចក្រ-សហគ្រាសអារឈើ ដេប៉ូទិញ-លក់ផល អនុផលព្រៃឈើ រោងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើ ឬ ក្រុមហ៊ុនរកស៊ីឈើគ្រប់ប្រភេទបានទេ ហើយក៏មិនអាចទៅធានាឱ្យអ្នកផ្សេងក្នុងការធ្វើអាជីវកម្មទាក់ទងនឹងវិស័យព្រៃឈើបានដែរ ។ ប៉ុន្តែមន្ត្រីរដ្ឋបាលព្រៃឈើគ្រប់រូប ក្រោយពីបានលាឈប់ ឬ ត្រូវបានបញ្ឈប់ពីការងាររដ្ឋរយៈពេលមួយឆ្នាំ អាចទៅប្រកបរបរអាជីវកម្មណាក៏បានពាក់ព័ន្ធនឹងវិស័យព្រៃឈើ ហើយក្នុងករណីបានប្រព្រឹត្តខុសច្បាប់ ត្រូវទទួលទោសតាមច្បាប់ស្តីពីព្រៃឈើលើកលែងតែមាត្រា ១០១ នេះ (មាត្រា ១០១ នេះ អាចយកមកអនុវត្តបានចំពោះមន្ត្រីរដ្ឋបាលព្រៃឈើដែលបានប្រព្រឹត្តខុសប៉ុណ្ណោះ) ។

- ***មិនបានរាយការណ៍ ឬ មិនបានដាក់ពាក្យបណ្តឹងចំពោះបទល្មើសព្រៃឈើថ្នាក់ទី ១ ដែលបានកើតក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួនទាន់ពេលវេលា :***

ក្នុងចំណុចនេះមានន័យថា មន្ត្រីរដ្ឋបាលព្រៃឈើគ្រប់រូបដែលមិនបានរាយការណ៍ជូនថ្នាក់លើរបស់ខ្លួន ដើម្បីជ្រាប និង ជួយមានវិធានការ ឬ ក៏ពុំបានដាក់ពាក្យបណ្តឹងទៅតុលាការចំពោះសកម្មភាពបទល្មើសព្រៃឈើថ្នាក់ទី១ (ដូចមានចែងក្នុងមាត្រា ៩៧ នៃច្បាប់ស្តីពីព្រៃឈើ) ដែលបានកើតមានក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយធ្វើមិនដឹងមិនឮ មិនឃើញបទល្មើស ឬ បណ្តែតបណ្តោយឱ្យបទល្មើសព្រៃឈើនោះរីករាលដាលកាន់តែធំ ឬ ទុកឱ្យបទល្មើសព្រៃឈើនោះបានកន្លងផុតពីសំណាញ់ច្បាប់ ។

<u>ឧទាហរណ៍ ១</u> : មានការកាប់រានដីព្រៃធ្វើជាកម្មសិទ្ធិដោយខុសច្បាប់នៅតំបន់ព្រៃបំរុងទុកអចិន្ត្រៃយ៍ក្នុងដែនសមត្ថកិច្ចគ្រប់គ្រងរបស់ខ្លួន បែរជាមន្ត្រីរដ្ឋបាលព្រៃឈើនោះមិនបានចាត់វិធានការចុះពិនិត្យស្រាវជ្រាវរកជនល្មើស និងចងក្រងសំណុំរឿងបទល្មើសទៅតុលាការ ដោយទុកឱ្យបទល្មើសនេះកើតឡើងរាប់ខែទើបចាត់វិធានការតាមនីតិវិធី ។

<u>ឧទាហរណ៍ ២</u> : មានមន្ត្រីរដ្ឋបាលព្រៃឈើម្នាក់បានលួចយកវត្ថុតាងបទល្មើសព្រៃឈើ (ឈើអារ) ដែលមន្ត្រីរដ្ឋបាលព្រៃឈើបានធ្វើការប្រមូលទុកពីការសន្និធិដោយខុសច្បាប់ទៅលក់ដើម្បីយកប្រាក់ជាប្រយោជន៍ផ្ទាល់ខ្លួន ហើយនាយសង្កាត់រដ្ឋបាលព្រៃឈើដែលគ្រប់គ្រងមន្ត្រីនោះ មិនបានចាត់ការប្តឹងមន្ត្រីនោះទៅតុលាការ ។

- ***ធ្វេសប្រហែសដោយចេតនាក្នុងការបំពេញភារកិច្ច ឬ ផ្តល់ពត៌មានឡូវរបាយការណ៍ក្លែងបន្លំជាលាយលក្សណ៍អក្សរដែលជាមូលហេតុបង្កឱ្យកើតមានបទល្មើសព្រៃឈើថ្នាក់ទី ១ :***

  - **ការធ្វេសប្រហែសដោយចេតនាក្នុងការបំពេញភារកិច្ច ដែលជាមូលហេតុបង្កឱ្យកើតមានបទល្មើសព្រៃឈើថ្នាក់ទី១ :** មានន័យថា មន្ត្រីរដ្ឋបាលព្រៃឈើបានដឹង ឬ បានឮ ឬបានទទួលពតិមានថានឹងមានសកម្មភាព

បទល្មើសព្រៃឈើថ្នាក់ទី១កើតឡើងក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ប៉ុន្តែមន្ត្រីរដ្ឋបាលព្រៃឈើនោះមិនបានចាត់វិធានការទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើនោះទេនាំឱ្យបទល្មើសព្រៃឈើថ្នាក់ទី១នោះបានកើតឡើង។

ឧទាហរណ៍ ១ ៖ មានប្រជាពលរដ្ឋម្នាក់បានមករាយការណ៍ជូនសមត្ថកិច្ចរដ្ឋបាលព្រៃឈើថា មានជនមួយក្រុមមានផែនការបាញ់សត្វជីរី នៅក្នុងព្រៃដែលប្រជាពលរដ្ឋធ្លាប់បានឃើញនៅខាងក្រោយភូមិ។ បន្ទាប់ពីបានទទួលពត៌មាននោះមក មន្ត្រីរដ្ឋបាលព្រៃឈើមិនបានចាត់វិធានការស្រាវជ្រាវរកជនដែលប៉ុនប៉ងដើម្បីធ្វើការអប់រំណែនាំឱ្យបញ្ឈប់ផែនការបរបាញ់សត្វជីរីនោះទេ ហើយក៏មិនបានរាយការណ៍ជូនអាជ្ញាធរមូលដ្ឋាន ឬ អង្គការអភិរក្សសត្វព្រៃ ដើម្បីជួយសហការទប់ស្កាត់ដែរ។ ប៉ុន្មានថ្ងៃក្រោយមក សត្វជីរីព្រៃមួយក្បាលត្រូវបានជនល្មើសបាញ់សម្លាប់ដើម្បីយកភ្លុក។ ការបរបាញ់សត្វជីរី (ស្ថិតក្នុងក្រុមប្រភេទសត្វជិតផុតពូជ) ជាបទល្មើសព្រៃឈើថ្នាក់ទី១។

ឧទាហរណ៍ ២ ៖ មានពត៌មានពីលោកប្រធានភូមិម្នាក់ថា មានជនមួយក្រុមមានបំណងនឹងចូលទៅកាប់រានដីព្រៃរបស់រដ្ឋយកដីធ្វើកម្មសិទ្ធិ។ បន្ទាប់ពីបានទទួលពត៌មាននោះមក មន្ត្រីរដ្ឋបាលព្រៃឈើមិនបានចាត់វិធានការណាមួយដើម្បីធ្វើការទប់ស្កាត់ក្រុមជនដែលប៉ុនប៉ងចូលទៅកាប់រានដីព្រៃនោះទេ នាំឱ្យបទល្មើសកាប់រានដីព្រៃនោះបានកើតមានឡើងក្នុងដែនសមត្ថកិច្ចគ្រប់គ្រងរបស់ខ្លួន។ ការកាប់រានដីព្រៃជាបទល្មើសថ្នាក់ទី១។

- **ផ្តល់ពត៌មាននូវរបាយការណ៍ក្លែងបន្លំជាលាយលក្ខណ៍អក្សរ ដែលជាមូលហេតុបង្កឱ្យកើតមានបទល្មើសព្រៃឈើថ្នាក់ទី ១ ៖** មានន័យថា មន្ត្រីរដ្ឋបាលព្រៃឈើបានឃើញ ឬ បានជួបប្រទះបទល្មើសព្រៃឈើថ្នាក់ទី១កើតមានឡើងក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ប៉ុន្តែមន្ត្រីរដ្ឋបាលព្រៃឈើនោះបានរាយការណ៍ជាលាយលក្ខណ៍ អក្សរមកថ្នាក់លើរបស់ខ្លួនថា មិនមានបទល្មើសព្រៃឈើថ្នាក់ទី១ទេ។

ឧទាហរណ៍ ១ ៖ នៅពេលចុះពិនិត្យស្រាវជ្រាវករណីបទល្មើសឈូសឆាយដីព្រៃ ដើម្បីហ៊ុំព័ទ្ធយកដីជាកម្មសិទ្ធិនៅទីតាំងមួយ មន្ត្រីរដ្ឋបាលព្រៃឈើបានរកឃើញថា ដីព្រៃដែលបានឈូសឆាយនោះស្ថិតនៅក្នុងផែនទីគំរបដីព្រៃឆ្នាំ ២០០២។ ដោយមានការត្រូវរ៉ូវគ្នាជាមួយជនល្មើស មន្ត្រីរដ្ឋបាលព្រៃឈើដែលបានចុះទៅពិនិត្យ បានធ្វើរបាយការណ៍ជូនថ្នាក់លើរបស់ខ្លួនថា ដីដែលគេបានឈូសឆាយនោះមិនស្ថិតនៅក្នុងផែនទីគំរបព្រៃឆ្នាំ ២០០២ ទេ។ ការឈូសឆាយដីព្រៃដោយខុសច្បាប់ជាបទល្មើសព្រៃឈើថ្នាក់ទី១។

ឧទាហរណ៍ ២ ៖ នៅពេលចុះពិនិត្យស្រាវជ្រាវករណីបាត់វត្ថុតាងបទល្មើសព្រៃឈើ (ឈើអារ) ដែលបានដកហូតពីជនល្មើស ហើយរក្សាទុកនៅផ្នែករដ្ឋបាលព្រៃឈើ មន្ត្រីរដ្ឋបាលព្រៃឈើថ្នាក់កណ្តាលបានរកឃើញថា មានមន្ត្រីរដ្ឋបាលព្រៃឈើម្នាក់ឈ្មោះ ក បានដឹកយកទៅលក់។ ដោយមានការត្រូវរ៉ូវគ្នាមន្ត្រីរដ្ឋបាលព្រៃឈើដែលបានចុះទៅពិនិត្យស្រាវជ្រាវ បានធ្វើរបាយការណ៍ជូនថ្នាក់លើរបស់ខ្លួនថា រកមិនឃើញមូលហេតុនៃការបាត់វត្ថុតាងទេ។ ការលួចលក់វត្ថុតាងបទល្មើសព្រៃឈើជាបទល្មើសថ្នាក់ទី១។

~~~~~~~~~~~~~~~~~~~~~~~
~~~~~~~~~~~~~~~~~~~~~~~